**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ជំរុញការទាក់ទាញទេសចរណ៍

## ករណីសិក្សាខេត្តបាត់ដំបង

ស្រាវជ្រាវ ពីថ្ងៃទី២៤ ខែឧសភា ដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ**ធុច រត្តនា**

**ឈុន គឹមឡេង**

សាស្ត្រាចារ្យណែនាំ

លោក **ស៊ូ គឹមព្រឹទ្ធា**


ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច    ឆ្នាំចូលសិក្សា ២០១៨

ជំនាន់ទី៨    ឆ្នាំសរសេរសារណា ២០២២

# អារម្ភកថា

ផ្ដើមចេញពីទិដ្ឋភាពប្រវត្តិសាស្ត្រ ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយដែលមានវ័យចំណាស់ និងមានវប្បធម៌ អរិយធម៌ល្បីល្បាញខ្ពង់ខ្ពស់បំផុតក្នុងទ្វីបអាស៊ី ។ ប៉ុន្តែក្រោយសង្គ្រាមស៊ីវិលជាងពីរទសវត្សរ៍កន្លងមកសង្គមកម្ពុជាទាំងមូលត្រូវបានបំផ្លាញស្ទើរតែលាយសាបសូន្យ។ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចគ្រប់វិស័យ និងប្រភពធនធានមនុស្សដែលជាកម្លាំងចលករក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិត្រូវកំទេចស្ទើរគ្មានសល់ ជាពិសេសវិស័យទេសចរណ៍ដែលជាសម្បត្តិបេតិកភណ្ឌជាតិដ៏មានតម្លៃដែលជាផលិតផលទេសចរណ៍។

ដើម្បីឆ្លើយតបនូវសេចក្ដីត្រូវការ ក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ យើងខ្ញុំបានសរសេរសារណាដែលទាក់ទងនឹងប្រធានបទ "**ជំរុញការទាក់ទាញទេសចរណ៍ ករណីសិក្សាខេត្តបាត់ដំបង**" សម្រាប់ជាជំនួយក្នុងការសិក្សាស្វែងយល់ពីទេសចរណ៍ក្នុងប្រទេសយើង ជាពិសេសសម្រាប់សិស្ស និស្សិតដែលចង់ដឹងពីទីតាំងរមណីយដ្ឋាន ចម្ងាយផ្លូវក៏ដូចជាផលិតផលទាក់ទងនឹងទេសចរណ៍ផ្សេងៗទៀត ។ ប្រធានបទនេះអាចទុកជាការចំណេះដឹងមួយផ្នែកសម្រាប់ផ្ដល់ជូន អ្នកដែលចង់សិក្សាស្រាវជ្រាវពីខេត្តបាត់ដំបង និងទីតាំងទេសចរណ៍នានាក្នុងក្រុងផងដែរ។

យើងខ្ញុំទាំងពីរនាក់ជឿជាក់ថា ប្រធានបទ ស្ដីពី "**ជំរុញការទាក់ទាញទេសចរណ៍ ករណីសិក្សាខេត្តបាត់ដំបង**" មិនអាចបញ្ជាក់បានគ្រប់ជ្រុងជ្រោយទាំងអស់ក្នុងភាពជាឯកសារស្រាវជ្រាវផ្លូវការណាមួយបានទេ ជាពិសេសផ្នែកបច្ចេកទេសក្នុងការរៀបចំ និងការសិក្សាស្រាវជ្រាវកម្រិតនេះ ។

អាស្រ័យហេតុនេះ ពួកខ្ញុំមានសេចក្ដីសោមនស្សរីករាយរង់ចាំការរិះគន់កែលម្អស្ថាបនា ពីសាស្ត្រាចារ្យ សិស្សានុសិស្សនិងនិស្សិតទាំងអស់។ ចំពោះរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនានូវពាក្យពេចន៍ វគ្គឃ្លា វេយ្យាករណ៍ អក្ខរក្រម សូមមេត្តាអភ័យទោសដល់ពួកខ្ញុំផង។

ជាចុងក្រោយយើងខ្ញុំសូមអភ័យទោស ដល់អ្នកទាំងអស់គ្នាចំពោះពាក្យឆ្គាំឆ្គងប្រការណាមួយក្នុងសៀវភៅមួយក្បាលនេះ និងសូមថ្លែងអំណរអរគុណដែលបានយកចិត្តទុកដាក់ក្នុងការអានសៀវភៅនេះផងដែរ សូមប្រសិទ្ធិពរជ័យដល់អ្នកទាំងអស់គ្នាឲ្យជួបតែសេចក្ដីសុខ សុភមង្គល កុំបីឃ្លាងឃ្លាតឡើយ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ ជានិស្សិតឆ្នាំទី៤ ជំនាន់ទី៨ ថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារ កិច្ច នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

## សូមគោរពប្រណិបត្តិដោយសេចក្តីកត្តញ្ញូតាធម៌ចំពោះ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនូវគុណូបការៈ ចំពោះមាតាបិតានៃយើងខ្ញុំដែលបានចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ការអប់រំប្រៀនប្រដៅ ជួយផ្គត់ផ្គង់ទំនុកបម្រុងសព្វបែបយ៉ាង ការជួចផ្តើមនូវចំណេះដឹងតាំងពីកុមារដល់បច្ចុប្បន្នដែលលោកបានផ្តល់ទាំងកម្លាំងកាយ និងកម្លាំងចិត្តស្មារតីដល់រូបខ្ញុំ។ បន្ថែមពីលើនេះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងកក់ក្តៅចំពោះ

- លោកឪពុកអ្នកម្តាយជាទីគោរពចំពោះការចិញ្ចឹមបីបាច់ថែរក្សា អប់រំប្រៀនប្រដៅ តាំងពីតូចរហូតមកដល់សព្វថ្ងៃដោយក្តីស្រលាញ់មេត្តាករុណាចំពោះកូន។
- លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យគ្រប់រូបដែលបានជួយបង្ហាត់បង្រៀន ផ្តល់ចំណេះដឹង និងការអប់រំប្រៀនប្រដៅយើងខ្ញុំតាំងពីកុមាររហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។
- លោកសាស្ត្រាចារ្យ **ស៊ូ គឹមព្រឹទ្ធា** ដែលជាសាស្ត្រចារ្យណែនាំសារណា បានជួយពន្យល់ណែនាំយើងខ្ញុំពីមេរៀនយ៉ាងលម្អិតនិងក្បោះក្បាយនូវចំណុចសំខាន់នានា ក្នុងកិច្ចការស្រាវជ្រាវដែលយើងខ្ញុំត្រូវធ្វើការស្រាវជ្រាវចងក្រងធ្វើសារណា។
- លោកគ្រូ **លន់ ពិសិដ្ឋ** ដែលបានជួយពន្យល់ ណែនាំ និងផ្តល់ការមតិយោបល់យ៉ាងក្បោះក្បាយដល់ពួកខ្ញុំ រួចទាំងការជួយត្រួតពិនិត្យកែសម្រួលសារណារបស់ពួកខ្ញុំ។
- លោក **អ៊ុច អ៊ុំភីនីស្សាវ៉ា** ដែលជាប្រធានមន្ទីរទេចរណ៍ខេត្តបាត់ដំបងដែលបានអនុញ្ញាតឲ្យក្រុមសិក្សាស្រាវជ្រាវរបស់ពួកខ្ញុំបានចុះស្រាវជ្រាវនៅខេត្តបាត់ដំបង។
- លោក **នី រស្មី** ដែលជាប្រធានការិយាល័យអប់រំបណ្តុះបណ្តាលនៃមន្ទីរទេសចរណ៍ខេត្ត បាត់ដំបង ដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំផ្តល់នូវបទសម្ភាសន៍យ៉ាងក្បោះក្បាយ និងបានផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំទៀតផង។

- លោក **ហាម អរុណ** ដែលជាប្រធានការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍នៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបងដែលបានផ្តល់នូវបទសម្ភាសន៍យ៉ាងក្បោះក្បាយ និងបានផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំទៀតផង។
- លោក **សោ ប៊ុនថា** ដែលជាមន្ត្រីផ្នែកបច្ចេកទេសនៃមន្ទីទេសចរណ៍ នូវបទសម្ភាសន៍យ៉ាងក្បោះក្បាយ និងបានផ្តល់ឯកសារមួយចំនួនដល់យើងខ្ញុំទៀតផង។
- មិត្តភក្តិដែលបានជួយជ្រោមជ្រែងជាកម្លាំងចិត្ត និងស្មារតីដល់ការសរសេរសារណានេះ។
- ទេសចរដែលបានចំណាយពេល និងចែករំលែកមតិយោបល់ផ្ទាល់ខ្លួន មកកាន់ពួកខ្ញុំ។

ជាចុងក្រោយយើងខ្ញុំសូមជូនពរដល់លោកឪពុកអ្នកម្តាយ លោកគ្រូ អ្នកគ្រូ ក្រុមការងារ ក្រុមគ្រួសារ និងមិត្តភក្តិទាំងអស់គ្នា ជួបតែសំណាងល្អ មានសេចក្តី សេចក្តីចម្រើន និងសូមជួបប្រទះនូវពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាតឃ្លាឡើយ ។

# មាតិកា

ចំណងជើង ទំព័រ


អក្សរកាត់..........ix

បញ្ជីតារាង..........x

បញ្ជីរូបភាព..........xi

បញ្ជីក្រាហ្វិក..........xii

សេចក្ដីផ្ដើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ..........១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ..........២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ..........២

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ..........២

៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ..........២

៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ..........៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..........៤

I. ជំពូកទី១: ការរំលឹកទ្រឹស្ដីដែលពាក់ព័ន្ធ

១.១. និយមន័យទេសចរណ៍..........៥

១.២. ប្រភេទនៃទេសចរណ៍..........៧

១.៣. ព័ត៌មានពីគោលដៅទេសចរណ៍..........៩

១.៤. ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍..........៩

១.៥. អធិរចនាសម្ព័ន្ធ ទេសចរណ៍..........១០

១.៦. ធនធាននិងផលិតផលទេសចរណ៍..........១០

១.៦.១. ធនធានអំណោយផលពីធម្មជាតិ ........................................................ ១០

១.៦.២. ធនធានទាក់ទាញបែបវប្បធម៌ ........................................................ ១០

១.៦.៣. ធនធានមនុស្ស ........................................................ ១១

១.៦.៤. តំបន់ទេសចរណ៍ ........................................................ ១១

១.៧. ការអភិវឌ្ឍទេសចរណ៍........................................................ ១២

១.៨. យុទ្ធសាស្ត្រនៃការគ្រប់គ្រង........................................................ ១៣

II. ជំពូកទី២: ការសិក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ

២.១. ស្ថានភាពទូទៅនៃខេត្តបាត់ដំបង........................................................ ១៤

២.១.១. ស្ថានភាពភូមិសាស្ត្រខេត្តបាត់ដំបង........................................................ ១៤

២.១.២.ប្រវត្តិខេត្តបាត់ដំបង ........................................................ ១៥

២.១.៣. ប្រវត្តិសង្ខេប និងសារៈសំខាន់របស់ក្រុងបាត់ដំបង ........................................................ ១៧

២.១.៤.ស្ថានភាពទេសចរណ៍ខេត្តបាត់ដំបង........................................................ ១៩

២.២. សក្តានុពលទេសចរណ៍ក្នុងក្រុងបាត់ដំបង ........................................................ ២៨

២.២.១. គោលដៅទាក់ទាញទេសចរ........................................................ ២៨

២.៣. ទីតាំងភូមិសាស្ត្រនៃតំបន់គោលដៅនីមួយៗនៅក្នុងក្រុងបាត់ដំបង........................................................ ៣០

២.៤. គោលបំណង និងគោលដៅនៃការអភិវឌ្ឍទេសចរណ៍វប្បធម៌ក្រុង........................................................ ៤០

២.៤.១. ចក្ខុវិស័យ........................................................ ៤០

២.៤.២. ទស្សនវិស័យ........................................................ ៤១

២.៤.៣. គោលបំណងនៃការអភិវឌ្ឍទេសចរណ៍វប្បធម៌ក្រុង ........................................................ ៤១

២.៤.៤. ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍ ........................................................ ៤៣

២.៥. យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្រុងបាត់ដំបង........................................................ ៤៧

២.៥.១. ការរៀបចំវិធីវប្បធម៌ភូមិវត្តគរ........................................................ ៤៧

២.៥.២. ការរៀបចំតំបន់សំណង់អភិរក្ស ........................................................................ ៥៥

III. ជំពូកទី៣: របកគំហើញនៃការសិក្សាស្រាវជ្រាវ

៣.១.របកគំហើញនៃការសិក្សាស្រាវជ្រាវទេសចរណ៍........................................................................ ៥៧
៣.១.១. របកគំហើញនៃការសិក្សាស្រាវជ្រាវលើសញ្ជាតិ ........................................................................ ៥៧
៣.១.២. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើភេទ ........................................................................ ៥៨
៣.១.៣. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើអាយុ........................................................................ ៥៨
៣.១.៤. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើមុខរបរ ........................................................................ ៥៩
៣.១.៥. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើបរិស្ថានក្នុងតំបន់គោលដៅ ................................ ៦០
៣.១.៦. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើហេដ្ឋារចនាសម្ព័ន្ធ ............................................ ៦០
៣.១.៧. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើអនាម័យក្នុងតំបន់គោលដៅ .............................. ៦១
៣.១.៨. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការស្គាល់តំបន់គោលដៅ.................................. ៦២
៣.១.៩. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើមធ្យោបាយធ្វើដំណើរ........................................ ៦២
៣.១.១០. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើគោលបំណងនៃធ្វើដំណើរទៅកាន់គោលដៅ ........ ៦៣
៣.១.១១. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើប្រភេទគោលដៅដែលមាននៅក្នុងក្រុងបាត់ដំបង .. ៦៤
៣.១.១២. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើឱកាសនៃការធ្វើដំណើរកម្សាន្ត .......................... ៦៤
៣.១.១៣. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើសេវាកម្មបម្រើដល់ទេសចរណ៍ .......................... ៦៥
៣.១.១៤. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការពេញចិត្តនៃសេវាកម្ម.................................. ៦៦
៣.១.១៥. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការយល់ឃើញពីសេវាកម្មថាគ្រប់គ្រាន់ទេ............ ៦៧
៣.១.១៦. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើរយៈពេលនៃការមកកម្សាន្ត .............................. ៦៨
៣.១.១៧. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើសន្តិសុខសុវត្ថិភាពក្នុងតំបន់គោលដៅ............... ៦៨
៣.១.១៨. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការវិលត្រឡប់មកកម្សាន្តជាថ្មីម្តងទៀត ............... ៦៩
៣.១.១៩. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការផ្សព្វផ្សាយពីតំបន់គោលដៅ......................... ៧០

៣.១.២០.របកគំហើញនៃការសិក្សាស្រាវជ្រាវលើការពន្យាពេលស្នាក់នៅរបស់ទេសចរដោយបង្កើនផលិតផលទេចរណ៍ ......................................................................................................៧២

៣.២. ការសិក្សាវិភាគពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង ..................................៧៣

៣.២.១. ចំណុចខ្លាំង..........................................................................................................៧៣

៣.២.២. ចំណុចខ្សោយ ......................................................................................................៧៥

៣.២.៣. ឱកាស ...............................................................................................................៧៦

៣.២.៤. ការគំរាមកំហែង ...................................................................................................៧៨

IV. ជំពូកទី៤: សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៤.១. សេចក្ដីសន្និដ្ឋាន..........................................................................................................៧៩

៤.២. ការផ្ដល់អនុសាសន៍ .....................................................................................................៧៩

ឯកសារយោង ................................................................................................................... ៨១

ឧបសម្ព័ន្ធ ......................................................................................................................... ៨២

# អក្សរកាត់

UNWTO= United Nation World Tourism Organization.................................................៦

# បញ្ជីតារាង

ចំណងជើង ទំព័រ

តារាងទី១៖ ប្រភពមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ....................................................................... ២៣

តារាងទី២៖ ប្រភពមន្ទីរទេសចរណ៍ខេត្តបាត់ដំបង (ទីតាំងលក់វត្ថុអនុស្សាវរីយ៍)..................................... ២៤

តារាងទី៣៖ ទិន្នន័យទេសចរឆ្នាំ២០១៦-២០២០(ប្រភពៈមន្ទីរទេសចរណ៍ខេត្តបាត់ដំបងឆ្នាំ២០២០) ........... ២៦

# បញ្ជីរូប

ចំណងជើង ទំព័រ


រូបភាពទី១៖ ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងខេត្តបាត់ដំបង (ប្រភព៖អនុក្រឹត្យលេខ៨០ ចុះថ្ងៃទី១៣ មិថុនា ២០១៨)........ ១៥

រូបភាពទី២៖ ផែនទីសង្កាត់ក្នុងក្រុងបាត់ដំបង ........ ២៧

រូបភាពទី៣៖ ភ្ញៀវទេសចរណ៍ទស្សនាខេត្តបាត់ដំបង ២០១៦ ដល់ឆ្នាំ ២០២០ ........ ២៨

រូបភាពទី៤៖ ស្ពានថ្មចាស់នាក្រុងបាត់ដំបង........ ៣១

រូបទី៥៖ សារៈមន្ទីរប្រវត្តិសាស្ត្រខេត្ត........ ៣២

រូបភាពទី៦៖ សារៈមន្ទីរវប្បធម៌........ ៣៣

រូបភាពទី៧៖ សំណង់អគារអភិរក្ស ........ ៣៤

រូបភាពទី៨៖ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ........ ៣៦

រូបភាពទី៩៖ ផ្ទះខ សង ផ្ទះបុរាណនាក្រុងបាត់ដំបង........ ៣៨

រូបភាពទី១០៖ ផ្ទះបុរាណ ផ្ទះប៉ិត ........ ៤០

រូបភាពទី១១៖ ថ្ងៃទី១ នៃការជួបជាមួយបងៗនៅមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ........ ៩០

រូបភាពទី១២៖ ថ្ងៃទី១ នៃការជួបជាមួយបងៗនៅមន្ទីរទេសចរណ៍ខេត្តបាត់ដំបង........ ៩០

រូបភាពទី១៣៖ ថ្ងៃទី២ នៃការជួបជាមួយបងៗនៅមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ........ ៩១

រូបភាពទី១៤៖ ផ្ទះបុរាណភូមិវត្តគរ ផ្ទះខ សង(លោកយាយបានរៀបរាប់ពីប្រវត្តិផ្ទះ) ........ ៩១

រូបភាពទី១៥៖ ផ្ទះបុរាណភូមិវត្តគរ ផ្ទះប៉ិត ........ ៩២

រូបភាពទី១៦៖ ឧបករណ៍នៅកខាងក្រោម ផ្ទះបុរាណភូមិវត្តគរ ផ្ទះប៉ិត ........ ៩២

រូបភាពទី១៧៖ របងសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង ........ ៩៣

រូបភាពទី១៨៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសំណង់អគារបារាំង ........ ៩៣

រូបភាពទី១៩៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសំណង់អគារបារាំង ...................................... ៩៤

រូបភាពទី២០៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសារមន្ទីរវប្បធម៌............................................ ៩៤

រូបភាពទី២១៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសារមន្ទីរវប្បធម៌............................................ ៩៥

រូបភាពទី២២៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសំណង់អគារបារាំង ...................................... ៩៥

រូបភាពទី២៣, ២៤៖ ផ្ទះបុរាណផ្ទះប៉ិត ......................................................................................... ៩៦

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១៖ ការបង្ហាញពីសញ្ជាតិ ................................................ ៥៧

ក្រាហ្វិកទី២៖ ការបង្ហាញពីភេទ ................................................ ៥៨

ក្រាហ្វិកទី៣៖ ការបង្ហាញពីអាយុ ................................................ ៥៩

ក្រាហ្វិកទី៤៖ ការបង្ហាញពីមុខរបរ ................................................ ៥៩

ក្រាហ្វិកទី៥៖ បរិស្ថាននៅតំបន់គោលដៅ ................................................ ៦០

ក្រាហ្វិកទី៦៖ ហេដ្ឋារចនាសម្ព័ន្ធ ................................................ ៦១

ក្រាហ្វិកទី៧៖ អនាម័យក្នុងតំបន់គោលដៅ ................................................ ៦១

ក្រាហ្វិកទី៨៖ ការស្គាល់ពីតំបន់គោលដៅ ................................................ ៦២

ក្រាហ្វិកទី៩៖ មធ្យោបាយធ្វើដំណើរ ................................................ ៦៣

ក្រាហ្វិកទី១០៖ គោលបំណងក្នុងការកម្សាន្ត ................................................ ៦៣

ក្រាហ្វិកទី១១៖ ប្រភេទគោលដៅក្នុងក្រុងបាត់ដំបង ................................................ ៦៤

ក្រាហ្វិកទី១២៖ ឱកាសក្នុងការទៅកម្សាន្ត ................................................ ៦៥

ក្រាហ្វិកទី១៣៖ សេវាកម្មបម្រើដល់ទេសចរក្នុងតំបន់គោលដៅ ................................................ ៦៦

ក្រាហ្វិកទី១៤៖ ការពេញចិត្តចំពោះសេវាកម្មបម្រើដល់ទេសចរក្នុងតំបន់គោលដៅ ................................................ ៦៧

ក្រាហ្វិកទី១៥៖ ភាពគ្រប់គ្រាន់នៃសេវាកម្មបម្រើដល់ទេសចរក្នុងតំបន់គោលដៅ ................................................ ៦៧

ក្រាហ្វិកទី១៦៖ រយៈពេលនៃការមកកម្សាន្ត ................................................ ៦៨

ក្រាហ្វិកទី១៧៖ សុខសុវត្ថិភាពនៅតំបន់ទេសចរណ៍ក្នុងក្រុង ................................................ ៦៩

ក្រាហ្វិកទី១៨៖ ការវិលត្រឡប់មកវិញ ................................................ ៦៩

ក្រាហ្វិកទី១៩៖ ការផ្សព្វផ្សាយពីតំបន់គោលដៅ ................................................ ៧០

ក្រាហ្វិកទី២០៖ ការពន្យាពេលស្នាក់នៅ ................................................ ៧១

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

វិស័យទេសចរណ៍ ជាវិស័យមួយដែលមានឥទ្ធិពលមួយផ្នែកធំក្នុងការជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន។ ជាក់ស្តែងវិស័យមួយនេះបាននាំមកនូវប្រាក់ចំណូលប្រហែលជា ១.៤៧ ទ្រីលាន ដុល្លារ ក្នុងឆ្នាំ២០១៩កន្លងទៅ ដែលមានចំនួនប្រហែល ១.៥៣ពាន់លាននាក់នៅជុំវិញពិភពលោក តាមរយៈ ចំណូលដែលបានមកពីទេសចរណ៍នេះបានធ្វើឱ្យការរស់នៅរបស់ប្រជាជនមានការរីកចម្រើន សម្បូរសប្បាយ ជាពិសេសមានការអភិវឌ្ឍទៅលើសមត្ថភាព ធនធានមនុស្សក្នុងសង្គម។ វាក៏ជាផ្នែកមួយក្នុងការចូលរួមចំណែក ក្នុងការអភិវឌ្ឍ និងអភិរក្សថែរក្សាធនធានវប្បធម៌ និងធម្មជាតិជាសកល ។ យ៉ាងណាមិញ ប្រទេសកម្ពុជាជាប្រទេសមួយដែលស្ថិតនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ដែលនៅចន្លោះមហាអំណាចពីរ មហាអំណាចវប្បធម៌ គឺ ឥណ្ឌា និងចិន។ ប្រទេសឥណ្ឌាជាមហាអំណាចវប្បធម៌ដែលបាននាំមកនូវវប្បធម៌ដែលបាននាំមកនូវវប្បធម៌ដ៏ច្រើនជាក់ស្តែកមានដូចជា នាសម័យហ្វូណន សម័យចេនឡាជាដើម ឯប្រទេសចិនបានមកនូវជំនួញជួញដូរ ដែលបានធ្វើឱ្យប្រជាជនកម្ពុជាចេះធ្វើជំនួញជួញដូរ ជាក់ស្តែងបានបង្ហាញក្នុងសិលាចារឹកនាប្រាសាទអង្គរវត្ត រួមទាំងមានការកំណាយប្រវត្តិសាស្ត្រមួយចំនួន ឧទាហរណ៍មាននៅកំពង់ផែអូកែវជាដើម ។ ប្រទេសកម្ពុជាស្ថិតនៅតំបន់អាស៊ីភាគអាគ្នេយ៍ដែលសម្បូរដោយធនធានវប្បធម៌ ធនធានធម្មជាតិដែលធនធានទាំងពីរនេះ អាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបម្រើឲ្យវិស័យទេសចរណ៍ ។ វិស័យទេសចរណ៍របស់កម្ពុជាត្រូវបានកំណត់ជាវិស័យអាទិភាព និងជាមាសបៃតង ដោយបានបង្កើតនូវកាលានុវត្តភាពការងារ លើកកម្ពស់ជីវភាពរស់នៅ និងបង្កើនប្រាក់ចំណូលជាតិ។ បើគិតចាប់តាំងពីសម័យកាលលោកម្ចាស់ រហូតដល់សម័យសង្គមរាស្ត្រនិយម យើងអាចសង្កេតឃើញពីសំណង់ប្រវត្តិសាស្ត្រ ដែលបានបន្សល់ទុកមកជាច្រើនដែលស្ថិតក្នុងក្រុងបាត់ដំបង ។ យ៉ាងណាមិញប្រទេសកម្ពុជាជាប្រទេសមួយដែលទទួលរងនូវសង្គ្រាមមនោគមន៍វិជ្ជា ជាប្រវត្តិសាស្ត្រកម្ពុជាស្ថិតនៅក្រោមអាណានិគមរបស់ប្រទេសបារាំងជិត១០០ឆ្នាំ ដែលនៅសម័យនោះបារាំងបានបន្សល់ទុកនូវសំណង់មួយចំនួន សុទ្ធតែជាសំណង់ប្រវត្តិសាស្ត្រហើយជាធនធានមួយក្នុងការទាក់ទាញទេសចរណ៍ ដែលរាយប៉ាយពេញផ្ទៃប្រទេសដោយក្នុងនោះមានឃើញនៅក្នុងខេត្តបាត់ដំបង ជាខេត្តមួយដែលសម្បូរទៅដោយសំណង់ប្រវត្តិសាស្ត្រតាំងពីអតីតកាល ជាពិសេសស្ថិតក្រុងបាត់ដំបង ។ សំណង់ប្រវត្តិសាស្ត្រទាំងអស់នេះបានជម្រុញ និងលើកទឹកចិត្តឲ្យមានការទាក់ទាញទេសចរណ៍ ក្រុងមួយនេះសម្បូរដោយធនធានវប្បធម៌ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងខេត្តបាត់ដំបងទាំងមូល ក៏ដូចជាស្ថិតក្នុងក្រុងបាត់ដំបង គឺត្រូវបានកំណត់ថាជាតំបន់ទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ ដោយសក្តានុពលទេសចរណ៍ក្នុងតំបន់នេះភាគច្រើន គឺពោរពេញទៅដោយលក្ខខណ្ឌធម្មជាតិដ៏ស្រស់ត្រកាល និងកេរ្តិ៍ដំណែលប្រពៃណីនិងវប្បធម៌បុរាណដ៏សម្បូរបែប ។ ប៉ុន្តែរហូតមកដល់សព្វថ្ងៃ ទីក្រុងដ៏ចំណាស់មួយនេះនៅតែពុំទាន់បានប្រែក្លាយមុខមាត់អាចស្រូបទាញទេចរចូលមកទស្សនាកម្សាន្ត ក្នុងចំនួនច្រើនស័ក្តិសមទៅនឹងភាពអស្ចារ្យរបស់ខ្លួននោះនៅឡើយទេ ។ ដោយយល់ឃើញនូវបញ្ហាទាំងនេះ យើងខ្ញុំជាក្រុមអ្នកសិក្សាស្រាវជ្រាវក៏មានចំណាប់អារម្មណ៍ ហើយមានចម្ងល់ថាតើមូលហេតុអ្វីខ្លះទៅ ដែល បណ្តាលឲ្យទីក្រុងនេះមិនទាន់អាចទាក់ទាញទេសចរបានច្រើន? ហើយថាតើយើងអាចនឹងមានវិធី ឬមធ្យោបាយយ៉ាងណា ជួយជំរុញលទ្ធភាពទីក្រុងនេះក្នុងការទាក់ទាញទេសចរមកទស្សនានូវសក្តានុពលវប្បធម៌ដ៏សម្បូរបែបទាំងនេះនាពេលអនាគត?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ដើម្បីបកស្រាយបង្ហាញនូវបញ្ហា ដែលកើតឡើងពីចំណាប់អារម្មណ៍នៃក្រុមអ្នកសិក្សាស្រាវជ្រាវ បានចោទសួរខាងលើឱ្យល្អិតល្អន់ និងអាចឱ្យចម្លើយនោះប្រកបដោយភាពសុក្រិតត្រឹមត្រូវច្បាស់លាស់ ការសិក្សាបានកំណត់បែងចែកនូវគោលបំណង ដែលត្រូវទៅសិក្សាដូចខាងក្រោម៖

- គោលបំណងទី១៖ ជំរុញឱ្យមានការអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌នៅក្នុងក្រុងបាត់ដំបង
- គោលបំណងទី២៖ បង្កើនការទាក់ទាញទេសចរណ៍ស្របទៅតាមការអភិវឌ្ឍខាងលើ
- គោលបំណងទី៣៖ យន្តការនៃការអភិវឌ្ឍ និងអភិរក្ស ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានផ្តោត ទៅលើការជំរុញការទាក់ទាញទេសចរណ៍វប្បធម៌ក្នុងក្រុងបាត់ដំបងតែប៉ុណ្ណោះ ដែលជាតំបន់គោលដៅបែបវប្បធម៌ប្រវត្តិសាស្ត្ររាប់គិតចាប់ពីសម័យបាត់ដំបងសម័យលោកម្ចាស់រហូតដល់សង្គមរាស្ត្រនិយមដែលជាសម័យកាលមួយដែលប្រទេសកម្ពុជាស្ថិតក្នុងការរីកចម្រើនយ៉ាងខ្លាំងដោយមានការធ្វើដំណើរតាមផ្លូវដែកផងដែរ។

# ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៥.១. ប្រភពទិន្នន័យ

ទិន្នន័យដែលយកមកសិក្សាស្រាវជ្រាវនេះគឺបានដកស្រង់មួយផ្នែកចេញពី បណ្ណាល័យសាកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បណ្ណាល័យសាកលវិទ្យាជាតិគ្រប់គ្រង ក្រសួងទេសចរណ៍ក្រុងភ្នំពេញ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង សហគមន៍ទេសចរណ៍វប្បធម៌វត្តគរ អត្ថបទមេរៀនសៀវភៅពុម្ពមុខវិជ្ជាសិក្សាកន្លងដែលបានសិក្សាពីឆ្នាំមូលដ្ឋានដល់ឆ្នាំទី៤ ប្រព័ន្ធផ្សព្វផ្សាយសង្គម (Social Media) បណ្តាញប្រព័ន្ធអ៊ីនធើណេត និងការចុះអង្កេតដោយផ្ទាល់។

## ៥.២. ការប្រមូលទិន្នន័យ

ក្នុងការសិក្សាស្រាវជ្រាវនេះពួកយើងបានប្រមូលទិន្នន័យដោយការសម្ភាសន៍ផ្ទាល់ជាមួយប្រធានការិយាល័យអប់រំ និងបណ្តុះបណ្តាលនៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ប្រធានការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍នៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបង មន្ត្រីផ្នែកបច្ចេកទេសនៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ការទទួលបានឯកសារនានាដែលទទួលបានពីសំណាក់មន្ទីរ និងមានការសម្ភាសន៍ជាមួយទេសចរដែលបានទៅកម្សាន្តតំបន់គោលដៅនានាក្នុងក្រុងបាត់ដំបង។

## ៥.៣. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យគឺធ្វើឡើងតាមរយៈការប្រមូលចម្លើយបានពីការសម្ភាសន៍ចំនួន២៥ គំរូតាងដោយគណនាជាភាគរយនៃចម្លើយគំរូតាងទាំងអស់នោះដោយប្រើប្រាស់កម្មវិធី Microsoft Excel លើការបង្កើតជាក្រាប រួមទាំងមានស្ថានភាពជាក់ស្តែងក្នុងឯកសារក៏ដូចជាទិដ្ឋភាពពិតជាក់ស្តែង។

# ៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

តាមរយៈរបកគំហើញនៃការសិក្សាស្រាវជ្រាវនេះបានផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋសហគមន៍ក្នុងការចូលរួមអភិវឌ្ឍន៍សហគមន៍តាមរយៈលំហូរនៃទេសចរណ៍ អាជ្ញាធរដែនដី មន្ទីរទេសចរណ៍ខេត្តបាត់ដំបងអាចប្រើប្រាស់អត្ថបទស្រាវជ្រាវនេះក្នុងការបំពេញបន្ថែមនូវចំណុចខ្វះខាតដែលកើតមាន ដោយឡែកនេះអត្ថបទសិក្សាស្រាវជ្រាវនេះជាផ្នែកមួយក្នុងការផ្តល់ពុទ្ធិដល់សិស្សនិស្សិតជំនាន់ក្រោយយកមកសិក្សាស្រាវជ្រាវបន្ត។

ប្រធានបទនៃការស្រាវជ្រាវនេះអាចទុកជាប្រធានបទមួយសម្រាប់ផ្តល់ជាទ្រឹស្តី និងការអនុវត្តជាក់ស្តែងក្នុងការអភិវឌ្ឍទេសចរណ៍ ដែលមានការចូលរួមពីប្រជាជនក្នុងតំបន់ និងស្ថាប័នដែលពាក់ព័ន្ធ តាមរយៈឯកសារ

យោងជាច្រើន ការចុះអង្កេត និងធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីពាក់ព័ន្ធ និងទេសចរ។ សម្រាប់ប្រធានបទនេះ សារៈសំខាន់នៃដូចជា៖

- អាជ្ញាធរដែនដីនៃក្រុងបាត់ដំបងអាចប្រើប្រាស់អត្ថបទស្រាវជ្រាវនេះសម្រាប់ការបំពេញបន្ថែមនូវចំនុចខ្វះខាតមួយចំនួនដែលកើតមាន។
- មន្ទីរទេសចរណ៍ខេត្តបាត់ដំបងអាចទុកជាឯកសារសម្រាប់បំពេញនូវភាពខ្វះខាតនូវចំនុចណាមួយដែលចាំបាច់។
- សិស្សនិស្សិតជំនាន់ក្រោយអាចទុកជាពុទ្ធិចំណេះដឹង សម្រាប់ការសិក្សាស្វែងយល់បន្ថែមទៀត។
- សម្រាប់ជំរុញដល់ការអភិវឌ្ឍប្រជាពលរដ្ឋនៅក្នុងសហគមន៍ដើម្បីឱ្យសហគមន៍ទទួលបានការអភិវឌ្ឍ និងអភិរក្សជានិរន្តន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានរៀបចំជាដូចតទៅ៖

សេចក្តីផ្តើម៖ ក្នុងអត្ថបទដែលបានបង្ហាញឱ្យស្គាល់ពីប្រធានបទ ចំណោទបញ្ហានៃប្រធានបទ គោលបំណងនៃការជ្រើសរើសយកប្រធានបទ ទំហំនៃការសិក្សាស្រាវជ្រាវ និងដែនកំណត់នៃប្រធានបទ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធការសិក្សាស្រាវជ្រាវ។

ជំពូកទី១៖ រំលឹកទ្រឹស្តីដែលពាក់ព័ន្ធ

ជំពូកទី២៖ ការសិក្សាលើស្ថានភាពទូទៅនៃការស្រាវជ្រាវ

ជំពូកទី៣៖ របកគំហើញនៃការស្រាវជ្រាវ

ជំពូកទី៤៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ឯកសារយោង៖ បង្ហាញពីឯកសារ និងប្រភពឯកសារដែលបានលើកយកមកសិក្សាស្រាវជ្រាវក្នុងសារណានេះ។

ឧបសម្ព័ន្ធ៖ ទាក់ទងនឹងលិខិតអនុញ្ញាតពីមូលដ្ឋានណាមួយក្នុងការសុំចុះសិក្សាស្រាវជ្រាវ សម្ភាសន៍ ផ្តិតកម្រង រូបភាព ទទួលយកឯកសារពាក់ព័ន្ធនានាដោយស្របច្បាប់។

# ជំពូកទី១

# ការរំលឹកទ្រឹស្តីដែលពាក់ព័ន្ធ

## ១.១ និយមន័យទេសចរណ៍

ពាក្យ ទេសចរណ៍ ត្រូវបានគេលើកមកកំណត់និងផ្តល់និយមន័យជាច្រើនមកហើយតែ មកទល់សព្វថ្ងៃនេះពុំទាន់បានត្រូវបញ្ចប់ជាស្ថាពរនោះទេ។ មានអ្នកប្រាជ្ញ និងអ្នកនិពន្ធសៀវភៅទាក់ទងនឹងផ្នែកទេសចរណ៍ បានកំណត់បញ្ញត្តិទេសចរណ៍ខុសៗគ្នាដូចខាងក្រោម៖

**ទេសចរណ៍** សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់មួយដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នាដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងទៀត។[1]

**ទេសចរណ៍** ជាការធ្វើសកម្មភាពកម្សាន្ត ដែលមានឥទ្ធិពលទៅលើការពង្រឹងសុខភាព ការរីកចម្រើន និងការអភិវឌ្ឍកម្លាំងកាយ និងចិត្តរបស់មនុស្សដែលធ្វើចលនា ឬធ្វើដំណើរ ចេញពីកន្លែងរស់នៅប្រចាំក្នុងរយៈពេលកំណត់មួយ។

និយមន័យ **ទេសចរណ៍** ក៏ត្រូវបានគេកំណត់ថាកើនឡើងពីភាសាអង់គ្លេស Tourism (Tour) ត្រូវបានទទួលស្គាល់ថា ជាការដើរលេងកម្សាន្តដោយថ្មើរជើង ឬការប្រើប្រាស់ យានជំនិះណាមួយ និងវិលត្រឡប់មកទីកន្លែងដែលចេញដំណើរវិញ ក្រោយពីបញ្ចប់សកម្មភាពនេះ។ មានការកំណត់ផ្សេងទៀតថា ទេសចរណ៍ជាការធ្វើដំណើរ ឬជាប្រភេទចលនារបស់មនុស្សដែលមិនទាក់ទងនឹងការផ្លាស់ប្តូរទីកន្លែងរស់នៅ និងស្វែងរកការងារ មានន័យថាជាការធ្វើដំណើរក្នុងបំណងសម្រាកលំហែកាយ និងអារម្មណ៍។ ជាការពិតណាស់ ទេសចរណ៍ត្រូវបានចាត់ទុកថាជាការផ្លាស់ប្តូរទីរបស់មនុស្សជាបណ្តោះអាសន្ន ដើម្បីឆ្ពោះទៅគោលដៅណាមួយ ដែលស្ថិតនៅក្រៅពីកន្លែងធ្វើការ និងលំនៅដ្ឋានប្រក្រតី។

**ទេសចរណ៍** ជាការធ្វើដំណើរក្នុងរយៈពេលមួយរបស់ពលរដ្ឋ ឬមហាជនពីទីស្នាក់នៅ(ផ្ទះ) របស់ខ្លួនទៅកាន់ប្រទេសណាមួយ ឬតំបន់ណាមួយក្នុងប្រទេស នាពេលទំនេរក្រៅពីការងារ ក្នុងគោលបំណងទទួលបានការសប្បាយរីករាយ សម្រាក ព្យាបាល ភៀវ ទស្សនកិច្ច ស្វែងយល់សាសនា និងការងារធុរកិច្ច តែមិនត្រូវបានអនុញ្ញាតឱ្យបំពេញការងារដែលទទួលបាននូវប្រាក់ ក្នុងតំបន់ដែលបានទៅដល់។

[1] ច្បាប់ស្តីពីទេសចរណ៍ ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩

តាមវចនានុក្រមអុកស្វឹត (Oxford Learner`s Pocket Dictionary) **ទេសចរណ៍** គឺជាសកម្មភាពជំនួញដែលទាក់ទងទៅនឹងការផ្តល់ទីកន្លែងស្នាក់នៅ សេវាផ្សេងៗ និងការកម្សាន្តដល់មនុស្សដែលទៅទស្សនាទីកន្លែងណាមួយដើម្បីភាពសប្បាយរីករាយ។

សរុបសេចក្តីមកយើងអាចកំណត់អត្ថន័យ **ទេសចរណ៍** គឺជាវិស័យមួយដែលមានឥទ្ធិពលយ៉ាងសម្បើមទាំងវិជ្ជមាន និងអវិជ្ជមាន លើការរស់នៅរបស់មនុស្ស និងលើបរិស្ថានជាដើម។ ដោយសារតែទេសចរណ៍ ទើបធ្វើឱ្យមនុស្សមានការលំហែកម្សាន្តពីការងារ និងអាចផ្លាស់ប្តូរវប្បធម៌ពីមួយទៅមួយតាមរយៈការប្រាស្រ័យទាក់ទងគ្នា។ ក្រៅពីនេះ យើងក៏អាចទាញបានផលប្រយោជន៍ជាច្រើនពីសំណាក់ទេសចរណ៍ទាំងសេវាកម្មក៏ដូចជាតំបន់ទេសចរណ៍ ឬសម្បទានានាដែលយើងមាន ដោយអភិវឌ្ឍន៍តំបន់ទេសចរណ៍ទាំងនោះឱ្យមានភាពទាក់ទាញ។

ចំពោះពាក្យ **ទេសចរ ឬ (Tourist)** ក៏មានអ្នកប្រាជ្ញ និងអ្នកស្រាវជ្រាវខាងវិស័យទេសចរណ៍លើកយកមកកំណត់និងផ្តល់និយមន័យឱ្យជាច្រើនលើកមកហើយ តែមកទល់សព្វថ្ងៃនេះ នៅពុំទាន់បានត្រូវបានបញ្ចប់ជាស្ថាពរនោះទេ។ នេះដោយហេតុថា សកម្មភាពទេសចរណ៍តែងតែវិវត្តន៍ស្របនឹងការវិវត្តន៍នៃសេដ្ឋកិច្ច សង្គម គំនិត និងការចង់បានរបស់ទេសចរ។

**ទេសចរ** សំដៅដល់អ្នកធ្វើដំណើរចេញពីបរិយាកាសប្រក្រតី ហើយប្រើប្រាស់សេវាកម្មទេសចរណ៍ដោយមានរយៈពេលលើសពី ២៤ម៉ោង និងមិនលើសពីមួយឆ្នាំជាប់ៗគ្នាក្នុងគោលបំណងទេសចរណ៍ និងមិនទាក់ទងដល់ការតាំងលំនៅដ្ឋាន ឬធ្វើសកម្មភាពរកប្រាក់កម្រៃឡើយ។

បើផ្តោតទៅលើគេហទំព័ររបស់ UNWTO វិញ **ទេសចរ** គឺសំដៅទៅលើមនុស្សដែលធ្វើដំណើរទៅកាន់ប្រទេសមិនមែនជាកន្លែងជាកន្លែងដែលគេធ្លាប់នៅ តែក្រៅពីបរិយាកាសដែលគេរស់នៅក្នុងកំឡុងពេល១២ខែ ក្នុងគោលបំណងសំខាន់ គឺទស្សនាកម្សាន្តជាជាងរកប្រាក់ចំណូលពីប្រទេសដែលខ្លួនទៅ។ ចង់និយាយពីអ្នកដែលស្នាក់នៅយ៉ាងហោចណាស់មួយយប់ក្នុងលក្ខណៈឯកជនក្នុងប្រទេសដែលខ្លួនដែលទៅកម្សាន្ត។

ច្បាប់ស្តីពីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់និយមន័យ **ទេសចរ** សំដៅដល់បុគ្គលទាំងឡាយជាជនជាតិកម្ពុជា ឬជនបរទេសដែលមកដល់តំបន់ផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលបានកំណត់ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀតព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ។[2]

---

[2] ច្បាប់ស្តីពីទេសចរណ៍ ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩

សរុបសេចក្ដីមក **ទេសចរ** គឺជាបុគ្គលម្នាក់ឬក្រុមណាមួយដែលធ្វើដំណើរកម្សាន្តទៅកាន់តំបន់ឬប្រទេសណាមួយដើម្បីធ្វើការទស្សនា ស្វែងយល់ពីធម្មជាតិ វប្បធម៌ អរិយធម៌ របៀបរបបរស់នៅរបស់មនុស្ស ផ្លាស់ប្ដូរបទពិសោធន៍ ចំណេះដឹង បង្កើតទំនាក់ទំនងមិត្តភាព ដែលក្នុងនោះទេសចរជាអ្នកនាំមកនូវរូបិយប័ណ្ណបរទេសជូនជាតិ បូករួមជាមួយសកម្មភាពចូលរួមការពារថែរក្សានិងអភិរក្ស រាល់ធនធានដ៏មានតម្លៃទាំងនោះឱ្យគង់វង្សយូរអង្វែង និងទទួលបានផលប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។

## ១.២. ប្រភេទនៃទេសចរណ៍

វិស័យទេសចរណ៍ត្រូវបានគេរាប់បញ្ចូលក្នុងវិស័យសំខាន់ៗនៃខឿនអភិវឌ្ឍន៍សេដ្ឋកិច្ច។ ទេសចរណ៍ត្រូវបានគេបែងចែកជាច្រើនប្រភេទដោយផ្អែកលើទីកន្លែង និងសក្ដានុពលភាពដែលទាក់ទាញភ្ញៀវបាន។ ប្រភេទទេសចរណ៍ទាំងនោះមាន៖

- ទេសចរណ៍វប្បធម៌ជាប្រភេទទេសចរណ៍ផ្អែកទៅលើធនធានវប្បធម៌ (Cultural Resource) រួមមានទំនៀមទំលាប់ ប្រពៃណី បេតិកភ័ណ្ឌ របាំ សិប្បកម្ម ពិធីបុណ្យ ផ្សេងៗ។
- ទេសចរណ៍ធម្មជាតិ សំដៅទៅលើផលិតផលធម្មជាតិទាំងឡាយដូចជា សត្វ រុក្ខជាតិ ទេសភាពល្អៗ និងភូមិវិទ្យា ធម្មជាតិ (ទន្លេ បឹង ទឹកធ្លាក់)។
- ទេសចរណ៍ទីក្រុងគឺផ្អែកទៅលើការទាក់ទាញផ្សេងៗ និងការចាប់ចិត្តលើទីក្រុងដោយរួមបញ្ចូលទាំងលក្ខណៈពិសេសនៃប្រវត្តិសាស្ត្រ និងវប្បធម៌ សារៈមន្ទីរ ហាងទំនិញ របាំ ភ្លេង ការសម្ដែងនាដកម្ម សណ្ឋារគារ ភោជនីយដ្ឋាន។
- ទេសចរណ៍គឺផ្អែកលើសកម្មភាពដើរកំសាន្តតាមមាត់ទន្លេ កីឡា នេសាទ ទៅជិះស្គី។
- ទេសចរណ៍ពាណិជ្ជកម្មគឺ ស្ថិតនៅលើសកម្មភាពរបស់អ្នកជំនាញដោយធ្វើដំណើរលំហែកំសាន្ត លាយលំជាមួយសកម្មភាពពាណិជ្ជកម្ម។
- ទេសចរណ៍ផ្សងព្រេងជាទេសចរប្រើកម្លាំងកាយច្រើន និងមានភាពអត់ធ្មត់ក្នុងការធ្វើដំណើរផ្សងព្រេងដូចជាការឡើងភ្នំខ្ពស់ៗ ដំណើរចុះតាមជ្រលងភ្នំធំៗជាដើម។
- ទេសចរដើម្បីសុខភាពគឺផ្អែកទៅលើបរិស្ថានសុខភាព និងការព្យាបាលជម្ងឺដូចជា ទឹកធម្មតាជាតិ និងកម្ដៅពន្លឺថ្ងៃទឹកក្ដៅធម្មជាតិ។

ទេសចរណ៍ត្រូវបានកំណត់ និងបែងចែកទៅតាមប្រភេទនិមួយៗដូចខាងក្រោម៖

- **ទេសចរណ៍ជាតិ** (National Tourism) ជាចង្កោមសកម្មភាពការងារ ដែលបម្រើឱ្យវិស័យទេសចរណ៍ក្នុងប្រទេសនិងទេសចរណ៍ក្រៅប្រទេស។
- **ទេសចរណ៍ក្នុងស្រុក** (Domestic Tourism) ជាសកម្មភាពទេសចរណ៍ដែលភ្ជាប់ជាមួយការធ្វើដំណើរជាទេសចរណ៍ និងធ្វើសកម្មភាពទេសចរណ៍របស់ប្រជាពលរដ្ឋទៅលើទឹកដីនៃប្រទេសកំណើត (ប្រទេសដែលគេរស់នៅជាអចិន្ត្រៃយ៍)។
- **ទេសចរណ៍អន្តរជាតិ** (International Tourism) ជាសកម្មភាពដែលចងភ្ជាប់ជាមួយនឹងការធ្វើដំណើរទេសចរណ៍ របស់ពលរដ្ឋប្រទេសមួយទៅប្រទេសមួយទៀត។ ទេសចរណ៍អន្តរជាតិ ជាសកម្មភាពទេសចរណ៍អន្តរជាតិដែលត្រូវបានបែងចែកជា២គឺ៖
- Inbound Tourism: សំដៅទៅលើជនទាំងឡាយណាដែលធ្វើដំណើរចូលមកកាន់ប្រទេសណាមួយ ហើយស្នាក់នៅទីនោះលើសពីរយៈពេល២៤ម៉ោង តែតិចជាងមួយឆ្នាំ ក្នុងគោលបំណងផ្សេងៗដែលមិនពាក់ព័ន្ធនឹងការស្វែងរកការងារ។
- Outbound Tourism: សំដៅលើជនទាំងឡាយណាដែលធ្វើដំណើរទៅកាន់ប្រទេសណាមួយហើយស្នាក់នៅប្រទេសនោះរយៈពេល ២៤ម៉ោង តែតិចជាងមួយឆ្នាំ ក្នុងគោលបំណងសម្រាកលំហែកាយសិក្សាស្វែងយល់ ពោលគឺមិនពាក់ព័ន្ធនឹងការស្វែងរកការងារនិងមិនមែនជាការផ្លាស់ប្តូរកន្លែងរស់នៅ។
- **ទេសចរណ៍អន្តរជាតិ** សំដៅទៅលើទេសចរណ៍ដែលធ្វើដំណើរឆ្លងកាត់ព្រំដែនប្រទេស។ អង្គការទេសចរណ៍ពិភពលោកបានកំណត់ទេសចរដូចជាមនុស្សដែលធ្វើដំណើរទៅ និងស្នាក់នៅក្នុងកន្លែងក្រៅបរិស្ថានធម្មតារបស់ពួកគេ មិនលើសពីមួយឆ្នាំជាប់គ្នាដើម្បីការកំសាន្តអាជីវកម្ម និងគោលបំណងផ្សេងទៀត។
- **ទេសចរណ៍សង្គម** (Social Tourism) ជាប្រភេទមួយនៃទេសចរណ៍ដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលសម្រាប់បង្កជាលទ្ធភាពដល់ស្រទាប់មហាជនដូចជា សិស្ស និស្សិត យុវវ័យ អ្នកចូលនិវត្តន៍ ជនពិការ និងពលរដ្ឋប្រទេសនេះ ធ្វើដំណើរកម្សាន្ត លំហែទេសចរណ៍ក្នុងរដូវទេសចរណ៍តិច (Low Season)។

នៅខែឧសភាឆ្នាំ ១៩៥៩ នៅក្នុងកិច្ចប្រជុំលើកទីពីរនៃទេសចរណ៍សង្គមនៅក្នុងប្រទេសអូទ្រីសលោក Walter Hunziker បានស្នើឡើងនូវនិយមន័យដូចខាងក្រោម៖ ទេសចរណ៍សង្គម គឺជាប្រភេទនៃវិស័យទេសចរណ៍បានអនុវត្ត ដោយក្រុមដែលមានប្រាក់ចំណូលទាប ព្រមទាំងមានការសម្របសម្រួលសេវាកម្មទាំងស្រុក។

ទេសចរណ៍ផ្ទៃក្នុង (Internal Tourism) ជាចង្កោមនៃសកម្មភាពការងារមាននៅផ្ទៃខាងក្នុងនៃតំបន់មួយ ទីកន្លែងមួយ ឬប្រទេសមួយ។ សកម្មភាពទេសចរណ៍បែបនេះជាទូទៅជាសកម្មភាពដែលបម្រើ ឱ្យទេសចរណ៍ក្នុងស្រុក និងទេសចរណ៍បរទេស។ វាជាប្រភេទទេសចរណ៍ ដែលធ្វើឡើងនៅផ្ទៃខាងក្នុងតំបន់ កន្លែង ឬប្រទេសមួយជាក់លាក់។

## ១.៣. ព័ត៌មានពីគោលដៅទេសចរណ៍

ព័ត៌មានពីគោលដៅទេសចរណ៍ជាប្រភពមួយដែលចាំបាច់ពីគោលដៅទេសចរណ៍ក្នុងការទាក់ទាញទេសចរណ៍ឱ្យចូលទៅកាន់តំបន់ទាំងនោះ។ កត្តាដ៏សំខាន់មួយទៀតដែលអាចឱ្យគោលដៅទេសចរណ៍មួយទទួលបានទេសចរមកទស្សនា គឺ ព័ត៌មានៈការផ្សាយពីស្ថានទូតប្រចាំប្រទេសប្រភពផ្តល់ទេសចរ, ការផ្សព្វផ្សាយពាណិជ្ជកម្ម (ប្រព័ន្ធអ៊ីនធើណេត ទូរទស្សន៍។ល។), កាផ្សាយតាមភាពយន្តឯកសារ, ការផ្សព្វផ្សាយរបស់សហគ្រាសទេសចរណ៍, ការផ្សាយតាមសៀវភៅណែនាំទេសចរណ៍ (Guide book), ការផ្សាយតៗគ្នារបស់ទេសចរទៅទេសចរ។ល។ ព័ត៌មានទាំងនោះអាចបង្ហាញអំពី ភាពទាក់ទាញ ហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្ម សេដ្ឋកិច្ច សន្តិសុខ សុវត្ថិភាព ព្រឹត្តិការណ៍នានាដែលបាននាំទេសចរណ៍គ្រប់ទិសទីទៅកាន់តំបន់គោលដៅនានាដែលទេសចរចង់ទៅដល់។

## ១.៤. ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍

ហេដ្ឋារចនាសម្ព័ន្ធ(Infrastructure): ជាលក្ខខណ្ឌសេដ្ឋកិច្ចដែលមានឥទ្ធិពលយ៉ាងខ្លាំងចំពោះការអភិវឌ្ឍនៃវិស័យទេសចរណ៍ពោលគឺ គ្មានហេដ្ឋារចនាសម្ព័ន្ធក៏គ្មានការអភិវឌ្ឍទេសចរណ៍ដែរ។ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍មានសមាសធាតុ ៤ សំខាន់ៗៈ បណ្តាញគមនាគមន៍(Transportation Network) ដូចជាផ្លូវថ្នល់ ផ្លូវទឹក ផ្លូវដែក និងផ្លូវអាកាស, បណ្តាញទូរគមនាគមន៍ (Telecommunication Network) ដូចជាប្រៃស៍ណីយ៍ ទូរស័ព្ទ ទូរសារ អ៊ីនធើណេត ។ល។, ប្រព័ន្ធផ្គត់ផ្គង់ទឹក ភ្លើង(Utilities Power supply), ប្រព័ន្ធលូរបង្ហូរទឹកកខ្វក់ (Sewage System)។

លទ្ធភាពដែលអាចចូលទៅដល់ (Accessibility) គឺជាដំណើរការមួយដែលធានាថាគោលដៅទេសចរណ៍ ផលិតផល និងសេវាកម្មទេសចរណ៍ត្រូវបានផ្តល់ជូនដល់ទេសចរគ្រប់រូបដែលបានទៅដល់កំបន់គោលដៅណាមួយ។ កត្តាចម្បងដែលអាចទាញទេសចរ ឬបង្កើតចំណាប់អារម្មណ៍របស់ទេសចរឱ្យចូលមកកម្សាន្តតំបន់គោលដៅណាមួយគឺ លទ្ធភាពដែលអាចចូលទៅដល់ (Accessibility)៖ ទំនាក់ទំនងការទូតរវាងពីរប្រភព(ផ្តល់ និងទទួលទេសចរ), មធ្យោបាយដឹកជញ្ជូនដែលអាចទៅដល់គោលដៅដោយសុវត្ថិភាពនិងផាសុកសុខភាព,

នយោបាយផ្ទៃក្នុងគោលដៅទេសចរណ៍, សន្តិសុខ សុវត្ថិភាពរបស់គោលដៅទេសចរណ៍និង, លទ្ធភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងការចូលដល់ក្នុងសកម្មភាពទេសចរណ៍។

## ១.៥. អធិរចនាសម្ព័ន្ធ ទេសចរណ៍

អធិរចនាសម្ព័ន្ធ គឺជារចនាសម្ព័ន្ធ ដែលធ្វើដំណើរការដោយសារហេដ្ឋារចនាសម្ព័ន្ធ ពោលគឺអធិរចនាសម្ព័ន្ធមិនអាចមិនមានហេដ្ឋារចនាសម្ព័ន្ធទេ តែការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធនាំឱ្យអធិរចនាសម្ព័ន្ធកាន់តែរីកចម្រើន តែផ្ទុយទៅវិញ បើគ្មានអធិរចនាសម្ព័ន្ធក៏ពុំមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែរ។ អធិរចនាសម្ព័ន្ធ គឺជាបណ្តាសម្បទាទាំងឡាយដែលបង្កើតសម្រាប់បម្រើសេវាកម្មដល់ទេសចរពេលគាត់ទៅដល់ទីណាមួយ ដូចជា៖ មូលដ្ឋានសេវាកម្មដឹកជញ្ជូន(មធ្យោបាយដឹកជញ្ជូននានា), មូលដ្ឋានសេវាកម្មស្នាក់នៅ, មូលដ្ឋានសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ, មូលដ្ឋានសេវាបម្រើការលំហែអារម្មណ៍ និងសម្បទាទេសចរណ៍ដទៃទៀត។

## ១.៦. ធនធាននិងផលិតផលទេសចរណ៍

ធនធានទេសចរណ៍ជាប្រភពនៃលទ្ធភាពទាក់ទាញ និងទទួលយ៉ាងសំខាន់របស់តំបន់គោលដៅទេសចរណ៍។ តំបន់មួយដែលមានធនធាន ប្រកបដោយសមត្ថភាពគ្រាប់គ្រាន់ តំបន់នោះនឹងមានលទ្ធភាពស្រូបទាញទេសចរកាន់តែខ្លាំង។ ធនធានទាំងនោះអាចទទួលបានដោយសារ៖ អំណោយផលពីធម្មជាតិជាធនធានដែលកើតឡើងដោយឯកឯងពីធម្មជាតិ, ការកែច្នៃចេញពីធម្មជាតិជាធនធានម្យ៉ាងដែលមនុស្សយកការច្នៃប្រឌិតរបស់ខ្លួនទៅបន្ថែមលើភាពសម្បូរបែបរបស់ធម្មជាតិអោយទៅជាធនធានដែលមានតម្លៃ និងជាភាពទាក់ទាញមួយសម្រាប់ទេសចរណ៍, វត្ថុសិល្បៈវប្បធម៌ជាធនធានមួយដែលចេញពីសិល្បៈការបង្កើតរបស់មនុស្សដែលបង្កើតអោយមានភាពទាក់ទាញពីសំណាក់ទេសចរ, ការបណ្តុះបណ្តាលជាការអប់រំដែលនាំអោយមានការអភិវឌ្ឍទៅលើគ្រប់ផ្នែកដែលមានដើម្បីទទួលបានធនធានដែលមានគុណភាព, ការស្រូបទាញពីប្រភពផ្សេងៗជាច្រើន។

### ១.៦.១. ធនធានអំណោយផលពីធម្មជាតិ

ប្រទេសទេសចរណ៍នីមួយៗមានសក្តានុពលអំណោយផលពីធម្មជាតិផ្សេងៗ គ្នាប្រទេសដែលមានអំណោយផលកាន់តែខ្លាំង ការទាក់ទាញកាន់តែខ្លាំង អំណោយផលពីធម្មជាតិទាំងនោះមានដូចជា៖ កត្តាអាកាសធាតុ, កត្តាទីតាំងភូមិសាស្ត្រមាន៖ សមុទ្រ, ទន្លេ, ស្ទឹង, បឹង, ជ្រោះ ភ្នំ កោះ, ទឹកធ្លាក់ផុស, ព្រឹត្តិការណ៍ធម្មជាតិផងដែរ។

### ១.៦.២. ធនធានទាក់ទាញបែបវប្បធម៌

ធនធានបែបវប្បធម៌មានការស្វែងយល់ពីជីវភាពរស់នៅ និងពណ៌សម្បុររបស់តំបន់គោលដៅដែលខុសពីជីវិតរស់នៅរបស់ទេសចរ និងជាចំណេះដឹង និងគំនិតថ្មីៗដែលមិនបានជួបពីមុន។ ជនជាតិនីមួយៗតែងមានវប្បធម៌ខុសៗគ្នា ភាពផ្សេងគ្នានៃវប្បធម៌នេះធ្វើឱ្យមនុស្សចង់ដឹង ចង់ឃើញ ទស្សនា វប្បធម៌ គឺជាការទាញ ឬច្នៃចេញពីធម្មជាតិរបស់មនុស្ស ធនធានបែបវប្បធម៌មានទាំងរូបីយ និងអរូបីយ ភាពទាក់ទាញទេសចរណ៍វប្បធម៌មានពីរប្រភេទ៖ ភាពទាក់ទាញដែលគេបង្កើតក្នុងគោលបំណងទេសចរណ៍, ភាពទាក់ទាញដែលគេបង្កើតមិនមែនដើម្បីទេសចរណ៍។ ក្នុងនោះក៏អាចរាប់បញ្ចូលផលដៃរនូវ ព្រឹត្តិការណ៍បែបវប្បធម៌ និងមានម្ហូបអាហារប្រចាំតំបន់ និងវត្ថុតាងប្រចាំតំបន់ផងដែរ។

### ១.៦.៣. ធនធានមនុស្ស

មនុស្សជាផ្នែកមួយ នៃការអភិវឌ្ឍ និងការផ្តល់សេវាកម្មទេសចរណ៍ តំបន់គោលដៅទេសចរណ៍មួយទាមទារនូវធនធានមនុស្សប្រកបដោយ សមត្ថភាពកែច្នៃធនធាន និងការអភិវឌ្ឍគោលគំនិតថ្មីៗ, សមត្ថភាពក្នុងការវិនិយោគទុនក្នុងវិស័យទេសចរណ៍, សមត្ថភាពគ្រប់គ្រងស្ថាប័ន សហគ្រាស ក្រុមហ៊ុន និងអាជីវកម្មទាំងឡាយក្នុងវិស័យទេសចរណ៍, សមត្ថភាពបម្រើការងារក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចប្រកបដោយភាពប៉ិនប្រសប់ និងផ្តល់ទំនុកចិត្តពីទេសចរ, សមត្ថភាពធ្វើឱ្យទេសចរទទួលបាននូវការបំពេញចិត្តដែលនាំឱ្យគេនឹងត្រឡប់មកម្តងទៀត ឬនិយាយតៗពីគោលដៅទេសចរណ៍នោះ។ គុណវុឌ្ឍិទាំងនេះអាចនិយាយជារួមមាន៣គឺ៖ មានចំណេះដឹង ជំនាញ ច្បាស់លាស់, មានបទពិសោធន៍និង, មានសីលធម៌វិជ្ជាជីវៈត្រឹមត្រូវ។ ការអភិវឌ្ឍចាំបាច់ត្រូវមានធនធានមនុស្សជាកត្តាមួយដ៏សំខាន់ ប្រសិនបើគ្មាននូវធនធានមនុស្សក្នុងការអភិវឌ្ឍនោះទេតំបន់គោលដៅទាំងនោះក៏គ្មានការអភិវឌ្ឍដែរ។

### ១.៦.៤. តំបន់ទេសចរណ៍

តំបន់ទេសចរណ៍ជាបណ្តាប្រភេទនៃការរៀបចំការទាក់ទាញទេសចរណ៍៖ តាមច្បាប់ទេសចរណ៍ តំបន់ទេសចរណ៍ សំដៅដល់តំបន់ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានជ្រើសរើសរៀបចំ និងអភិវឌ្ឍន៍បម្រើឱ្យគោលបំណង និងសកម្មភាពទេសចរណ៍។ តំបន់ទេសចរណ៍នីមួយៗអាចមានការប្រែប្រួលទៅតាមចរិកលក្ខណៈ និងចំណាត់ថ្នាក់របស់វា ដូចជា៖

- រមណីយដ្ឋាន(Resort) សំដៅដល់ទីតាំង ដែលមានភាពទាក់ទាញទេសចរណ៍ដូចជា វប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ។ល។ ដែលរៀបចំកែច្នៃឡើង ហើយត្រូវបានអនុញ្ញាតឱ្យរៀបចំ សម្រាប់ធ្វើអាជីវកម្មបម្រើការសម្រាក លំហែនិងកម្សាន្តតាមគោលបំណងទេសចរណ៍ ស្របច្បាប់។

- ស្ប៉ា (Spa or Mediainal Water) កន្លែងដែលមានទឹកក្តៅផុសពីដី ឬទឹកដែលមានសារធាតុព្យាបាលសុខភាព។
- ទីក្រុងបុរាណ ឬទីក្រុងប្រវត្តិសាស្ត្រ(Historical Town Center)
- តំបន់ការពារធម្មជាតិ (Protected Areas) នៅកម្ពុជាមាន៦៤កន្លែង ដោយបែងចែកជា ៦ ប្រភេទធំៗរួមមាន៖ ឧទ្យានជាតិ(១២) ដែនជំរកសត្វព្រៃ (២៤) តំបន់ប្រើប្រាស់ច្រើនយ៉ាង (៦) តំបន់ការពារទេសភាព(២) តំបន់បេតិកភណ្ឌធម្មជាតិ និងតំបន់រ៉ាមសារ(៥)។

## ១.៧. ការអភិវឌ្ឍទេសចរណ៍

ពាក្យអភិវឌ្ឍន៍បានវិវត្តពិន័យចង្អៀត ទស្សនទានអភិវឌ្ឍន៍សេដ្ឋកិច្ចប្រពៃណីឈានទៅ កាន់តែទូលំទូលាយ ការអភិវឌ្ឍប្រកបដោយ ការកែតម្រូវជាបន្តបន្ទាប់នានាភាពថ្មី នៃការតម្រង់ទិស គឺការគិតគូពីបរិស្ថានធម្មជាតិ ឬបរិស្ថាននិយមតាមរយៈដំណាក់កាលនីមួយៗនៃការអនុរក្សទៅនិរន្តរភាព។ ការអភិវឌ្ឍក្នុងន័យទូទៅតាមវចនានុក្រមភូមិសាស្ត្រ គឺជាការប្រើប្រាស់ធនធាន ដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅរបស់ជាតិមួយ មានន័យថាសង្គមមានបច្ចេកទេសមួយបានត្រូវផ្លាស់ប្តូរទៅជា សង្គមមានបច្ចេកវិទ្យាខ្ពស់ទំនើប ដោយឆ្លើយតបទៅ និងការកើនឡើងនៃចំណូល។ ជារួមការអភិវឌ្ឍមានន័យថាជាការផ្លាស់ប្តូរពីអ្វីដែលគ្មានឱ្យទៅជាមាន និងផ្លាស់ប្តូរពីអ្វីដែលមានស្រាប់ ឱ្យកាន់តែមានលក្ខណៈសម្បត្តិប្រសើរឡើង។[3] ជាក់ស្តែងការអភិវឌ្ឍគឺជាការផ្លាស់ប្តូរនូវកម្រិតជីវភាពរស់នៅរបស់ជាតិ ឱ្យមានការរីកចម្រើននិងប្រសើរឡើង។ ការយល់ដឹងពីការអភិវឌ្ឍអាចជួយយើងឱ្យយល់ថែមទៀតអំពីបុព្វហេតុ និងដំណោះស្រាយចំពោះបញ្ហាដែលកើតមានឡើង។ ម្យ៉ាងទៀតវិញទៀត គឺជាដំណើរនៃការអភិវឌ្ឍដែលកំពុងតែត្រូវគេអនុវត្តនិងបញ្ជាក់ពីភាពរីកចម្រើន ឬមានការរីកចម្រើនទៅមុខជាក់លាក់។

ការអភិវឌ្ឍ ក្នុងន័យទេសចរណ៍ គឺសំដៅលើការពង្រឹងផលិតផលទេសចរណ៍ ដើម្បីផ្គត់ផ្គង់តាមតម្រូវការទីផ្សារសមស្រប ដោយទាក់ទាញការទស្សនាទាំងភ្ញៀវដែលបានមកទស្សនាហើយ និងភ្ញៀវថ្មីៗបន្ថែមទៀត។ ការអភិវឌ្ឍផលិតផលទេសចរណ៍ត្រូវមានពីរកម្រិតសំខាន់ៗគឺ កម្រិតតូច គួរលើកទឹកចិត្តជូនសហគមន៍ប្រជាពលរដ្ឋ និងកម្រិតធំ ត្រូវធ្វើការសិក្សាលើការវិនិយោគដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ និងមានទំនួលខុសត្រូវ។

ការអភិវឌ្ឍក្នុងលក្ខណៈទ្រឹស្តី ដែលមនុស្សជាទូទៅចាត់ទុកការអភិវឌ្ឍថាជាការលូតលាស់និងការរីកចម្រើនទៅមុខប្រកបដោយជោគជ័យ។ ជាការពិតណាស់ តាមការសិក្សាការអភិវឌ្ឍគឺជាដំណើរការពហុមាត្រា

[3] សេចក្តីផ្តើមទេសចរណ៍៖ លោកសាស្ត្រាចារ្យ ឈឹម ផាន់ណា

ដ្ឋានដែលរួមបញ្ចូលនូវការផ្លាស់ប្តូរ និងការអភិវឌ្ឍទាំងបរិមាណ និងគុណភាព។ ការអភិវឌ្ឍគឺធ្វើឱ្យសង្គមមួយមានការរីកចម្រើនលូតលាស់ជឿនលឿនលើគ្រប់វិស័យ ដូចជា វិស័យទេសចរណ៍ប្រព័ន្ធរដ្ឋបាល នយោបាយ រចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ដូចនេះ ពាក្យថាការអភិវឌ្ឍនេះ គឺត្រូវធ្វើឱ្យមានសុក្រិតភាពលើស្ថាប័នសង្គម រដ្ឋបាលសាធារណៈ ផ្នត់គំនិតប្រជាជន ការជម្រុញកំណើនសេដ្ឋកិច្ច ដើម្បីលុបបំបាត់ភាពក្រីក្រ អនក្ខភាព និងការថែរក្សាការពារបរិស្ថានធម្មជាតិ និងសម្បត្តិ វប្បធម៌នានា។ រួមសេចក្តីមក ការអភិវឌ្ឍមានន័យថា៖

- ផ្លាស់ប្តូរពីអ្វីដែលគ្មាន ទៅជាមាន
- ផ្លាស់ប្តូរពីអ្វីដែលមានស្រាប់ឱ្យមានលក្ខណៈសម្បត្តិកាន់តែប្រសើរឡើង។ ពោលគឺផ្លាស់ប្តូរកម្រិតជីវភាពរស់នៅរបស់ប្រជាជាតិឱ្យមានការរីកចម្រើន និងប្រសើរឡើង
- ការអភិវឌ្ឍ គឺជាការធ្វើអ្វីដែលគ្មានឱ្យទៅជាមាន និងអ្វីដែលមានរួចហើយ ត្រូវតែធ្វើឱ្យប្រសើរឡើងប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។

## ១.៨. យុទ្ធសាស្ត្រនៃការគ្រប់គ្រង

យុទ្ធសាស្ត្រគ្រប់គ្រង គឺជាវិធីសាស្ត្រដែលប្រើ ក្នុងការគ្រប់គ្រងអ្នកក្រោមបង្គាប់គ្រប់គ្រងអតិថិជន និងគ្រប់គ្រងខ្លួនឯង។ និយាយឱ្យចំ គឺជាការពង្រឹងភាពជាអ្នកដឹកនាំ និងដែលជាពិសេសគឺភាពប៉ិនប្រសប់ក្នុងការថ្លឹងថ្លែង។

# ជំពូកទី២

# ទិដ្ឋភាពទូទៅនៃខេត្តបាត់ដំបង

## ២.១. ស្ថានភាពទូទៅនៃខេត្តបាត់ដំបង

### ២.១.១. ស្ថានភាពភូមិសាស្ត្រខេត្តបាត់ដំបង

ខេត្តបាត់ដំបងជាខេត្តមួយស្ថិតនៅប៉ែកពាយ័ព្យតាមបណ្តោយបឹងទន្លេសាបនៃព្រះរាជណាចក្រកម្ពុជា មានចម្ងាយ ២៩១គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៥ ដែលមានវិសាលភាពផ្ទៃដី ១១,៧៤៨ គីឡូម៉ែត្រក្រឡា ដែលបច្ចុប្បន្នចែកចេញជា ក្រុង០១ ស្រុក១៣ ឃុំសង្កាត់១០២ និង៨០៩ ភូមិ។ ខេត្តបាត់ដំបងមានប្រជាជនចំនួន ១,៣១២,០៥១ នាក់ ក្នុងនោះស្ត្រី ៦៦០,៩៧៥ នាក់ ស្មើនឹង ២៧៦,៤៥២ គ្រួសារ ដោយប្រជាជនភាគច្រើនប្រកបរបរកសិកម្ម (៧១.៤ភាគរយ) ព្រោះខេត្តនេះសម្បូរផ្ទៃដីដាំដុះ និងសុទ្ធសឹងជាដីល្បាប់ដែលមានជីវជាតិល្អដល់ដំណាំ។ ខេត្តបាត់ដំបងមានព្រំប្រទល់ជាប់

- ខាងកើតជាប់នឹង៖ ខេត្តពោធិ៍សាត់-បឹងទន្លេសាប
- ខាងលិចជាប់នឹង៖ ខេត្តប៉ៃលិន-ព្រះរាជាណាចក្រថៃ
- ខាងត្បូងជាប់នឹង៖ ខេត្តពោធិ៍សាត់
- ខាងជើងជាប់នឹង៖ ខេត្តបន្ទាយមានជ័យ។




រូបភាពទី១៖ ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងខេត្តបាត់ដំបង(ប្រភព៖អនុក្រឹត្យលេខ៨០ ចុះថ្ងៃទី១៣ មិថុនា ២០១៨)

## ២.១.២. ប្រវត្តិខេត្តបាត់ដំបង

ខេត្តបាត់ដំបងជាខេត្តមួយស្ថិតនៅភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជាស្ថិតជាប់បឹងទន្លេសាប។ បើតាមសិលាចារឹកថ្មប្រាសាទដែលយើងមាន និងបានរកឃើញរហូតដល់សព្វថ្ងៃ នៅមុនសម័យ និងសម័យអង្គរគេពុំបានឃើញ និងចែងឲ្យយើងដឹងថា តើសម័យនោះមានភូមិស្រុកណា ដែលមានឈ្មោះបាត់ដំបងនោះទេ។ ប៉ុន្តែយើងក៏មិនហ៊ានសន្និដ្ឋានថា ឈ្មោះបាត់ដំបង នេះមានប្រើ ឬមិនប្រើក្នុងសម័យនោះដែរ។ ប៉ុន្តែក្នុងសម័យអង្គរ និងក្រោយអង្គរ តាមឯកសារមហាជនខ្មែរមានប្រើឈ្មោះស្រុកបាត់ដំបង។ ហេតុអ្វីបានជាហៅឈ្មោះបាត់ដំបង ប្រវត្តិសាស្ត្រសរសេរលើសិលាចារឹកមិនបានឆ្លើយឱ្យដឹងឡើយ គឺមានតែនៅក្នុងរឿងព្រេងប៉ុណ្ណោះគឺ រឿងតាដំបងក្រញូង ដែលខ្មែរយើងយល់ថាជារឿងកើតមានតាំងពីសម័យអង្គរដែលបានពន្យល់ពីដើមហេតុដែលនាំឱ្យយើងហៅឈ្មោះបាត់ដំបង ឬអូរដំបង។ ឯឈ្មោះព្រះដំបងគឺស្តេចរាមាទី១ កំណត់ឱ្យហៅឈ្មោះភូមិសង្កែថាជា ″ព្រះដំបង″។ កាលពីមុនសម័យអង្គរ និងសម័យអង្គរភាគខាងលិច និងភាគពាយ័ព្យនៃបឹងទន្លេសាប គឺជាដែនដីអមោយបុរៈ និងជាដែនដីភិមៈបុរៈ។ នៅក្នុងសម័យអង្គរដែនដីឬភូមិភាគអមោយបុរីមានការរីកចម្រើនខ្លាំង ដោយសារដីមានជីវជាតិល្អ អាចដាំដំណាំស្រូវ និងបន្លែផ្លែឈើផ្សេងៗបានប្រកបដោយទិន្នផលល្អប្រសើរ។

ប្រជារាស្ត្រខ្មែរជំនាន់នោះមករស់នៅភូមិភាគនេះច្រើនជាភស្តុតាងបង្ហាញគឺមានប្រាសាទបុរាណជាច្រើនសន្ធឹកសន្ធាប់ក្នុងតំបន់នេះ។ ប៉ុន្តែប្រាសាទបុរាណទាំងនោះរលំបាក់បែកស្ទើរតែទាំងអស់លើកលែង ប្រាសាទបាណន់ ប្រាសាទឯកភ្នំ ប្រាសាទបាសែត ប្រាសាទស្នឹង បន្ទាយទ័យ បន្ទាយឆ្មារ ជាដើមដែលនាម៉ឺនសព្វមុខមន្ត្រី និងប្រជារាស្ត្រជំនាន់នោះកសាងឡើងសម្រាប់ជាទីសក្ការៈបូជាដល់ព្រះអទិទេព និងទេវៈផ្សេងៗ ខាងព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា និងពោធិសត្វផ្សេងៗខាងពុទ្ធសាសនា នៅសតវត្សក្រោយមកទៀតដែនដីបាត់ដំបង ត្រូវបានទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ពីចម្បាំងរាំងជល់ដោយការឈ្លានពានពីសំណាក់ពួកសៀម តាំងពីសតវត្សទី១៥ រហូតដល់សតវត្សទី១៨ ធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនជំនាន់នោះធ្លាក់ក្រលំបាករងទុក្ខ ព្រាត់ប្រាសនិវាសគ្រួសារ ទ្រព្យសម្បត្តិ ផ្ទះសម្បែងគួរឱ្យខ្លោចផ្សារ។ នៅចុងសតវត្សទី១៨ ដល់ដើមសតវត្សទី២០ បាត់ដំបងក៏ធ្លាក់នៅក្រោមអំណាចត្រួតត្រា ជិះជាន់របស់ពួកសៀមអស់រយៈពេលជាងមួយសតវត្សដែលគ្រប់គ្រងដោយអំណាចគ្រួសារចៅហ្វាបែន ក្រោយមកគេដាក់ឈ្មោះថា "ត្រកូលអភ័យវង្ស" អស់ ០៦ តំណរហូតដល់ឆ្នាំ១៩០៧។ តាមសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ សៀមត្រូវប្រគល់មកឱ្យកម្ពុជាវិញ នៅទឹកដីដែលខ្លួនធ្លាប់កាន់កាប់ជាងមួយសតវត្សគឺ បាត់ដំបង សៀមរាបអង្គរ សិរីសោភ័ណ្ឌ និងចុងកាល់ដោយប្តូរនឹងខេត្តត្រាត និងតំបន់ដាច់សេ (ដែនដីលាវ) ប៉ែកខាងលើនៃទន្លេមេគង្គ។ ប៉ុន្មានខែក្រោយមកព្រះករុណាព្រះបាទស៊ីសុវត្ថិ ទ្រង់បានចេញ ព្រះរាជប្រកាសលេខ ៦៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩០៧ កំណត់ដែនដីបាត់ដំបងត្រូវបែងចែកជា ០៣ ខេត្តគឺ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តសិរីសោភ័ណ្ឌ។ នៅឆ្នាំ១៩២៥ ទឹកដីខេត្តបាត់ដំបងត្រូវបានបែងចែកសារជាថ្មីដោយមានចំនួនស្រុកចំនួន ០៧គឺ ស្រុកបាត់ដំបង ស្រុកសង្កែ ស្រុកមោងឫស្សី ស្រុកមង្គលបុរី ស្រុកទឹកជោរ ស្រុកសិរីសោភ័ណ្ឌ និងស្រុកបិតត្បូង។ ខែឧសភា ឆ្នាំ១៩៥៣ តំបន់រដ្ឋបាលប៉ោយប៉ែតត្រូវបានបង្កើតឡើងចំណុះស្រុកសិរីសោភ័ណ្ឌ។ ខែកក្កដា ឆ្នាំ១៩៥៧ ស្រុកទឹកជោរត្រូវបានបែងចែកជាពីរគឺ ស្រុកព្រះនេត្រព្រះ និងស្រុកភ្នំស្រុក។ ស្រុកសិរីសោភ័ណ្ឌត្រូវបានបែងចែកទៅជាពីរស្រុកគឺស្រុកសិរីសោភ័ណ្ឌ និងស្រុកបន្ទាយឆ្មារ។ ខែមីនា ឆ្នាំ១៩៦៥ តំបន់រដ្ឋបាលប៉ោយប៉ែត ដែលបានបង្កើតឡើងនៅឆ្នាំ១៩៥៣ នោះត្រូវបានចាត់ថ្នាក់ជាស្រុកឈ្មោះថា អូរជ្រៅ។ ខែកក្កដា ឆ្នាំ១៩៦៥ ទឹកដីមោងឫស្សីមួយផ្នែកត្រូវបានកាត់ទៅជាតំបន់រដ្ឋបាលគាស់ក្រឡ។ ខែមីនា ឆ្នាំ១៩៦៦ ស្រុកថ្មីមួយទៀតត្រូវបានបង្កើតឡើងគឺ ស្រុកថ្មពួក មានទីតាំងនៅថ្មពួក ជាមួយគ្នានេះស្រុកបន្ទាយឆ្មារត្រូវបានដកចេញពីខេត្តបាត់ដំបង ឲ្យចំណុះខេត្តឧត្តរមានជ័យវិញ ដែលជាខេត្តទើបបង្កើតថ្មី។ នៅដើមសម័យសាធារណរដ្ឋខ្មែរមានស្រុកចំនួនពីរបានបង្កើតឡើងគឺ ស្រុកបាណន់ និងស្រុកគាស់ក្រឡ។ សរុបមកដល់ត្រឹមនេះបាត់ដំបងមានស្រុកចំនួន ០៩គឺ ស្រុកបាត់ដំបង ស្រុកសង្កែ ស្រុកមោងឫស្សី ស្រុកមង្គលបុរី ស្រុកសិរីសោភ័ណ្ឌ ស្រុកអូរជ្រៅ ស្រុកព្រះនេត្រព្រះ ស្រុកបាណន់ ស្រុកគាស់ក្រឡ និងតំបន់រដ្ឋបាលចំនួនពីរគឺ តំបន់រដ្ឋបាលបាក់ព្រា និងតំបន់រដ្ឋបាលល្វា។ ក្នុង

របបវាលពិឃាត ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ខេត្តបាត់ដំបងក៏ដូចខេត្តនានាទូទាំងប្រទេសដែរ ប្រជាពលរដ្ឋត្រូវបានជម្លៀសចុះឡើង ពិសេសពីតំបន់ទីក្រុង ទីប្រជុំជនទៅកាន់ទីជនបទ និងតំបន់ព្រៃភ្នំ។ ខេត្តបាត់ដំបងធ្លាប់ល្បីថាជាជង្រុកស្រូវនៃប្រទេសបានក្លាយទៅជាតំបន់ទទួលទារុណកម្មកាប់សម្លាប់និងបង្អត់អាហារពេលនោះខេត្តពុំមានព្រំប្រទល់ច្បាស់លាស់ទេដោយអង្គការដឹកនាំពេលនោះដាក់ខេត្តបាត់ដំបងទៅក្នុងតំបន់ភាគពាយ័ព្យ មានតំបន់មួយ តំបន់៣ តំបន់៤ និងតំបន់៥។ ខណនោះមានឮគេហៅឈ្មោះស្រុកខ្លះដែលដូចជាស្រុកភ្នំសំពៅ ស្រុកបាត់ដំបង ស្រុកមង្គលបុរី ស្រុកសង្កែ ស្រុកមោងឫស្សី ស្រុក៤១ ស្រុក៤២...។ល។ ខេត្តបាត់ដំបងត្រូវបានរំដោះជាស្ថាពរពីរបបប្រល័យពូជសាសន៍នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៩ ក្បាលម៉ាស៊ីនដឹកនាំមានឈ្មោះថាគណៈកម្មាធិការប្រជាជនបដិវត្តន៍ (ខេត្ត ស្រុក ទីរួមខេត្ត ឃុំសង្កាត់)។ គណៈកម្មាធិការប្រជាជនឃុំ/សង្កាត់ត្រូវបានជ្រើសរើសដោយការបោះឆ្នោតដំបូងបំផុតនៅឆ្នាំ១៩៨៣។ ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦ ខេត្តបាត់ដំបងមានស្រុកចំនួន ០៩ ទីរួមខេត្តចំនួន ០១។ នៅឆ្នាំ១៩៨៦ ស្រុកថ្មី៣ត្រូវបានបង្កើតឡើងបន្ថែមទៀត មានស្រុកបាណន់ ស្រុកបវេល និងស្រុកឯកភ្នំ។ ត្រឹមដំណាក់កាលនេះបាត់ដំបងមាន ១២ស្រុក និងទីរួមខេត្ត១ គឺស្រុកមោងឫស្សី ស្រុកបាណន់ ស្រុកឯកភ្នំ ស្រុកបាត់ដំបង ស្រុកសង្កែ ស្រុករតនមណ្ឌល ស្រុកមង្គលបុរី ស្រុកសិរីសោភ័ណ្ឌ ស្រុកព្រះនេត្រព្រះ ស្រុកថ្មពួក ស្រុកភ្នំស្រុក និងស្រុកបវេល។ ឆ្នាំ១៩៨៨ ស្រុកចំនួន០៥ គឺស្រុកមង្គលបុរី ស្រុកថ្មពួក ស្រុកសិរីសោភ័ណ្ឌ ស្រុកព្រះនេត្រព្រះ និងស្រុកភ្នំស្រុកត្រូវបានកាត់ចេញដើម្បីបង្កើតជាខេត្តថ្មីមួយទៀតគឺ ខេត្តបន្ទាយមានជ័យ។

### ២.១.៣. ប្រវត្តិសង្ខេប និងសារៈសំខាន់នៃក្រុងបាត់ដំបង

ទីក្រុងបាត់ដំបងបានប្រែក្លាយក្នុងរយៈពេលដ៏ខ្លីមួយ ពីភូមិអ្នកនេសាទ ដែលលាតសន្ធឹងតាមបណ្តោយដងស្ទឹងសង្កែ ទៅជាទីក្រុងដាច់ស្រយាលតូចមួយនៅមួយនៅសម័យអង្គម្ចាស់ក្នុងសតវត្សទី១៩ បន្ទាប់មកក្លាយទៅជាទីក្រុងតូចមួយ ដែលរៀបតាមបែប អឺរ៉ុបហើយចុងក្រោយបន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យក្នុងទសវត្ស១៩៥០ វាបានក្លាយជាទីប្រជុំជនកណ្តាលដ៏សំខាន់មួយប្រចាំភូមិភាគពាយព្យ។ ប្រវត្តិអភិវឌ្ឍន៍ក្រុងដ៏សំខាន់នេះ ជាមួយនឹងមរតក វប្បធម៌ប្លែកៗ ពីគ្នាទៅតាមដំណាក់កាលនីមួយៗរបស់វាត្រូវបានបន្សល់ទុក និងអាចមើលឃើញរហូតដល់សព្វថ្ងៃ។

បាត់ដំបងសម័យលោកម្ចាស់(១៧៩៥-១៩០៧)៖

បាត់ដំបងគឺជាទីក្រុងតូចមួយដែលមានប្រជាពលរដ្ឋប្រហែល ២៥០០ នាក់ ហើយក្រុងនេះលាតសន្ធឹងតាមបណ្តោយដងស្ទឹងសង្កែ ប៉ែកខាងលិច។ ទីក្រុងមានផ្លូវតែមួយគត់រត់តាមបណ្តោយដងស្ទឹង និងមានប្រជាជនបានសាងសង់លំនៅឋានរប៉ាត់រប៉ាយតាមសងខាងផ្លូវនេះ ហើយនៅត្រង់ទីតាំងផ្សារណាត់បច្ចុប្បន្នគឺជាទី

ផ្សារលំហាមួយនៅសម័យនោះ។ សំណង់សំខាន់ៗដែលបានសាងសង់សម័យនោះ ភាគច្រើនគឺជាវត្តអារាម ដែលបានសាងសង់តាមបណ្តោយដងស្ទឹងសង្កែទាំងសងខាង និងវិហារចិន។ បន្ទាយមួយមានរាងចតុកោណ ដែលហៅថា «កំផែនកែវ» ត្រូវបានសាងសង់ ឡើងចុងទសវត្សឆ្នាំ១៨៣០ ជាមួយនិងនិវេសនដ្ឋានរបស់ អភិបាលខេត្តដែលហៅថា «លោកម្ចាស់» ដែលសព្វថ្ងៃជាអគារសាលាខេត្ត។

បាត់ដំបងក្រោមអាណាព្យាបាលបារាំង(១៩០៧-១៩៥៣)៖ បន្ទាប់ពីបាត់ដំបងត្រូវថៃប្រគល់ឱ្យខ្មែរវិញ ឆ្នាំ ១៩០៧ រដ្ឋបាលបារាំងបានរៀបចំប្លង់អភិវឌ្ឍន៍ក្រុង ដំបូងសម្រាប់ទីក្រុង។ ពួកគេបានរៀបចំគំរូប្លង់ផ្លូវមួយ មានរាងជាក្រលាចត្រង្គដែលមានដំណើរការល្អ និងបានបំពាក់នូវរចនាសម្ព័ន្ធក្រុង ហើយនិងបានសាងសង់ផ្លូវ ប្រព័ន្ធបង្ហូរទឹកស្អុយ និងប្រឡាយព័ទ្ធជុំវិញ។ ផ្លូវសំខាន់បីត្រូវបានសាងសង់ស្របនឹងស្ទឹងសង្កែ ដែលសព្វថ្ងៃ មានឈ្មោះថា ផ្លូវលេខ១ ផ្លូវលេខ២ និង ផ្លូវលេខ៣។ ត្រើយខាងលិច និងត្រើយខាងកើតត្រូវបានតភ្ជាប់ដោយ ស្ពានពីរក្នុងឆ្នាំ ១៩១៧ (ស្ពានដែក និងស្ពានថ្មចាស់)។ ផ្ទះលក់ទំនិញ ជាច្រើនត្រូវសាងសង់ និងបានខណ្ឌ ផ្តាច់ពីគ្នាជាប្លង់តូចៗដោយផ្លូវកាត់ទទឹង និងច្រកសេរភាព(ច្រកផ្លូវតូច)ដែលចន្លោះផ្លូវ សំខាន់ទាំងបី ដូច្នេះវា បានផ្តល់នូវលំហ និងទីធ្លាសម្រាប់ការប្រកបរបរ និងជំនួញខ្នាតតូចដែលធ្វើឡើងដោយខ្មែរ-ចិន។ បារាំងបាន ប្រើប្រាស់កំផែងសម្រាប់កិច្ចការយោធា ហើយពួកគេបានសាងសង់ពន្ធជាគារមួយនៅក្នុងបរិវេណនោះ។ ក្នុង ពេលជាមួយគ្នា មន្ទីរពេទ្យមួយត្រូវបានសាងសង់នៅផ្នែកខាងជើងនៃទីក្រុងនៅក្បែរធនាគារឥណ្ឌូចិន។

ចាប់ពីឆ្នាំ១៩២៦ ប្លង់អភិវឌ្ឍន៍ក្រុងលើកទីពីរត្រូវបានបង្កើតឡើង។ ផ្លូវរថភ្លើងត្រូវបានកសាងឡើង ដើម្បីតភ្ជាប់ខេត្តបាត់ដំបងទៅរាជធានីភ្នំពេញ និងរចនាសម្ព័ន្ធក្រុងត្រូវបានពង្រីកទៅទិសខាងលិចរហូតដល់ផ្លូវ រថភ្លើងក្នុងនោះមានអក្សក្រុងសំខាន់ៗរត់តម្រង់ទៅស្ថានីយ៍រថភ្លើង។ ផ្សារណាត់បានសាងសង់នៅឆ្នាំ១៩៣៦ ដែលបានរៀបចំរចនា យ៉ាងត្រឹមត្រូវតាមបទ អាតដេកូ(Art Deco) នៅលើទីតាំងនៃផ្សារលំហានៅមាត់ស្ទឹង។ តាំងពីពេលនោះមក ផ្សារនេះត្រូវបានចាត់ទុកជាចំណុចសំគាល់ទីតាំងដ៏សំខាន់មួយសម្រាប់ទីក្រុងបាត់ដំបង។ ហើយនៅពេលនោះផងដែរ មានសំណង់ដ៏ប្រណិតជាច្រើនត្រូវបានសាងសង់ដូចជា ភូមិគ្រឹះនិងសំណង់សាធារ ណៈសំខាន់ជាដើម ហើយសំណង់មួយចំនួនបានក្លាយទៅជាបេតិកភណ្ឌទីក្រុង និងបានបង្កើតនូវលក្ខណៈ ពិសេសនៃក្រុងបាត់ដំបងរហូតដល់សព្វថ្ងៃ។ ការអភិវឌ្ឍក្រុមនាសម័យអាណានិគមបារាំង សំដៅរកទស្សនៈវិស័ យនៃការអភិវឌ្ឍឱ្យក្លាយទៅជាមជ្ឈមណ្ឌលរដ្ឋបាល និងជំនាញ។

បាត់ដំបងក្នុងសម័យឯករាជ្យ (សង្គមរាស្រ្តនិយម ១៩៥៣-១៩៧០)៖ សម័យឯករាជ្យគឺជា «យុគ សម័យមាស» នៃប្រវត្តិសាស្រ្តកម្ពុជា។ ប្លង់អភិវឌ្ឍន៍ក្រុងត្រូវពង្រីក ៥ដងធំ ជាងប្លង់រៀបចំក្រុងសម័យបារាំង។ យោងទៅតាមប្លង់អភិវឌ្ឍន៍ក្រុងលើកទីបីសម្រាប់ទីក្រុងបាត់ដំបង តំបន់ពង្រីកក្រុងធំៗ ត្រូវបានគ្រោងសម្រាប់

ប៉ែកខាងជើង (តំបន់លំនៅឋានដែលបានរៀបចំត្រឹមត្រូវហៅថា{Le quartier vert de Sangkum Reastr Niyum} ប៉ែកខាងកើត និងប៉ែកខាងត្បូងនៃទីក្រុង។ ប្លង់ក្រុងដែលបានរៀបចំតាមលក្ខណៈបច្ចេកទេស និងប្រកបដោយសោភណ័ភាពនាពេលនោះ គឺមានមហិច្ឆិតាធំធេង និងមានដែលមានស្រាប់។ រហូតមកដល់សព្វថ្ងៃ តំបន់ដែលគ្របដណ្តប់ដោយប្លង់រៀបចំក្រុងនេះ ពុំទាន់បានអភិវឌ្ឍន៍ពេញលេញ និងមានលំនៅឋាន កុះករឡើយទេ។

បាត់ដំបងបានក្លាយទៅជាទីក្រុងដ៏ទំនើបមួយរបស់ខេត្តមជ្ឈមណ្ឌលពាណិជ្ជកម្ម និងឧស្សាហកម្មសម្រាប់តំបន់។ ហេដ្ឋារចនាសម្ព័ន្ធធំៗ និងទីកន្លែងផ្តល់សេវាសាធារណៈមួយចំនួន ត្រូវបានសាងសង់នៅក្រោមកម្មវិធីទំនើបភាវូបនីយកម្ម នៃរដ្ឋាភិបាលកម្ពុជារបស់ព្រះអង្គម្ចាស់នរោត្តមសីហនុនៅពេលនោះ។ ស្ថាបន័មន្ទីរមួយចំនួនដូចជាតុលាការ និងអគាររដ្ឋបាលសាធារណៈផ្សេងទៀតត្រូវបានបង្កើតផងដែរនៅត្រើយសងខាងលិចស្ទឹង។ រោងចក្រវាយនភ័ណ្ឌ និងរោងចក្រតំបាញត្រូវបានសាងសង់ដោយអ្នកវិនិយោគបារាំងនិងចិន ព្រលានយន្តហោះត្រូវបានរៀបចំឲ្យមាន ដំណើរការ និងផ្លូវដែកត្រូវបានសាងសង់ដើម្បីតភ្ជាប់ទៅព្រំប្រទល់ខ្មែរ ថៃ ប៉ោយប៉ែត។ សាលារៀនមួយចំនួនធំ និងសាកលវិទ្យាល័យមួយត្រូវបានសាងសង់។ មណ្ឌលកីឡា សារមន្ទីរ និងអគារតាំងពិពណ៌ត្រូវបានសាងសង់ ដើម្បីបម្រើឱ្យតម្រូវការផ្នែកវប្បធម៌របស់ប្រជាពលរដ្ឋដែលកំពុងមានការកើនឡើង។ រដ្ឋាភិបាលបានលុបអូរ និងប្រឡាយមួយចំនួនទៀតត្រូវបានប្រែក្លាយ និងប្រើប្រាស់ជាប្រព័ន្ធបង្ហូរទឹកស្អុយ។

ក្រុងបាត់ដំបងពីសម័យសង្គមរាស្ត្រនិយមមានលក្ខណៈរឹងមាំ និងមានការ ផ្លាស់ប្តូរតិចតួចប៉ុណ្ណោះតាំងពីពេលនោះមក។ ការអភិវឌ្ឍនៃក្រុងបាត់ដំបងបានបង្កើនល្បឿនយ៉ាងខ្លាំងតាំងពីចុងទសវត្ស៍ឆ្នាំ១៩៩០ ជាពិសេសបណ្តាលមកពីការរីកចំរើនផ្នែកជំនួញលើផលិតផលកសិកម្ម និងផ្នែកជំនួញខ្នាតតូច ហើយនិងមានការកើនឡើងផ្នែកឧស្សាហកម្មទេសចរណ៍។

## ២.១.៤.ស្ថានភាពទេសចរណ៍

### ក. សម្បទា សេវាកម្មទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍

ដោយមានការយកចិត្តទុកដាក់ និងចង្អុលណែនាំពីក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្តបាត់ដំបងផ្ទាល់ក្នុងចលនាប្រឡងប្រណាំង"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ" និងយុទ្ធនាការផ្សព្វផ្សាយ"កម្ពុជា៖ ព្រះរាជណាចក្រអច្ឆរិយ ផ្តល់ភាពកក់ក្តៅ" មន្ទីរទេសចរណ៍ខេត្តបានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តបាត់ដំបងដោយបានពង្រឹងគុណភាពសេវាកម្មដែលមានស្រាប់ និងបង្កើតផលិតផលទេសចរណ៍ថ្មីៗ ដោយទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ឱ្យបានជា

អតិបរមា ផ្អែកលើមូលដ្ឋាននៃសម្បត្តិវប្បធម៌ ធម្មជាតិ ប្រវត្តិសាស្ត្រ និងសាសនា ប្រកបដោយ គុណភាព ប្រសិទ្ធភាព និងចីរភាពបន្ថែមទៀតជូនទេសចរ គួបផ្សំនឹងកត្តាសន្តិសុខ សណ្តាប់ធ្នាប់សង្គមធ្វើឱ្យទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនាខេត្តបាត់ដំបង ពីមួយឆ្នាំទៅមួយឆ្នាំកាន់តែមានកំណើនគួរឱ្យកត់សម្គាល់។

បច្ចុប្បន្ននេះចំនួនភ្ញៀវដែលមកទស្សនានៅតំបន់សក្តានុពលមានការកើនឡើងដែលធ្វើឱ្យទេសចរបង្កើនការស្នាក់នៅកម្ពុជា និងបង្វែរទិសដៅពីការទស្សនាខេត្តដែលមានតំបន់ទេសចរណ៍សក្តានុពលខ្ពស់មកទស្សនាតំបន់ធម្មជាតិ ប្រវត្តិសាស្ត្រ កែច្នៃ ក្នុងខេត្តបាត់ដំបងនិងមួយចំនួនទៀតតាមរយៈក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍នានា ដែលគេពង្រីកកញ្ចប់ធ្វើដំណើរកម្សាន្តរបស់ក្រុមហ៊ុនទាំងនោះ តាមរយៈផ្លូវគោកនិងតាមដងស្ទឹងសង្កែនិងតាមតំបន់បឹងទន្លេសាប។ ចំនួនទេសចរណ៍នេះនឹងអាចថយចុះទៅវិញប្រសិនបើមិនមានការអភិវឌ្ឍតំបន់កម្សាន្តថ្មីៗបន្ថែម និងម្យ៉ាងទៀតបើតំបន់ធម្មជាតិត្រូវបានបំផ្លិចបំផ្លាញខ្វះការអភិរក្ស ព្រមជាមួយការខ្វះកិច្ចសហការជាមួយផ្នែកឯកជន ឬពីសហគមន៍ណាមួយដែលអាចចូលរួមច្នៃបង្កើតផលិតផលទាក់ទាញទេសចរក្រៅពីផលិផលដែលមានស្រាប់ដែលមានមិនអាចរួមចំណែកបង្កើនកំណើនទេសចរណ៍គ្រប់គ្រាន់ឡើយ។

កត្តាជាមូលដ្ឋានសំខាន់ចាំបាច់បំផុតនោះក្នុងការទាក់ទាញទេសចរគឺការអភិវឌ្ឍផលិតផលទេសចរណ៍ ហើយការអភិវឌ្ឍផលិតផលទាំងនោះគឺត្រូវផ្តោតលើការធ្វើពិពិធកម្មផលិតផលឱ្យមានលក្ខណៈថ្មីប្លែកពីគេដែលអាចស្របតាមទីផ្សារបច្ចុប្បន្ន និងលើកកម្ពស់ផលិតផលដែលមានស្រាប់ប្រកបដោយស្តង់ដារ និងមានគុណភាពខ្ពស់។ ការអភិវឌ្ឍផលិតផលទេសចរណ៍មានទាំងផ្នែករឹង និងផ្នែកទន់ដែលផ្តោតជាសំខាន់លើសម្បត្តិធនធានធម្មជាតិ និងប្រភពសក្តានុពលនានារបស់ខេត្តសម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់។

ការអភិវឌ្ឍវិស័យទេសចរណ៍តាមតំបន់អាទិភាពជាការចាំបាច់មួយ ហើយត្រូវកំណត់ទៅតាមប្រភេទផលិតផលទេសចរណ៍ដោយធ្វើការសិក្សានិងវាយតម្លៃឱ្យបានលម្អិតច្បាស់លាស់ ទៅលើប្រភពធនធានសក្តានុពលទាក់ទាញផ្នែកទេសចរណ៍ និងផលប៉ះពាល់ផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម។ ជាគោលការណ៍ និងទស្សនទានរួមក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ពិតជាមានភាពចាំបាច់ និងសារសំខាន់ណាស់ដែលក្នុងនោះរួមមានដូចជារាជរដ្ឋាភិបាល ផ្នែកឯកជន និងសមាគមន៍អង្គការដែលមិនមែនរដ្ឋាភិបាលជាដើម។

⌘ ស្ថិតិអាជីវកម្ម សេវាកម្មទេសចរណ៍ក្នុងខេត្តបាត់ដំបង ឆ្នាំ២០២០

១. សណ្ឋាគារក្នុងខេត្ត សរុបមានចំនួន ៤៦ កន្លែង ដែលមានបន្ទប់សរុបចំនួន ១,៨១៥ បន្ទប់

- បន្ទប់ គ្រែ ១ មាន៖ ៨៩០បន្ទប់
- បន្ទប់គ្រែ ២ មាន៖ ៩២៥បន្ទប់

សាលប្រជុំ មានចំនួន៖ ២២សាល

២. ផ្ទះភ្ញៀវក្នុងខេត្តសរុបមានចំនួន ៩៥ កន្លែង ដែលមានបន្ទប់សរុបចំនួន ១,៤៦៩ បន្ទប់ ក្នុងនោះ

- បន្ទប់គ្រែ ១មាន៖ ១,០៥៤ បន្ទប់
- បន្ទប់គ្រែ ២មាន៖ ៤១៥ បន្ទប់

៣. ផ្ទះស្នាក់ក្នុងខេត្តសរុបមាន មានចំនួន ០៣ កន្លែង ដែលមានបន្ទប់សរុបចំនួន ១០ បន្ទប់

៤. ភោជនីយដ្ឋាន-អាហារដ្ឋានក្នុងខេត្តសរុប មានចំនួន ១៣៥ កន្លែង

- តុចំនួន ១,៨៧០
- កៅអីចំនួន ៨,៧៧០

៥. ម៉ាស្សា សុខភាព-ស្ប៉ា ៖ មានចំនួន ៤ កន្លែង ស្មើនឹង ៣៨ គ្រែ (ផ្អាកបណ្តោះអាសន្ន)

៦. កីឡាទេសចរណ៍ ៖ មានចំនួន ០៣ កន្លែង

៧. ខារ៉ាអូខេ ៖ មានចំនួន ១៥ កន្លែង ស្មើនឹង ១៣២ បន្ទប់ (ផ្អាកបណ្តោះអាសន្ន)

៨. រង្គសាល-ឌីស្កូតែក ៖ មានចំនួន ០១ កន្លែង (ផ្អាកបណ្តោះអាសន្ន)

៩. ទីភ្នាក់ងារទេសចរណ៍ ៖ មាន ០២ សាខា (ផ្អាកបណ្តោះអាសន្ន)

១០. អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក ៖ មាន ០៦ សាខា

១១. អាជីវកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវគោក ៖ មាន ០១ អាជីវកម្ម

១២. មគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ ៖ មាន ៣០ នាក់

⌘ ស្ថិតិរមណីយដ្ឋាន និងគោលដៅទេសចរណ៍ក្នុងខេត្តបាត់ដំបង ឆ្នាំ២០២១

ក. រមណីយដ្ឋានទេសចរណ៍ មាន ២០ ទីតាំង ក្នុងនោះ

- រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ៖ ៥ ទីតាំង
- រមណីយដ្ឋានប្រវត្តិសាស្ត្រកែច្នៃ៖ ១ ទីតាំង
- រមណីយដ្ឋានវប្បធម៌ធម្មជាតិ៖១ ទីតាំង
- រមណីយដ្ឋាន ធម្មជាតិកែច្នៃ៖ ១០ ទីតាំង
- កីឡាទេសចរណ៍ (កែច្នៃ)៖ ៣ ទីតាំង

ខ. សហគមន៍ និងអេកូទេសចរណ៍មាន ០៤ ទីតាំង

គ. គោលដៅទេសចរណ៍មាន ៥៤ ទីតាំងក្នុងនោះ

- ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ៖ ៥ ទីតាំង
- ទេសចរណ៍សិល្បៈ៖ ៤ ទីតាំង
- ធម្មជាតិកែច្នៃ៖ ១១ ទីតាំង
- ធម្មជាតិ៖ ១១ ទីតាំង
- កែច្នៃ៖ ៩ ទីតាំង
- ផលិតផលគាំទ្រទេសចរណ៍៖៨ ទីតាំង
- ផ្សារទេសចរណ៍៖ ៣ ទីតាំង
- ទេសចរណ៍ប្រវត្តិសាស្ត្រ៖ ៣ ទីតាំង

ឃ. ទេសចរណ៍សាសនាមាន៖ ២២ ទីតាំង

ង. កសិទេសចរណ៍មាន៖ ០៤ ទីតាំង

តាមភូមិសាស្ត្រជាក់ស្តែងបាត់ដំបងជាខេត្តមួយដែលស្ថិតក្នុងចំណោមខេត្តជុំវិញបឹងទន្លេសាបនៃប្រទេសកម្ពុជាដែលស្ថិតលើទីតាំងអំណោយផលមានសម្បទាទេសចរណ៍សមស្របអាចឆ្លើយតបទៅនឹងតម្រូវការទេចរណ៍បានគ្រប់គ្រាន់។ តំបន់គោលដៅក្នុងខេត្តបាត់ដំបងអាចតភ្ជាប់ទៅកាន់ខេត្តនៅតាមបណ្តាភូមិភាគពាយ័ព្យ និងសម្រួលដល់ការដំណើររបស់ទេសចរបានយ៉ាងល្អប្រសើរ។ លើសពីនេះទៅទៀតភ្ញៀវដែលមកទស្សនាខេត្តបាត់ដំបងក៏អាចភ្ជាប់ដំណើរកម្សាន្តរបស់ពួកគេទៅកាន់ប្រទេសថៃ និងតំបន់ប្រាសាទអង្គររួចក៏អាចបន្តដំណើរ

ចាកចេញតាមរយៈការហោះហើរពីខេត្តសៀមរាប ទៅកាន់តំបន់គោលដៅ និងប្រទេសផ្សេងៗទៀតក្នុងតំបន់ជុំវិញបានផងដែរ។

| បរិយាយ | ឯកតា | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|
| **សណ្ឋាគារ** | បន្ទប់ | ១,៩៨៥ | ១,៩៧៥ | ១,៨៣៥ | ១,៨៦៦ | ១,៩៣៤ |
| **ផ្ទះសំណាក់** | បន្ទប់ | ១,១៩៩ | ១,៣១៧ | ១,៤៣៥ | ១,៤១៦ | ១,៤៥៩ |
| **ភោជនីយដ្ឋាន** | កៅអី | ៤,២៣៣ | ៤,២០៥ | ៤,៤៧៦ | ៦,០៨០ | ៥,៩០៩ |
| **ទូកដឹកភ្ញៀវ** | ទូក | ៣០ | ២៥ | ២០ | ១៥ | ១២ |
| **មគ្គុទេសក៏ទេសចរណ៍** | នាក់ | ០០ | ០១ | ០០ | ០២ | ៣០ |

តារាងទី១៖ ប្រភពមន្ទីរទេសចរណ៍ខេត្តបាត់ដំបង

### ខ. ផលិតផលទេសចរណ៍កន្លែងលក់វត្ថុអនុស្សាវរីយ៍

ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ការពង្រឹងសមត្ថភាព និងការថែរក្សាវប្បធម៌ប្រពៃណីរបស់ប្រជាជនដែលក្នុងនោះការអភិវឌ្ឍជំនាញក៏ត្រូវបានពង្រឹង និងយកចិត្តទុកដាក់ផងដែរ។ ជាងនេះទៅទៀតចំនួនអ្នកលក់វត្ថុអនុស្សាវរីយ៍ក្នុងក្រុងបាត់ដំបងមិនសូវមានចំនួនច្រើន ហើយភាគច្រនមានលក់តាមផ្ទះ បណ្ណាគារ ទីផ្សារ និងតាមរមណីយដ្ឋាន ដោយភាគច្រនជារបស់កែច្នៃពីធនធានធម្មជាតិក្នុងស្រុកដែលមាន។ តាមរយៈរបកគំហើញនេះមន្ទីរទេសចរណ៍ខេត្តបានធ្វើការផ្សព្វផ្សាយ និងសម្របសម្រួលឲ្យអាជីវករចូលរួមក្នុងការលើកស្ទួយសិល្បៈខ្មែរដែលកើតចេញពីស្នាដៃកូនខ្មែរ តាមរយៈការលក់វត្ថុអនុស្សាវរីយ៍ដែលមានដូចជាគំនូរ គ្រឿងចម្លាក់ថ្មត្បូង ឈើ និងសម្ភារៈប្រើប្រាស់ដែលធ្វើពីសូត្រ ក្រមា ត្នោត ដូង ផ្តៅ ឬស្សីជាដើម។

| ទីតាំង | ឈ្មោះហាងលក់វត្ថុអនុស្សាវរីយ៍ | ប្រភេទវត្ថុអនុស្សាវរីយ៍ |
|---|---|---|
| ក្រុងបាត់ដំបង | សម្បត្តិវិជ្ជា | រូបចាក់ (អំបោះ) |
| | ហាក់ ប៊ុនធឿន | គ្រឿងចម្លាក់ថ្ម និងគំនូរ |
| | មួយ គត់ | គ្រឿងចម្លាក់ឈើ |
| | ឃួន ប៊ុនធី | គ្រឿងចម្លាក់ឈើ |
| | ឡូនលី ទ្រី កាហ្វេ ណោតឆ័រ ប៊ូទិក ស្ប៉ា | គ្រឿងប្រាក់ គ្រឿងចម្លាក់ឈើ និងថ្ម |
| | ដឹ ហ្គេកូ | ប្រាក់ ស្ពាន់ លង្ហិន |
| | Bric-a-Brac Battambong | អំបោះ ប្រាក់ ស្ពាន់ គំនូរ |
| | ឥន្ទ្រទេវី | ចម្រុះ |
| | ឡាភីហ្សា | ប្រាក់ ស្ពាន់ លង្ហិន |

តារាងទី២៖ ប្រភពមន្ទីរទេសចរណ៍ខេត្តបាត់ដំបង (ទីតាំងលក់វត្ថុអនុស្សាវរីយ៍)

## ២.២. សក្តានុពលទេសចរណ៍ក្នុងក្រុងបាត់ដំបង

ខេត្តបាត់ដំបង ជាមេដៃកងក់មួយនៃតំបន់នេះដែលមានសក្តានុពលទាក់ទាញទេសចរណ៍។ ចក្ខុវិស័យនៃការអភិវឌ្ឍទេសចរណ៍ក្នុងខេត្តបាត់ដំបង គឺការជម្រុញការអភិរក្សទេសចរណ៍ ដែលជាទេសចរណ៍វប្បធម៌ និងធម្មជាតិ ប្រកបដោយការទទួលខុសត្រូវ និងនិរន្តភាពដោយស្រូបយកផលប្រយោជន៍ ពីវិស័យទេសចរណ៍រួមចំណែក កសាងសេដ្ឋកិច្ចសង្គម បង្កើតឱកាសការងារ និងការកាត់បន្ថយភាពក្រីក្រ។ ក្នុងនោះការអភិវឌ្ឍគោលដៅទាក់ទាញទេសចរណ៍ គឺត្រូវសម្រេចឱ្យបានទាំងបរិមាណនិងគុណភាពត្រូវប្រើឱ្យអស់លទ្ធភាពនូវសក្តានុពលដែលមានប្រកបដោយមនសិការ និងត្រូវគោរពដល់តម្លៃវប្បធម៌សង្គម ជាតិទាំងមូល។ ការអភិវឌ្ឍតំបន់ទេសចរណ៍ត្រូវធានាគ្រប់គ្រង ទប់ស្កាត់ ការប៉ះពាល់អវិជ្ជមាននៃទេសចរណ៍លើសេដ្ឋកិច្ចវប្បធម៌សង្គម និងបរិស្ថាន។ ទន្ទឹមនឹងការងារដែលត្រូវអនុវត្ត ត្រូវសហការជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យមើលទាំងអស់គ្នានូវចំណុចខ្លាំង ចំណុចខ្វះខាត ភាពងាយស្រួលការប្រឈម ដើម្បីពង្រឹង និង អភិវឌ្ឍន៍ផលិតផលទេសចរណ៍របស់យើងទៅអនាគតប្រកបដោយគុណភាព និងនិរន្តរភាព។

យោងតាមការសិក្សារបស់មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ភ្ញៀវទេសចរជនជាតិបារាំងឈរលើលំដាប់ទី១ ដែលមកទស្សនាខេត្តបាត់ដំបងច្រើនជាងគេ ព្រោះទីនេះសម្បូរនូវសំណង់អភិរក្សតាំងពីសម័យអនានិគមបារាំង ដែលជាកត្តាមួយទាក់ទាញទេសចរបារាំង និងទេសចរអឺរ៉ុបផ្សេងៗមកបាត់ដំបងយ៉ាងច្រើន។ ជាទូទៅភ្ញៀវទេសចរដែលធ្វើដំណើរមកកាន់ខេត្តបាត់ដំបងស្នាក់នៅជាមធ្យមចំនួន ០៣ថ្ងៃដោយប្រើប្រាស់ សេវាដឹកជញ្ជូន សេវាស្នាក់នៅ សេវាម្ហូបអាហារ សេវាភេសជ្ជៈ សេវាមគ្គុទ្ទេសក៍ សេវាកម្សាន្ត សេវាទស្សនា និងទិញវត្ថុអនុស្សាវរីយ៍ ក្នុងនោះភ្ញៀវជាតិម្នាក់ចំនាយជាមធ្យម ៥០ដុល្លារអាមេរិកនិងភ្ញៀវអន្តរជាតិម្នាក់ចំនាយជាមធ្យម ១១០ ដុល្លារអាមេរិក ។

រយៈពេល៥ឆ្នាំចុងក្រោយ វិស័យទេសចរណ៍មានការរីកចម្រើយ៉ាងឆាប់រហ័សគួរកត់សម្គាល់។ ចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិបង្កើនសន្ទុះកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ នេះហើយដែលជាកត្តាលីករជម្រុញឱ្យមានការវិនិយោគលើវិស័យទេសចរណ៍កាន់តែខ្លាំងក្លាផងដែរ។ តែគួរឱ្យសោកស្ដាយក្នុងវិបត្តិកូវីដ-១៩នេះ វិស័យទេសចរណ៍បានទទួលរងផលប៉ះពាល់យ៉ាងខ្លាំង។ ភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិបានធ្លាក់ ខណៈពេលដែលទីផ្សារទេសចរសំខាន់ៗដែលតែងមកកម្សាន្តទស្សនាខេត្តបាត់ដំបង ត្រូវបានរាជរដ្ឋាភិបាលសម្រេចផ្អាកទិដ្ឋការ ចូលមកកម្ពុជា ដើម្បីទប់ស្កាត់នូវការរីករាលដាលជំងឺកូវីដ-១៩ ក្នុងនោះមានដូចជា ជនជាតិបារាំង, អាមេរិក, អេស្ប៉ាញ, អាល្លឺម៉ង់ជាដើម។ កត្តាទាំងនេះហើយបណ្ដាលឱ្យអាជីវកម្មមួយចំនួនធំត្រូវសម្រេចចិត្តបិទដំណើរ ការអាជីវកម្មមួយរយៈ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ការពារការចម្លងដល់បុគ្គលិក និងម្ចាស់អាជីវកម្មផ្ទាល់ និងជួបប្រទះបញ្ហាហិរញ្ញវត្ថុ (មិនមានចំនូលដើម្បីទប់ទល់ការចំណាយ) និងអាជីវកម្មមួយចំនួន ទៀតដូចជា ខារ៉ាអូខេ ក្លិបកម្សាន្ត បៀរហ្គាឌិន ត្រូវបានរាជរដ្ឋាភិបាលសម្រេចឱ្យផ្អាកដំណើរការបណ្ដោះអាសន្ន។ អាចនិយាយបានថា ចំនួនភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិបានធ្លាក់ចុះយ៉ាងខ្លាំងដល់ចំនុចអប្បរិមាដែល មិនធ្លាប់មានពីមុនក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

| ស្ថិតិទេសចរណ៍ | ឯកតា | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|
| **ទេសចរអន្តរជាតិ** | នាក់ | ៩៦,៤៦០ | ៩៨,៣០៤ | ១០០,៧៤៤ | ១០១,៤៧៣ | ៣៣,៨៨៧ |
| **ទេសចរជាតិ** | នាក់ | ៥១៣,៣៩០ | ៦១៨,១៣៩ | ៥៦៧,៥៨៨ | ៥៩០,៣១៤ | ៤៧០,៨៧២ |
| **សេវាស្នាក់នៅ** | បន្ទប់ | ៣,១៥៧ | ៣,៤៣១ | ៣,៤១៧ | ៣,៥៣៩ | ៣,២៨៤ |
| **កម្លាំងពលកម្ម** | នាក់ | ៤,៤៣៧ | ៣,៦៨០ | ៣,៥៩១ | ៤,៣០៦ | ៤,០៣២ |
| **ចំណូលទេសចរណ៍** | លាន $ | ៣០.៧៨ | ៣៦.៨០ | ៣៩.៤៦ | ៤០.១៧ | ២៧.២៧ |

តារាងទី៣៖ ទិន្នន័យភ្ញៀវទេសចរឆ្នាំ២០១៦-២០២០(ប្រភពៈមន្ទីរទេសចរណ៍ខេត្តបាត់ដំបងឆ្នាំ២០២០)

ក្នុងឆ្នាំ២០២០ វិស័យទេសចរណ៍បានបង្កើតចំណូលចូលសេដ្ឋកិច្ចខេត្តប្រមាណ ២៧.២៧ លានដុល្លារសហរដ្ឋអាមេរិក និងបានផ្តល់ឱកាសការងារដោយផ្ទាល់ចំនួន ៤,០៣២ នាក់ (ស្ត្រី ២១៨២ នាក់) និងដោយប្រយោលរាប់ម៉ឺននាក់ទៀតដូចជា ម៉ូតូឌុប អ្នកលក់ចាប់ហួយ អ្នកចិញ្ចឹមមាន់ទាជ្រូកត្រី អ្នកដាំបន្លែ ម្ចាស់ចំការ សិប្បកម្មនានា អ្នកលក់ដូរនៅតាមទីផ្សារ។ល។ យើងសង្កេតឃើញថា ក្នុងកំឡុងវិបត្តិកូវីដ១៩នេះ អាជីវកម្ម សេវាកម្មទេសចរណ៍បានកាត់បន្ថយចំនួនបុគ្គលិកយ៉ាងច្រើន ដែលនាំឱ្យធនធានមនុស្សក្នុងវិស័យទេសចរណ៍ទទួលរងផលប៉ះពាល់ និងបាត់បង់ការងារប្រមាណ ជាង ៥០ ភាគរយ។ (ប្រភពៈ មន្ទីរទេសចរណ៍ខេត្តបាត់ដំបងឆ្នាំ២០២០)

### ក. វិស័យទេសចរណ៍ក្នុងក្រុងបាត់ដំបង

ទេសចរណ៍ទីក្រុងជានិន្នាការទេសចរណ៍ដ៏សំខាន់មួយនាពេលបច្ចុប្បន្ននេះ។ ទេសចរចាប់ផ្តើមមានទំនោរទៅលើការទស្សនកិច្ចនៅតាមទីក្រុងដែលមានភាពទាក់ទាញនូវវប្បធម៌ ប្រវត្តិសាស្ត្រ ភាពសំប្បូរបែបនិមិត្តរូបនៃភាពទោល និងបរិយាកាសល្អប្រសើរ។ ប្រសិនបើទីក្រុងមានការរៀបចំបានល្អ និងមានភាពទាក់ទាញ នោះភ្ញៀវទេសចរនឹងមានការចាប់អារម្មណ៍ ចង់មកទស្សនាកម្សាន្ត ដើម្បីទទួលបាននូវបទពិសោធន៍ថ្មីៗ។ ទីក្រុងមួយចំនួនមានភាពអំនោយផលស្រាប់ បានទាក់ទាញភ្ញៀវទេសចរជាច្រើនលាននាក់ក្នុងមួយឆ្នាំៗ។ ទេសចរណ៍ទីក្រុងងាយស្រួលក្នុងការអភិវឌ្ឍព្រោះជាបណ្តុះនៃអាជីវកម្ម សេវាកម្មគ្រប់ប្រភេទស្រាប់ ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងភាពងាយស្រួលជាច្រើនទៀត។ ក៏ប៉ុន្តែ វាមានការលំបាកយ៉ាងខ្លាំងត្រង់ផលប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅ ព្រោះទីក្រុងជាកន្លែងប្រមូលផ្តុំនៃមនុស្ស។ ដូចនេះ បើចង់រៀបចំទីក្រុងឱ្យមានចរិកលក្ខណៈជាទីក្រុងទេសចរណ៍ ចាំបាច់ដាច់ខាតត្រូវមានការចូលរួមពីប្រជាពលរដ្ឋទាំងអស់។ ដើម្បីឱ្យមានការចូលរួម ត្រូវឱ្យមានការផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹង លើកទឹកចិត្ត និងផ្តល់នូវអត្ថប្រយោជន៍

មួយចំនួនដល់ពួកគាត់។ ហេតុនេះ ទាមទារឱ្យអាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវសហការគ្នា និងអនុវត្តការងារប្រកបដោយឆន្ទៈ និងការទទួលខុសត្រូវ។

ក្រុងបាត់ដំបងត្រូវបានចាត់ទុកជាទីក្រុងស្រស់បំព្រងមួយរបស់កម្ពុជា។ ក្រុងបាត់ដំបង ជាបេះដូងរបស់ខេត្តបាត់ដំបង ក្នុងនោះសង្កាត់ស្វាយប៉ោជាសង្កាត់ដែលប្រជុំដោយតំបន់រដ្ឋបាល និងលេចធ្លោជាងគេ។




រូបភាពទី២៖ ផែនទីសង្កាត់ក្នុងក្រុងបាត់ដំបង

ក្រុងបាត់ដំបង បានជាប់ជាទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី១ (២០១៨-២០២០) ហើយបានទទួលឡាបិលទីក្រុងទេសចរណ៍ស្អាតអាស៊ាននៅខេត្តឈៀងម៉ៃ ព្រះរាជាណាចក្រថៃ និងបន្តគ្រងជ័យលាភីលេខមួយ ផ្ការំដួល៣ទង ក្នុងការប្រឡងប្រណាំងទីក្រុងស្អាតកម្ពុជា លើកទី២ផងដែរ (២០១៨-២០២១)។ ភាពទាក់ទាញសំខាន់ៗរបស់ក្រុងបាត់ដំបងមានដូចជា ផ្ទះខ្មែរបុរាណដែឡមានអាយុកាលលើសពី១០០ឆ្នាំ ស្ពានថ្មចាស់មុខសាលាខេត្ត អគារស្ថាបត្យកម្មសម័យអាណានិគមបារាំង ប្រវត្តិសាស្ត្រសម័យលោកម្ចាស់ វត្តបុរាណ សួនច្បារសាធារណៈជាច្រើនកន្លែង ដងស្ទឹងសង្កែដ៏ល្បីល្បាញតាមរយៈបទចំរៀងរបស់អធិរាជសំឡេងមាសស៊ិន ស៊ីសាមុត ការសម្តែងរបស់អង្គការហ្វារពន្លឺសិល្បៈ គំនូសសិល្បៈលើជញ្ជាំងតាមផ្លូវ និងសម្បទាទ្រទ្រង់ដ៏សម្បូរបែបជាច្រើន។ មិនតែប៉ុណ្ណោះ អត្រាចំណាយផ្សេងៗរបស់ទេសចរក្នុងក្រុងបាត់ដំបង មានកម្រិតទាប ដែលជាផ្នែកមួយលើកទឹកចិត្តដល់ភ្ញៀវទេសចរសម្រាប់ការស្នាក់នៅ កម្សាន្តរយៈពេលវែង។




រូបភាពទី៣៖ ភ្ញៀវទេសចរណ៍ទស្សនាខេត្តបាត់ដំបង ២០១៦ ដល់ឆ្នាំ ២០២០

## ២.២.១. គោលដៅទាក់ទាញទេសចរ

ក្រុងបាត់ដំបង ជាទីក្រុងមួយដែលស្ថិតនៅប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា ដែលមានទីប្រជុំនៅអមដងស្ទឹងសង្កែដែលទីក្រុងនេះមានវិសាលភាពធំ និងជាប៉ូលសេដ្ឋកិច្ចយ៉ាងសំខាន់។ នៅពេលលឺឈ្មោះខេត្តបាត់ដំបង គេតែងនឹកឃើញដល់វាលស្រែវាលស្រូវពណ៌ខៀវ និងល្បឿងទុំ តែនៅពេលគេនិយាយពីក្រុងបាត់ដំបង គឺគេនឹកឃើញដល់ដងស្ទឹងសង្កែ និងទីក្រុងបេតិកភណ្ឌ ដែលមានវប្បធម៌ចម្រុះសម័យកាលផងដែរ ដោយសារតែទីក្រុងនេះ មានរឿងរ៉ាវប្រវត្តិសាស្ត្រជាច្រើនសម័យកាល ដូចជាសម័យកាលបាត់ដំបងសម័យលោកម្ចាស់ បាត់ដំបងសម័យបារាំង បាត់ដំបងសម័យសង្គមរាស្ត្រនិយម និងសម័យក្រោយៗមកទៀត រហូតដល់សម័យបច្ចុប្បន្ននេះ។

អ្វីដែលពិសេសនោះ គឺក្រុងបាត់ដំបង មានសំណង់ស្ថាបត្យកម្មចម្រុះសម័យកាល ដែលទទួលបាននូវការចាប់អារម្មណ៍ សំណង់ស្ថាបត្យកម្មសំខាន់ៗទាំងនោះ បានលេចរូបរាងឡើងតាមសម័យកាលនីមួយៗ ដែលមានដូចជា៖

- ផ្ទះបុរាណខ្មែរ

- សំណង់ស្ថាបត្យកម្មសម័យលោកម្ចាស់មានដូចជា៖ អគារសាលាខេត្តចាស់ (សាងសង់សម័យលោកម្ចាស់)
- សំណង់បែបសាសនា វត្តអារាមសម័យលោកម្ចាស់ (ព្រះវិហារមុខប្រជើត ដំបូលលយ ស្ទីលបាត់ដំបង)
- សំណង់ស្ថាបត្យកម្មសម័យអាណានិគម៖ សំណង់ផ្ទះល្វែងផ្លូវលេខ០១ ដល់ផ្លូវលេខ០៣ ស្ពានថ្មចាស់មុខសាលាខេត្ត និងផ្សារណាត់។
- សំណានង់ស្ថាបត្យកម្មសម័យសង្គមរាស្ត្រនិយម៖ កីឡាមណ្ឌលហៃលទឹកព្រះសីហនុ ស្ពានថ្មថ្មីស្ទឹងសង្កែ (ផ្លូវជាតិលេខ៥) ម៉ូតែលបាត់ដំបង អាកាសយានដ្ឋានបាត់ដំបងបែកចាន សាលពិព័រសង្គមរាស្ត្រនិយម សារៈមន្ទីរខេត្តបាត់ដំបង ចំណតរថភ្លើងក្រុងបាត់ដំបង អគារកណ្តាលវិទ្យាល័យនេតយ៉ង់ អគារអ៊ាបប៊ុយគី ក្នុងវិទ្យាល័យនេតយ៉ង់ អគារអ៊ាបឃុត (អគារចាស់) សាកលវិទ្យាល័យភូមិន្ទបាត់ដំបង។ សំណង់ស្ថាបត្យកម្មទាំងអស់នេះហើយ ជាគ្រឿងលំអរ ដែលបន្ថែមសម្រស់ដល់ទីក្រុងបាត់ដំបងឱ្យកាន់តែស្រស់ស្អាត និងមានភាពទាក់ទាញ ដែលវាបានក្លាយជាផលិតផលសម្រាប់ទេសចរណ៍បែបទីក្រុង មិនអាចកាត់ថ្លៃបានោឡើយ។

គោលដៅសម្រាប់ទាក់ទាញទេសចរណ៍វប្បធម៌នាក្រុងបាត់ដំបងមានដូចជា៖

១. តំបន់សហគមន៍ទេសចរណ៍វប្បធម៌វត្តគរ៖ ផ្ទះបុរាណដែលមានអាយុ១០០ឆ្នាំចំនួន ២ផ្ទះក្នុងចំណោម២០ផ្ទះ ស្ថិតនៅភូមិវត្តគរ សង្កាត់វត្តគរក្រុងបាត់ដំបង ខេត្តបាត់ដំបង ត្រូវបានកសាងឡើងនៅឆ្នាំ១៩២០ បាននិងកំពុងទាក់ទាញភ្ញៀវទេសចរឲ្យទស្សនាជាហូរហែ នឹងបានជួយបង្កើនប្រាក់ចំណូលដល់ដល់ម្ចាស់ផ្ទះ និងប្រជាពលរដ្ឋនៅតំបន់នោះបានមួយកំរិតថែមទៀត។

២. សារមន្ទីរប្រវត្តិសាស្ត្រខេត្ត៖ ជាទីតាំងវប្បធម៌ប្រវត្តិសាស្ត្រដែលបានកសាងឡើងនាសម័យលោកម្ចាស់ ជាកន្លែងសម្រាប់លោកម្ចាស់ស្នាក់នាសម័យអតីតកាល។

៣. សារមន្ទីរវប្បធម៌ខេត្ត៖ សារមន្ទីរខេត្តបាត់ដំបង មានទីតាំងស្ថិតនៅស្របតាមមាត់ស្ទឹងសង្កែត្រើយខាងលិចស្ថិតនៅភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង នៅខាងជើងសាលាខេត្តប្រមាណ ៣០០ម៉ែត្រ។ អ្នកទេសចរអាចទៅទស្សនានៅទីនោះដោយ ថ្មើរជើងបាន។

៤. សំណង់ស្ថាបត្យកម្មប្រវត្តិសាស្ត្រដែលកសាងក្នុងសម័យបារាំង៖ ជាសំណង់វប្បធម៌ប្រវត្តិសាស្ត្រដែលបានបន្សល់ទុកពីសម័យបារាំងដែលស្ថិតតាមដងស្ទឹងសង្កែក្រុងបាត់ដំបង។

៥. អគារមន្ទីរទេសចរណ៍ខេត្តៈ អគារសំខាន់នៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបង គឺជាអគារដែលបានកសាងឡើងក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩២០ នាពេលដែលអាណានិគមបារាំងបានត្រួតត្រាខេត្តបាត់ដំបង បន្ទាប់លោកម្ចាស់បានភៀសខ្លួនទៅបច្ចឹម។អគារសំខាន់នៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបងនេះ ត្រូវបានសាងសង់ឡើងតាមរចនាបថអាណានិគម ទាំងការប្រើប្រាស់ពណ៌ និងមុខងារនៃការប្រើប្រាស់។ អគារត្រូវបានគេសន្និដ្ឋានថា ជាអគារសម្រាប់លំនៅឋានអ្នកស្នាក់នៅជនជាតិបារាំង ដែលគ្រប់គ្រងខេត្តនាសម័យនោះ ។

៦. ស្ពានថ្មចាស់ៈ មានទីតាំង ស្ថិតនៅចំពីមុខអគារសាលាខេត្តចាស់ ឆ្លងកាត់ស្ទឹងសង្កែ ត្រូវបានសាងសង់ឡើងនៅឆ្នាំ ១៩១៦ ដែលមានភាព ស៊ីវិល័យតាមរចនាបថបារាំង។ បច្ចុប្បន្នស្ពាននេះ មិនត្រូវបានអនុញ្ញាតឲ្យរថយន្ត រឺម៉ូតូឆ្លងកាត់ឡើយ ដោយសារមានសភាពទ្រុឌទ្រោម។

## ២.៣. ទីតាំងភូមិសាស្ត្រនៃតំបន់គោលដៅនីមួយៗនៅក្នុងក្រុងបាត់ដំបង

### ក. ស្ពានថ្មចាស់

ស្ពានថ្មចាស់ មានទីតាំង ស្ថិតនៅចំពីមុខអគារសាលាខេត្តចាស់ ឆ្លងកាត់ស្ទឹងសង្កែ ត្រូវបានសាងសង់ឡើងនៅឆ្នាំ ១៩១៦ ដែលមានភាព ស៊ីវិល័យតាមរចនាបថបារាំង។ ទីតាំងស្ថិតនៅភូមិកម្មករ សង្កាត់ស្វាយប៉ោល ក្រុងបាត់ដំបង។ បច្ចុប្បន្នស្ពាននេះ មិនត្រូវបានអនុញ្ញាត ឲ្យរថយន្ត រឺម៉ូតូឆ្លងកាត់ឡើយ ដោយសារមានសភាពទ្រុឌទ្រោម។ ស្ពាននេះមានអាយុកាលជាង ១00ឆ្នាំ នៅក្បាលស្ពានមានលំអរដោយតោថ្មចំនួនពីរបែរមុខទៅរកសាលាខេត្ត ហើយវាមានឈ្មោះល្បីល្បាញតាមរយៈបទចំរៀងជាច្រើនរបស់អធិរាជសម្លេងមាស និងការនិពន្ធចម្រៀងដោយករីគង់ ប៊ុនឈឿន ។ ដោយសារស្ពានមានសភាពទ្រុឌទ្រោម មិនអាចឲ្យរថយន្តឆ្លងកាត់បាន ទើបរដ្ឋបាលខេត្ត បានសាងសង់ស្ពានមួយទៀតនៅជិតគ្នា ដែលមានឈ្មោះថា ស្ពាន១៣ មករា ដើម្បីសម្រួលការធ្វើដំណើរឆ្លងកាត់ស្ទឹងសង្កែ។



រូបភាពទី៤៖ ស្ពានថ្មចាស់នាក្រុងបាត់ដំបង

## ខ. សារៈមន្ទីរប្រវត្តិសាស្ត្រខេត្ត

សារៈមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង ជាសំណងវប្បធម៌ប្រវត្តិសាស្ត្រដែលស្ថិតក្នុង ភូមិកម្មករ សង្កាត់ស្វាយប៉ោល ក្រុងបាត់ដំបង ជាអគារចំណាស់មានអាយុកាលជាង១០០ឆ្នាំ ជាអតីតផ្ទះលោកម្ចាស់កាលពីសម័យមុន មានលម្អដោយសួនច្បារ ដើមចំប៉ី។ នៅផ្នែកខាងក្នុងមានតាំងលម្អដោយសម្ភារៈបុរាណខ្មែរ និងចាប៉ីយក្ស។ អគារនេះជាសំណង់ប្រវត្តិសាស្ត្រដ៏ល្អឯក ដោយស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលខេត្តបាត់ដំបង។




រូបទី៥៖ សារៈមន្ទីរប្រវត្តិសាស្ត្រខេត្ត

### គ. សារៈមន្ទីរវប្បធម៌

សារមន្ទីរខេត្តបាត់ដំបង មានទីតាំងស្ថិតនៅស្របតាមមាត់ស្ទឹងសង្កែត្រើយខាងលិច ស្ថិតនៅភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង នៅខាងជើងសាលាខេត្តប្រមាណ ៣០០ម៉ែត្រ។ អ្នកទេសចរអាចទៅទស្សនានៅទីនោះដោយ ថ្មើរជើងបាន។ សារមន្ទីរនេះសាងសង់ឡើងនៅឆ្នាំ ១៩៦៨ តាមរចនាបថខ្មែរបុរាណនិងត្រូវបានសម្ពោធឲ្យប្រើប្រាស់ដោយ ព្រះបាទសម្តេចព្រះនរោត្តមសីហនុ។ សារមន្ទីរខេត្តបាត់ដំបងមានទីធ្លាធំល្មម ហើយមានកន្លែងចតរថយន្តធំទូលាយ ព្រមទាំងសួនច្បារយ៉ាងស្រស់ បំព្រង។ នៅខាងក្នុងអគារមានដាក់តាំងវត្ថុបុរាណជាច្រើន ដែលមានតំលៃទាក់ទងទៅនឹងស្នាដៃស្ថាបត្យកម្មខាងសាសនា សិល្បៈខ្មែរ ព្រមទាំងមានផ្ទាំងគំនូរកុលភាគន៍។ ភាគច្រើនវត្ថុបុរាណទាំងនោះមានដូចជា រូបបដិមាករ រូបចំលាក់ បំណែកថ្មប្រាសាទបាក់បែក ក្រៅពីនោះមានវត្ថុខ្លះសល់ពីសម័យបុរេប្រវត្តផងដែរ។ នៅតាមខឿនមានតាំងផ្ទាំងគំនូរ និងរូបថតជាច្រើនផងដែរ។ លើសពីនេះមានស្រះចិញ្ចឹមត្រីដែលភ្ញៀវទេសចរទៅទស្សនាអាចអង្គុយលេង អាន សៀវភៅនៅទីនោះដោយបរិយាកាសត្រជាក់ និងស្ងប់ស្ងាត់។




រូបភាពទី៦៖ សារៈមន្ទីរវប្បធម៌

### ឃ. សំណង់ស្ថាបត្យកម្មប្រវត្តិសាស្ត្រ

ប្រទេសកម្ពុជាធ្លាប់ស្ថិតនៅក្រោមអាណានិគមបារាំងអស់រយៈពេល ៩០ ឆ្នាំគត់ គិតពីឆ្នាំ ១៨៦៣ មកដល់ឆ្នាំ ១៩៥៣។ ក្នុងរយៈពេលជិត ១០០ ឆ្នាំ នៃការគ្រប់គ្រងរបស់បារាំងបានបន្សល់ទុកនូវអនុស្សាវរីយ៍ជាច្រើនសម្រាប់ប្រទេសកម្ពុជា។ ជាពិសេស គឺសំណង់អគារដែលសង់ឡើងយកម៉ូដតាមស្ថាបត្យកម្មទំនើបបារាំង និងសំណង់ខ្លះទៀតគូរប្លង់ និង រចនាផ្ទាល់ដោយស្ថាបត្យករបារាំងតែម្តង ស្ថិតនៅរាយប៉ាយនៅក្នុងទីក្រុង ដែលជាអតីតទីប្រជុំជនសំខាន់នៅសម័យអាណានិគម ដូចជា ក្រុងបាត់ដំបង ជាដើម។ សំណង់បន្សល់ទុកពីសម័យបារាំងនៅក្រុងបាត់ដំបងមួយភាគធំ គឺជាផ្ទះល្វែងនៅច្រាំងខាងលិច នៃស្ទឹងសង្កែ នៅតាមបណ្តោយផ្លូវលេខ ១ លេខ ២ និងលេខ ៣។ អគារមួយចំនួននៅតែគង់វង្សស្ថិតស្ថេរមកដល់សព្វថ្ងៃទទួលបានការលាបពណ៌ មើលទៅដូចជាអគារទើបនឹងសង់ថ្មី។ អគារមួយចំនួនតូចទៀត ត្រូវបានវាយចោល និង កសាងវិញ ដោយយកតាមគំរូប្លង់ដដែល។ ក្រៅពីនេះ នៅសល់អគារមួយចំនួន ដែលនៅរាយប៉ាយជុំវិញទីក្រុង។ សព្វថ្ងៃ អគារទាំងនោះជាកត្តាទាក់ទាញយ៉ាងខ្លាំងដល់ភ្ញៀវទេសចរឲ្យមកទស្សនាទីក្រុងនេះ។

សំណង់ទាំងនោះមានទីតាំងស្ថិតនៅក្នុងក្រុងបាត់ដំបង ដែលសំណង់ទាំងបានកសាងចាប់ពីឆ្នាំ ១៩០៧ រហូតដល់ឆ្នាំ ១៩៦០។



រូបភាពទី៧៖ សំណង់អគារអភិរក្ស

**ខ. អគារមន្ទីរទេសចរណ៍**

អគារនេះមានទីតាំងស្ថិតនៅស្ថិតចំពីមុខសាលាខេត្តបាត់ដំបង ដែលជាទីតាំងស្នូលនៃទីក្រុង ដែលមានលក្ខណៈប្រវត្តិ វប្បធម៌ និងទេសចរណ៍ចម្រុះ ស្របតាមបណ្តោយផ្លូវលេខ០១ផ្នែកខាងមុខ និងរ៉ូបតាមដងស្ទឹងសង្កែផ្នែកខាងក្រោយ ក្នុងភូមិសាស្រ្ត ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង។ អគារនៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបង គឺជាអគារដែលបានកសាងឡើងក្នុងកំឡុងទស្សវត្សឆ្នាំ១៩២០ នាពេលដែលអាណានិគមបារាំងបានត្រួតត្រាខេត្តបាត់ដំបង បន្ទាប់លោកម្ចាស់បានភៀសខ្លួនទៅបច្ចឹម។ អគារនៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបងនេះ ត្រូវបានសាងសង់ឡើងតាមរចនាបថអាណានិគម ទាំងការប្រើប្រាស់ពណ៌ និងមុខងារនៃការប្រើប្រាស់។ អគារត្រូវបានគេសន្និដ្ឋានថា ជាអគារសម្រាប់លំនៅឋានអ្នកស្នាក់នៅជនជាតិបារាំង ដែលគ្រប់គ្រងខេត្តនាសម័យនោះ ។

នៅកំឡុងឆ្នាំ១៩៩៧ អគារនេះត្រូវបានប្រគល់មកឲ្យក្រសួងទេសចរណ៍ ដើម្បីប្រើប្រាស់ជាមន្ទីរទេសចរណ៍ខេត្តបាត់ដំបង មកដល់បច្ចុប្បន្ននេះ។ លក្ខណៈពិសេសនៃអគារសំខាន់នៃមន្ទីរទេសចរណ៍ខេត្តបាត់ដំបងបងនេះគឺ៖

- ជាទម្រង់ប្រអប់បញ្ឈរ មានកំពស់០១ជាន់
- នៅផ្នែកខាងមុខនៃអគារគឺមានទ្វារធំចំនួន០១ បង្អួចតូចទម្រង់បញ្ឈរចំនួន០៤និងបង្អួចធំចំនួន០១
- នៅផ្នែកចំហៀងខាងជើងអគារនេះត្រូវបានរចនានូវទ្វារចូលចំនួន០១ និងបង្អួចចំនួន០៦
- នៅផ្នែកខាងត្បូង អគារនេះបានរចនាមានលក្ខណៈប្លែកយ៉ាងពិសេសដោយមានរានហានដែលមានកំពស់ប្រហែលកន្លះម៉ែត្រ និងមានទ្វារចូលចំនួន០១ និងបង្អួចចំនួន០៧
- នៅផ្នែកជណ្តើរអគារនេះត្រូវបានគេរចនាឡើងមានលក្ខណៈបត់កោងរមួលឆ្ពោះទៅជាន់ខាងលើ ដោយប្រើប្រាស់ឈើ និងជញ្ជាំងបេតុង មានចោះរន្ធពន្លឺចំនួន០៦ និងផ្ទឹមភ្ជាប់ជណ្តើរខាងលើគេប្រើប្រាស់ប្រភេទដែកអ៊ី(I)
- ការបើកលំហរធំៗនៃបង្អួច និងធ្វើជាលក្ខណៈពិសេសសំរាប់តំបន់ត្រូពិច ដែលអនុញ្ញាត្តឱ្យខ្យល់ និងពន្លឺចេញចូលបាន បង្ករលក្ខណៈងាយស្រួល និងផាសុកភាពដល់អ្នកប្រើប្រាស់អគារ។




រូបភាពទី៨៖ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង

## ច. តំបន់សហគមន៍ទេសចរណ៍វប្បធម៌វត្តគរ

ខេត្តបាត់ដំបង ត្រូវបានគេដឹងថា ជាខេត្តដែលមានបន្សល់សំណង់បែបបុរាណប្រវត្តិសាស្រ្តជាច្រើនពីសម័យអាណានិគមបារាំង និងផ្ទះបែបបុរាណតាំងពីរជ្ជកាលបាត់ដំបងសម័យលោកម្ចាស់ផងដែរ។ នៅក្នុងនោះផ្ទះបុរាណនៅក្រុងបាត់ដំបងទោះបីជាមានច្រើនខ្នងបន្សល់ទុកយ៉ាងណាក្តី តែមានត្រឹមតែផ្ទះ ២ខ្នងតែប៉ុណ្ណោះដែលបើកជាសាធារណៈឱ្យភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនាកម្សាន្តនោះ នោះគឺ ផ្ទះប៉ិត និងផ្ទះខសង។

១. ផ្ទះបុរាណម៉ូត "ខ សង" របស់យាយ យៀង

ផ្ទះខ្មែរបុរាណ "ម៉ូដ ខសង" ស្ថិតក្នុងខេត្តបាត់ដំបង សាងសងឡើងក្នុងឆ្នាំ ១៩០៧ តាំងពីមុនសម័យប៉ុលពត មកម្លេះ ។ ផ្ទះខ្មែរបុរាណមួយនេះមានអាយុ ១១១ឆ្នាំហើយ ក្រោយពីទឹកដីនៃខេត្តបាត់ដំបង បានកាត់ចេញពីថៃមកឲ្យខ្មែរវិញ។ ផ្ទះបុរាណនេះ បានក្លាយទៅជាផ្ទះដែលមានអាយុកាលចាស់ជាងគេនៅភូមិវត្តគរ

សង្កាត់គរ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ទន្ទឹមនឹងនេះ វាបានក្លាយជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់សម្រាប់អ្នកជំនាន់ក្រោយ បន្ទាប់ពីសម័យលោកម្ចាស់បានរលាយបាត់ទៅ។ លោក យាយ យៀង បានរស់នៅក្នុងផ្ទះជាកេរ្តិ៍ដូនតា ដែលសល់តាំងពីសម័យលោកម្ចាស់ ដោយសារតែផ្ទះនេះមានវ័យចំណាស់ជាង ១០០ ឆ្នាំ និង ជាប់ទាក់ទងប្រវត្តិសាស្ត្រ ផ្ទះនេះក៏បានទាក់ទាញភ្ញៀវបរទេស និង ខ្មែរខ្លះ ចូលទស្សនា មិនលស់ថ្ងៃ។ លោកយាយបានរៀបរាប់ថា អ្នកកសាងផ្ទះនេះ គឺជីដូនជីតារបស់គាត់ ដែលកាលណោះជាស្មៀនរបស់លោកម្ចាស់កថាថនឈុំ ស្ដេចត្រាញ់ចង្វាត់បាត់ដំបង (វាជាងារដែលស្ដេចថៃដាក់ឲ្យ) ។ ដោយនៅឆ្នាំ ១៩០៧ ទឹកដីបាត់ដំបងត្រូវកាត់មកឲ្យខ្មែរយើងវិញ ហើយជីតាលោកយាយជាស្មៀនលោកម្ចាស់ ដល់ពេលនោះលោកម្ចាស់ទៅស្រុកថៃក៏ហៅជីតាទៅជាមួយ តែដោយលោកតាមិនព្រមទៅ ក៏មកទិញដីមួយហិចតានៅទីនេះហើយសាងសង់ផ្ទះនេះឡើង។ រចនាបថផ្ទះនេះស្ថិតក្នុងប្រភេទផ្ទះខសង ឬផ្ទះដំបូលពីរជាន់ សសរវាធ្វើពីឈើធ្នឹក រនាបក្ដារធ្វើពីឈើក្រាវហើយមានពិតានមានលក្ខណខុសប្លែកពីផ្ទះឯទៀតៗធ្វើពីគគីរ។ ដូច្នេះហើយបានជាផ្ទះនេះមានខ្យល់អាកាសត្រជាក់ស្រួលណាស់។ ចំណែកជញ្ជាំងវិញ គឺប្រើបាយអរដែលលាយតាមរូបមន្តពិសេសរបស់ខ្មែរពីបុរាណមានកំបោរលាយខ្សាច់ ហើយខាងក្នុងមានឫស្សី និងស្ករក្រហម។ នៅតាមបង្អួច និងទ្វារសុទ្ធតែមានពាសដែកការពារមិនឲ្យចោរគាស់ចូលបាន។ នៅសម័យខ្មែរក្រហម កម្មាភិបាលខ្មែរក្រហមបានមកស្នាក់នៅផ្ទះនេះ ហើយខ្មែរក្រហមបម្រុងរុះរើផ្ទះនេះនៅខែចេត្រឆ្នាំ ១៩៧៩ តែពួកវៀតណាមវាយចូលមកខែមករា ក៏ខកខានមិនបានរើហើយលោកយាយក៏មកនៅផ្ទះនេះវិញរហូតដល់សព្វថ្ងៃ។ មកទល់ពេលនេះ ផ្ទះនេះមានចំណាស់ ១១១ឆ្នាំហើយ ហើយដើមឈើដែលនៅជុំវិញផ្ទះគឺ លោកតារបស់លោកយាយជាអ្នកដាំដោយផ្ទាល់ហើយមានអាយុ ១១០ឆ្នាំហើយ។ ទោះយ៉ាងណាផ្ទះបុរាណមួយនេះនៅតែមានភាពរឹងមាំដដែល និងមានការខូចខាតតិចតួចប៉ុណ្ណោះ។



រូបភាពទី៩៖ ផ្ទះ"ខ សង" ផ្ទះបុរាណនាក្រុងបាត់ដំបង

២. ផ្ទះប៉ិតបុរាណរបស់លោកយាយ ប៊ុន រឿង

ផ្ទះបុរាណរបស់លោកយាយ ប៊ុន រឿង បានកសាងឡើងនៅឆ្នាំ១៩២០ ធ្វើពីឈើ៣ប្រភេទ ដែលមានផ្នែកដំបូល និងសសរធ្វើពីឈើធ្នឹក ហោណាំងធ្វើពីឈើកកោះ ផ្នែកខាងក្នុងផ្ទះធ្វើពីឈើបេង ក្នុងរជ្ជកាលកាលព្រះបាទ ស៊ីសុវត្ថិ ។ ផ្ទះនេះសាងសង់ដោយលោកឧកញ៉ា នូ ពិនិត្យ ភីង និងភរិយា លោកស្រី យិន ។ លោកឧកញ៉ាជាមេទ័ព តែលុះដល់វ័យចំណាស់គាត់បានប្តូរមកធ្វើជាស្មាក្តីវិញ។ លោកទាំងពីរមាន កូន៧នាក់: ប្រុស ១ ស្រី៦។

ក្រោយពីលោកទទួលអនិច្ចកម្មទៅផ្ទះនេះ ត្រូវបានគ្រប់គ្រងដោយកូនស្រីទី៦ គឺអ្នកស្រី នូ ភុន ព្រមទាំងស្វាមី ឈ្មោះ ប៊ុន ឈួយ លោកទាំងពីរជាឪពុកម្តាយរបស់ម្ចាស់ផ្ទះសព្វថ្ងៃនេះ។ ផ្ទះបុរាណស្ថិតនៅភូមិវត្តគរ សង្កាត់វត្តគរក្រុងបាត់ដំបង ខេត្តបាត់ដំបង ចំងាយ២គម ពីសាលាខេត្ត បាត់ដំបង។ នៅភូមិវត្តគរ មានផ្ទះបុរាណចំនួន២០ផ្ទះ តែមានផ្ទះបុរាណចំនួន២ប៉ុណ្ណោះ ដែលអាចទស្សនា បាន។ បច្ចុប្បន្នផ្ទះនេះមានអ្នកគ្រប់គ្រងថែរក្សាបីជំនាន់មកហើយ។

ផ្ទះនេះមានបណ្តោយ ២៩ម៉ែត្រ និងទទឹង ១០.៥ម៉ែត្រ សង់លើផ្ទៃដី ៥៤៥០ម៉ែត្រការ៉េ សង់តាមលំនាំម៉ូត ប៉ិត មានន័យថាហោណាំង (រានហាល) នៅខាងមុខ។ ផ្ទះនេះមានជណ្តើរពីរៈ ខាងមុខធ្វើ ពីថ្ម រីឯខាងក្រោយធ្វើពីឈើ។ ដំបូលប្រក់ក្បឿងស្រកានាគបុរាណតែខាងក្នុងគ្មានពិដានទេ និងមាន ក្បូរក្បាច់យ៉ាងប្រណិតនៅលើព្រំផ្ទះ។ ឈើផ្នែកនាងខាងលើនៃដំបូលធ្វើពីឈើធ្នឹក ក្តារក្រាលខាងក្នុងផ្ទះធ្វើពីឈើបេង ក្តារក្រាលរានហាល ធ្វើពីឈើកកោះ។ ចំណែកជញ្ជាំងវិញ ធ្វើពីឫស្សី ត្បាញបុកជាមួយបាយអ។ សសរទាំង៣៦សុទ្ធតែធ្វើពីឈើធ្នឹកទាំងអស់ ហើយនៅតែមានសភាពរឹងមាំរហូតដល់ពេលបច្ចុប្បន្ននេះ។

ផ្ទះបុរាណនេះចែកជាបីផ្នែក ៖

ទី១ រានហាលខាងមុខ និងចំហៀង

ទី២ នៅចំកណ្តាលផ្ទះមានបន្ទប់ទទួលភ្ញៀវដ៏ធំមួយ នៅខាងឆ្វេងដៃផ្នែកខាងក្រោយនៃបន្ទប់ទទួលភ្ញៀវមានទ្វារមួយនាំទៅកាន់បន្ទប់គេងពីរ។

ទី៣ ទល់មុខបន្ទប់គេងទាំងពីរមានទ្វារ មានទ្វារមួយទៀតនាំទៅកាន់រានហាលចំហៀងនិងជណ្តើរដែលធ្វើពីឈើ។ ចេញពីទ្វារនោះនៅខាងឆ្វេងដៃប្រហែលជា ៥ម៉ែត្រ មានផ្ទះបាយមួយទៀត។

នៅជំនាន់ខ្មែរក្រហម ផ្ទះនេះត្រូវបានគេយកធ្វើជាកន្លែងសំរាប់បោកស្រូវដាក់សំភារៈហើយនិងធ្វើជាផ្ទះបាយរួម ដែលជាហេតុបណ្តាលឲ្យខូចខាតអស់ពាក់កណ្តាលនៅផ្នែកខាងក្រោយគឺផ្ទះបាយបច្ចុប្បន្ននេះ។ ផ្ទះបុរាណមានការទាក់ទាញចំពោះភ្ញៀវជនជាតិបារាំងមានចំនួនច្រើនជាងគេនិងអាចទស្សនាជីវភាពប្រជាជនដែលរស់នៅតាមដងស្ទឹង ប្រកបរបដាំបន្លែ នេសាទត្រី ។ ដំណើកំសាន្តឆ្ពោះទៅកាន់ផ្ទះបូរាណ គឺជាដំណើទេសចរណ៍បែបប្រវត្តិសាស្ត្រ ដែលធ្វើឲ្យភ្ញៀវមិនអាចបំភ្លេចបានដោយសារតែពេលទៅទស្សនានៅទីនោះ បានឃើញផ្ទះបូរាណចាស់ៗបង្កប់ដោយលក្ខណៈ ស្ថាបយកម្មខ្មែរ ដែលនៅគង់វង្ស ដូចជា ឧបករណ៍ប្រើប្រាស់សំរាប់ការងារកសិកម្ម សិប្បកម្មតម្បាញ ក្បូរក្បាច់រចនាលំនៅដ្ឋានដែលជារចនាបទខ្មែរបុរាណ។




រូបភាពទី១០៖ ផ្ទះបុរាណ ផ្ទះប៉ិត

## ២.៤. គោលបំណង និងគោលដៅនៃការអភិវឌ្ឍក្រុងដើម្បីទាក់ទាញទេសចរ

### ២.៤.១. ចក្ខុវិស័យ

ក្រុងបាត់ដំបង មានសក្តានុពលទេសចរណ៍ដ៏ទាក់ទាញ ដែលធ្វើឲ្យទេសចរចូលមកកម្សាន្តមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ក្រោមការចង្អុលបង្ហាញពីសំណាក់ ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង មន្ទីរទេសចរណ៍បានខិតខំពង្រឹង គុណភាពសេវាតាមបណ្តាមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ ព្រមទាំងជម្រុញនូវការរៀបចំអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ ដើម្បីត្រៀមលក្ខណៈសម្រាប់ទាក់ទាញភ្ញៀវទេសចរក្រោយវិបត្តកូវីដ១៩បញ្ចប់។

ការអភិវឌ្ឍទេសចរណ៍ក្រុងបាត់ដំបងមានចក្ខុវិស័យធ្វើឱ្យ៖ ក្រុងបាត់ដំបង ក្លាយជាគោលដៅទេសចរណ៍ទីក្រុងដ៏មានសក្តានុពលបំផុតសម្រាប់ភូមិភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា អាចប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាកម្សាន្តបានច្រើនបំផុត ជាទីក្រុងដែលមានភាពសម្បូរបែបនៃផលិតផលទេសចរណ៍ ព្រឹត្តិការណ៍ទេសចរណ៍ចម្រុះ និងមានភាពទាក់ទាញបែបវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងធម្មជាតិ ដែលរំលេចចេញនូវអត្តសញ្ញាណរបស់ខេត្តបាត់ដំបងផ្ទាល់ និងជាគោលដៅទេសចរណ៍ដែលផ្តល់ភាពកក់ក្តៅ គុណភាពសេវាកម្ម ភាពស្មោះត្រង់ សន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់ ព្រម

ទាំងផ្តល់បទពិសោធន៍ល្អៗដែលមិនអាចបំភ្លេចបានជូនដល់ភ្ញៀវទេសចរ និងចង់វិលត្រលប់មកម្តងហើយម្តងទៀត។

## ២.៤.២. ទស្សនវិស័យ

ការរៀបចំផែនការអភិវឌ្ឍទេសចរណ៍ទីក្រុង ទាមទារឱ្យមានការគិតគូរឱ្យបានច្បាស់លាស់ជាមុន ចៀសវាងការអនុវត្តដំណើរការទៅមានការរារាំង ឬបញ្ហាផ្សេងៗ។ ការអភិវឌ្ឍនេះទៀតសោត ត្រូវតែសមស្របទៅនឹងលក្ខណៈរបស់តំបន់ និងមានការបែងចែកតំបន់បានច្បាស់លាស់ ត្រូវធានាឱ្យបានថា វិស័យទេសចរណ៍នឹងបែងចែកអត្ថប្រយោជន៍ជាអតិបរមាដល់ប្រជាពលរដ្ឋ។

ទស្សនវិស័យសម្រាប់ការអភិវឌ្ឍ **ក្រុងបាត់ដំបងជាទីក្រុងទេសចរណ៍** មានដូចខាងក្រោម៖

- ជម្រុញអោយមានការស្តារបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធធ្វើដំណើរជាពិសេសការធ្វើដំណើរតាមរយៈផ្លូវដែក
- រៀបចំផលិតផល និងព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗទាក់ទាញទេសចរឱ្យមកកម្សាន្តកាន់តែច្រើន
- លើកកម្ពស់កេរ្តិ៍ឈ្មោះក្រុងបាត់ដំបងឱ្យកាន់តែល្បីល្បាញទៅកាន់ពិភពលោក
- ជម្រុញ សេវាកម្មទេសចរណ៍ប្រកបដោយស្តង់ដាខ្ពស់
- រក្សាបាននូវអនាម័យ បរិស្ថានស្អាត (គោលដៅបៃតង) សណ្តាប់ធ្នាប់ សុវត្ថិភាព និងសោភណ្ឌភាព
- អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព
- មានការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- បង្កើនចំនូលជាអតិបរមាដល់ប្រជាពលរដ្ឋក្នុងក្រុង ជាពិសេសអ្នកមានជំនាញ និងអាជីវករប្រកបអាជីវកម្មផ្ទាល់ ឬប្រយោលជាមួយនឹងវិស័យទេសចរណ៍។

## ២.៤.៣. គោលបំណងនៃការអភិវឌ្ឍទេសចរណ៍វប្បធម៌ក្រុង

ការអភិវឌ្ឍទេសចរណ៍ក្រុងបាត់ដំបងមានសារៈសំខាន់ណាស់សម្រាប់ តម្រង់ទិសក្នុងការគ្រប់គ្រងអភិវឌ្ឍន៍វិស័យទេសចរណ៍ទីក្រុង ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ជាតិ ឆ្នាំ២០១២-២០២០ របស់ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ និងស្របតាមតម្រូវការចាំបាច់ នៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធិភាព គុណភាព និរន្តរភាព និងការទទួលខុសត្រូវ ព្រមទាំងទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា។

ដើម្បីសម្រេចគោលដៅនេះការអភិវឌ្ឍទេសចរណ៍វប្បធម៌ក្រុងបាត់ដំបងមានគោលបំណង និងទិសដៅអភិវឌ្ឍន៍ដូចខាងក្រោម៖

- រៀបចំអភិវឌ្ឍន៍ក្រុងបាត់ដំបងអោយក្លាយជា ទីក្រុងទេសចរណ៍វប្បធម៌ដ៏ទាក់ទាញជាងគេនៅភូមិភាគពាយ័ព្យនៃព្រះរាជណាចក្រកម្ពុជា។
- រៀបចំកែសម្រួលគោលដៅទេសចរណ៍វប្បធម៌ដែលមានស្រាប់ក្នុងក្រុងឱ្យមានលក្ខណៈស្តង់ដា និងសម្បទាបម្រើឱ្យវិស័យទេសចរណ៍កាន់តែប្រសើរជាពិសេសលើទេសចរណ៍បែបវប្បធម៌ប្រវត្តិសាស្ត្រ។
- បង្កើតនូវផលិតផលទេសចរណ៍ និងព្រឹត្តិការណ៍ទាក់ទាញទេសចរណ៍ថ្មីៗ ប្លែកៗឱ្យកាន់តែសម្បូរបែប ដែលរំលេចច្បាស់នូវអត្តសញ្ញាណរបស់ខេត្តបាត់ដំបង។
- ជំរុញការងារប្រឡងប្រណាំងទីក្រុងស្អាតឱ្យកាន់តែមានប្រសិទ្ធភាព។
- ជម្រុញការផ្សព្វផ្សាយព័ត៌មាន និងសក្តានុពលទេសចរណ៍ខេត្ត និងក្រុងបាត់ដំបង ឱ្យបានទូលំទូលាយ ដើម្បីទាក់ទាញទេសចរ និងដៃគូឯកជនអភិវឌ្ឍន៍នានាបន្ថែម។
- ពង្រឹង និងពង្រីកវិសាលភាពនៃមណ្ឌលពត៌មានទេសចរណ៍ និងឯកសារឬព័ត៌មានពាក់ព័ន្ធនឹងវិស័យទេសចរណ៍។
- បង្កើតកិច្ចសហាប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ ដើម្បីលើកកម្ពស់វិស័យទេសចរណ៍ឱ្យកាន់តែប្រសើរឡើង ដូចជា គ្រិះស្ថានអប់រំសម្រាប់ការបណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍ បណ្តាញផ្សព្វផ្សាយនានា យុវជនដែលមានសក្តានុពល ចងក្រងបណ្តាញអាជីវកម្មសេវាកម្មទេសចរណ៍ អង្គការ និងគម្រោងនានា។
- ជម្រុញការពង្រឹងសមត្ថភាពបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ឱ្យមានស្តង់ដារ និងជំនាញច្បាស់លាស់ ដើម្បីធានាដល់ការបម្រើសេវាដល់ទេសចរប្រកបដោយគុណភាព។
- ពង្រឹងយន្តការគ្រប់គ្រងអាជីវកម្ម សេវាកម្មទេសចរណ៍ប្រកបដោយគុណភាព។
- ពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញាត្តិនានា ដើម្បីលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍។
- លើកទឹកចិត្តចំពោះប្រជាពលរដ្ឋ សហគមន៍ និងវិស័យឯកជន ក្នុងការចូលរួម និងការវិនិយោគនានាក្នុងវិស័យទេសចរណ៍បន្ថែម ដើម្បីរួមចំណែកបង្កើនឱកាសការងារ ប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- បន្ថែមការយល់ដឹងពីអត្ថប្រយោជន៍នៃវិស័យទេសចរណ៍ដល់ប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយ ដើម្បីឱ្យពួកគាត់អាចចូលរួមអភិវឌ្ឍន៍ និងទទួលបានផលប្រយោជន៍ពីទេសចរណ៍ទាំងអស់គ្នា។

- លើកទឹកចិត្តឱ្យសាធារណៈជន និងទេសចរឱ្យចូលរួមការពារ និងផ្សព្វផ្សាយពីសិល្បៈ វប្បធម៌ទំនៀមទម្លាប់ ប្រពៃណី ប្រវត្តិសាស្ត្រ សក្តានុពល របស់ក្រុងបាត់ដំបងឱ្យបានផុសផុលឡើង និងប្រកបដោយចីរភាព។
- លើកកម្ពស់ផលិតផលក្នុងស្រុក (ឧទាហរណ៍៖ ផ្លែឈើបាត់ដំបងតាមរដូវកាល) ម្ហូបអ្នកបាត់ដំបងដល់ទេសចរឱ្យបានតែទូលំទូលាយ។
- ជម្រុញការអនុវត្តគោលនយោបាយជាតិពាក់ព័ន្ធនឹងវិស័យទេសចរណ៍ បទដ្ឋានគតិយុត្តិ និងស្តង់ដារនានាដែលដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត។
- បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋឱ្យរស់នៅប្រកបដោយសុខមាលភាព តាមរយៈការជម្រុញកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍វិស័យទេសចរណ៍។
- ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈឱ្យកាន់តែប្រសើរឡើងសាកសមជាទីក្រុងផ្តល់ទំនុកចិត្ត និងភាពកក់ក្តៅដល់ប្រជាពលរដ្ឋ និងទេសចរ។
- លើកម្ពស់បរិស្ថាន ធនធានធម្មជាតិ និងអនាម័យក្នុងទីក្រុងឱ្យកាន់តែប្រសើរឡើង គ្រប់គ្រងភាពស៊ីសង្វាក់គ្នា និងការតុបតែលម្អនៃសំណង់អគារក្នុងតំបន់អភិរក្សដើម្បីបម្រើឱ្យវិស័យទេសចរណ៍។

### ២.៤.៤. ការអភិវឌ្ឍផលិតផលទេសចរណ៍

កំណើនទេសចរកើនរហូតមកដល់បច្ចុប្បន្ន ទាមទារឱ្យមានការអភិវឌ្ឍនូវផលិតផលថ្មីៗដើម្បីបម្រើដល់តម្រូវការរបស់ទេសចរ។ គួសបញ្ជាក់ផងដែរថា ទេសចរដែលមកកម្សាន្តក្នុងខេត្តបាត់ដំបងស្ទើរតែ ៩០ភាគរយវិលត្រលប់ពីគោលដៅនានាមកស្នាក់នៅក្នុងក្រុងបាត់ដំបងវិញ។ កត្តាបង្ហាញថា ទេសចរណ៍ក្នុងក្រុងនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលភ្ញៀវ ជាពិសេសទេសចរពេលរាត្រី។

កត្តាធនធានមនុស្សបម្រើសេវាកម្មទេសចរណ៍ក្នុងខេត្តនៅមានកម្រិតក៏ជាបញ្ហាផងដែរ ដោយសារតែបុគ្គលិកពុំទាន់មានជំនាញច្បាស់លាស់និងគ្រប់គ្រាន់ ហើយបុគ្គលិករបស់បណ្តាសេវាកម្មដែលបានបណ្តុះបណ្តាលហើយមានការផ្លាស់ប្តូរចេញចូលជាញឹកញាប់ ដោយកត្តាប្រាក់ខែ ឬក៏ការផ្លាស់ទីលំនៅ ឬមុខរបរជាដើម។ កត្តាតម្លៃសេវាកម្ម ក៏ជាផ្នែកចូលរួមកំណត់នៃការទាក់ទាញទេសចរផងដែរ។ ជាក់ស្តែង សម្រាប់ខេត្តនិងក្រុងបាត់ដំបង ពុំចោទជាបញ្ហាឡើយចំពោះករណីនេះ។

ជារួមការធ្វើពិពិធកម្មទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ គុណភាព និរន្តរភាពជាកត្តា មិនអាចខ្វះបានដើម្បីធានានិរន្តរភាពនៃកំណើនទេសចរបានឡើយ។

## ក. ការអភិរក្ស និងគ្រប់គ្រងធនធានសក្តានុពលទេសចរណ៍ក្នុងក្រុង

ដោយមើលពីទិសដៅរយៈពេលវែង ការអភិវឌ្ឍវិស័យទេសចរណ៍វប្បធម៌ ធម្មជាតិ ត្រូវបានគិតគូរការងារគ្រប់គ្រង និងអភិរក្សធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។

ផលិតផលទេសចរណ៍ក្នុងក្រុងបាត់ដំបងភាគច្រើន ផ្តើមចេញពីសក្តានុពលទេសចរណ៍បែបវប្បធម៌ សិល្បៈ ប្រវត្តិសាស្ត្រ និងសាសនា មានដូចជា សារមន្ទីរ ផ្ទះបុរាណ សំណង់អភិរក្ស វត្តអារាមជាដើម។ បច្ចុប្បន្ន សង្កេតឃើញថា សំណង់អភិរក្សមួយចំនួនតូចត្រូវបានជួសជុលនិងកែប្រែខុសពីទម្រង់ដើម ដែលនាំឱ្យបានបង់អត្តសញ្ញាណរបស់តំបន់ក៏ដូចជាភាពទាក់ទាញនៃស្ថាបត្យកម្ម។ រីឯទីវត្តអារាមមិនត្រូវបានរៀបចំជាលក្ខណៈបម្រើឱ្យវិស័យទេសចរណ៍នៅឡើយ ដូចជាព្រះវិហារវត្តបិទពេលមិនមានពិធីបុណ្យ ខ្វះបដិសណ្ឋារកិច្ច និងសម្ភារទ្រទ្រង់ផ្សេងៗ។ ស្នាដៃសិល្បៈដែលជាចំណុចសំខាន់របស់ក្រុង មិនត្រូវបានលើកយកមកបង្ហាញឱ្យបានទូលំទូលាយដល់សាធារណៈជន និងទេសចរ។ ចំណុចទាំងនេះហើយធ្វើឱ្យទេសចរ ហាក់មិនសូវចាប់អារម្មណ៍ទេសចរណ៍ក្រុងបាត់ដំបងប៉ុន្មានឡើយ លើកលែងពេលរាត្រីដែលពីគេត្រលប់មកពីតាមគោលដៅនានាដើម្បីស្នាក់នៅវិញ។

កត្តាទាំងនេះ ត្រូវឱ្យមានការយកចិត្តទុកដាក់ និងចូលរួមពីសំណាក់ស្ថាប័នទទួលបន្ទុក អាជ្ញាធរ អង្គភាពពាក់ព័ន្ធ ប្រជាពលរដ្ឋ និងឧស្សាហកម្មទេសចរណ៍ទាំងអស់រួមគ្នាក្នុងការលើកកម្ពស់ អភិរក្ស និងផ្តល់វិភាគទានគាំទ្រទៅតាមលទ្ធភាព។

## ខ. ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

តាមលទ្ធផលនៃការស្រាវជ្រាវ ទេសចរអន្តរជាតិមកលេងកម្ពុជា ក៏ដូចខេត្តបាត់ដំបងភាគច្រើន ៨០% ទស្សនាមួយដង ហើយអ្នកទស្សនាលើសពីមួយដងមាន២០%។ នេះជាបញ្ហាប្រឈមមួយព្រោះថា បើយើងរក្សាបានចំណែកអ្នកមកទស្សនាច្រើនដង នោះកំណើនទេសចរនឹងកើនយ៉ាងរហ័ស ដោយមានការបញ្ចូលគ្នារវៀងភ្ញៀវថ្មី និងភ្ញៀវចាស់។ ករណីនេះក៏បណ្តាលមកពីការផ្សព្វផ្សាយ និងសកម្មភាពទីផ្សារនៅមានកំរិត ដែលមិនអាចឲ្យភ្ញៀវដឹងពីសក្តានុពលទេសចរណ៍ហើយមកទស្សនាបានច្រើនដង។

ទោះបីជាការសិក្សាទីផ្សារ និងការផ្សព្វផ្សាយទេសចរណ៍របស់ខេត្តបាត់ដំបងនៅមានកម្រិត ប៉ុន្តែយន្តការ និងសកម្មភាពជាច្រើន ដែលរួមគ្នាដោយរដ្ឋ និងឯកជន បានជម្រុញលើកកំពស់កិត្យានុភាពខេត្ត ក៏ដូចជាខេត្តនានាទូទាំងប្រទេសកម្ពុជាផងដែរ។ ក្នុងនោះយុទ្ធនាការផ្សព្វផ្សាយ "កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ" និងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ" ដែលត្រូវបានការចូលរួមគាំទ្រជ្រួតជ្រាបជាសកល។

តាមការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍របស់ខេត្តបាត់ដំបង មានការពាក់ព័ន្ធទៅនឹងកត្តាខាងក្នុង និងខាងក្រៅដោយជាប់ទាក់ទងកត្តា ៤ យ៉ាងគឺៈ

១.ផលិតផលទេសចរណ៍

២.ថ្លៃលក់ផលិតផល

៣.ទីផ្សារ

៤.ការផ្សព្វផ្សាយ។

កត្តាទាំងនេះ ជាមូលដ្ឋានជម្រុញការអភិវឌ្ឍទេសចរណ៍ ពិសេសការឈានទៅសម្រេចចក្ខុវិស័យនៃការប្រែក្លាយខេត្តបាត់ដំបង ជាគោលដៅទេសចរណ៍គំរូ និងសម្រេចបានគោលដៅនៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

ការចូលរួមរបស់វិស័យឯកជន ក្នុងការផ្សព្វផ្សាយផលិតផលទេសចរណ៍នៅពុំទាន់ស៊ីសង្វាក់គ្នា ដោយការផ្សព្វផ្សាយដាច់ដោយឡែកពីគ្នា និងសម្ភារៈផ្សព្វផ្សាយទេសចរណ៍ទាំងនោះ គុណភាព និងបរិមាណនៅមានកម្រិត និងការផ្សព្វផ្សាយពុំទាន់បានចំគោលដៅប្រព័ន្ធបច្ចេកទេស ដែលជាបញ្ហាតម្រូវឲ្យអ្នកអនុវត្តត្រូវរិះរកយុទ្ធសាស្ត្រដោះស្រាយជាជំហានៗ។

## គ.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍

ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ទេសចរ តាមជម្រើសមួយដ៏ប្រសើរក្នុងការទាក់ទាញទេសចរជាតិ និងទេសចរអន្តរជាតិ និងផ្តល់ឱកាសនូវជម្រើសជាច្រើនតាមមធ្យោបាយធ្វើដំណើរ និងការផ្តល់នូវផាសុកភាព គឺការកសាងនូវហេដ្ឋារចនាសម្ព័ន្ធរបស់ខេត្តឱ្យបានល្អប្រសើរ។ នាពេលបច្ចុប្បន្ននេះហេដ្ឋារចនាសម្ព័ន្ធ របស់ខេត្តបាត់ដំបងមានស្ថានភាពល្អប្រសើរ និងស្ថានភាពនៃហេដ្ឋារចនាសម្ព័ន្ធទៅកាន់តំបន់រមណីយដ្ឋានក៏បានល្អជាងមុន។ ការធ្វើដំណើរតាមរយៈផ្លូវដែកជាចំណុចពិសេសដ៏ទាក់ទាញមួយយ៉ាងសំខាន់ដែលជួយជម្រុញក្នុងការទាក់ទាញភ្ញៀវអោយធ្វើដំណើរទៅកាន់ក្រុងបាត់ដំបង។ ផ្លូវដែកសម្រាប់ការធ្វើដំណើរនេះមានចាប់ពីក្រុងភ្នំពេញទៅកាន់ក្រុងបាត់ដំបងដែលអាចអោយទេសចរជាតិ និងអន្តរជាតិធ្វើដំណើរបានប្រកបដោយផាសុកភាព។ ការធ្វើដំណើរជាថ្មីម្តងទៀតដែលជាការបើកដំណើរការធ្វើដំណើរបែបជើងហោះហើរក៏អាចជាកត្តាមួយដែលអាចឆក់យកការចាប់អារម្មណ៍ពីទេសចរដូចគ្នា។ មិនថារដ្ឋាភិបាល រដ្ឋាលខេត្ត មន្ទីរដែលពាក់ព័ន្ធទេបាននឹងកំពុងរៀបចំអោយមានការប្រើប្រាស់នៅការធ្វើដំណើរតាមជើងហោះហើរទៅកាន់ក្រុងបាត់ដំបង។ រីឯមធ្យោបាយសម្រាប់ធ្វើ

ដំណើរទៅកាន់តំបន់គោលដៅនានាក៏មានការអភិវឌ្ឍបន្ថែមដូចគ្នាដើម្បីសម្រួលដល់ទេសចរសម្រាប់ធ្វើដំណើរក្នុងក្រុងទៅកាន់គោលដៅនីមួយៗ។

**ឃ. សន្តិសុខ សុវត្ថិភាពភ្ញៀវទេសចរ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន**

សណ្តាប់ធ្នាប់សង្គម សន្តិសុខសាធារណៈ និងសុវត្ថិភាព មានសភាពការណ៍ល្អប្រសើរក្រោមការដឹកនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ ឯកឧត្តម ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងបានដាក់ផែនការជាប្រចាំ ដោយបញ្ជាឲ្យកងកម្លាំងនគរបាលខេត្ត និងក្រុង ឈរជើងប្រចាំតាមតំបន់គោលដៅសំខាន់ៗ សំដៅទប់ស្កាត់ និងបង្ការការបង្កបញ្ហាគ្រោះថ្នាក់ផ្សេងៗ ពីសំណាក់ក្មេងទំនើងដល់ការដើរកម្សាន្តរបស់ទេសចរជាតិ និងអន្តរជាតិ។

សន្តិសុខ និងសុវត្ថិភាព ជាបញ្ហាចម្បងដែលត្រូវតែរៀបចំ និងពង្រឹងបន្ថែមជាប្រចាំ។ បញ្ហាប្រឈមមួយចំនួនពីសុវត្ថិភាពរបស់ភ្ញៀវដែលភាពអសកម្មទាំងនេះទាមទារឱ្យមានការខិតខំប្រឹងប្រែងពីគ្រប់ភាគីពាក់ព័ន្ធ បញ្ហាជារួមមាន៖

- អនាម័យចំណីម្ហូបអាហារមិនទាន់បានល្អជាទូទៅ ពិសេសនៅតាមតំបន់កម្សាន្ត អាហារចម្អិនស្រាប់តាមតូបលក់អាហារតាមបណ្តោយផ្លូវជាតិ។
- អំពើចោរកម្មដែលមាននៅតាមទីក្រុង និងបណ្តាស្រុក និងបញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដែលតែងកើតមាន ជាកង្វល់មួយរបស់អ្នកទេសចរផងដែរ។

បញ្ហាទាំងអស់ខាងលើនេះ ខេត្តបាត់ដំបងបានចូលរួមយ៉ាងសកម្មទៅលើការងារអនុវត្តភូមិ ឃុំមានសុវត្ថិភាពយ៉ាងម៉ឺងម៉ាត់។ ចំពោះបញ្ហាសុវត្ថិភាពនៅតាមរមណីយដ្ឋានទេសចរណ៍ មន្ទីរបានខិតខំណែនាំដល់អ្នកគ្រប់គ្រងនៅតាមរមណីយដ្ឋាន និងបានសហការជាមួយស្ថាប័នមានសមត្ថកិច្ចនានា ដើម្បីធ្វើការគ្រប់គ្រងលើការងារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងចរាចរណ៍បានយ៉ាងល្អប្រសើរ។

**ង. ការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍**

ការអភិវឌ្ឍធនធានមនុស្សក្នុងមុខជំនាញទេសចរណ៍នៅមានកំរិត តម្រូវការធនធានមនុស្សដែលមានវិជ្ជាជីវៈពិតប្រាកដ និងមានបទពិសោធន៍ ដើម្បីបម្រើឱ្យវិស័យទេសចរណ៍ក្នុងការជម្រុញការអភិវឌ្ឍទេសចរណ៍របស់ខេត្តប្រកបដោយភាពរីកចម្រើន និងឆ្លើយតបតាមតម្រូវការទីផ្សារបច្ចុប្បន្ននេះ កំពុងជាឧបសគ្គ និងចោទជាបញ្ហាខ្លាំង។ ការជួយគាំទ្រដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងរយៈពេលខ្លី និងរយៈពេលវែង ពីបណ្តាដៃគូ

អភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន និងការជម្រុញឲ្យមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ប្រចាំតំបន់ គឺត្រូវបានលើកទឹកចិត្ត។

បញ្ហាប្រឈមមួយចំនួន ដែលតែងតែជួបប្រទះនៅក្នុងការអនុវត្តផែនការសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្សរួមមាន៖

- សមត្ថភាពមន្ត្រីជំនាញនៅមានកម្រិតទាំងបរិមាណ និងបទពិសោធន៍ក្នុងការអនុវត្តការងារ។
- ធនធានមនុស្សក្នុងបណ្តាសេវាកម្មឯកជន និងសហគមន៍ នៅមានភាពទន់ខ្សោយក្នុងការ ចាប់យកការយល់ដឹងឱ្យស៊ីជម្រៅពីវិស័យទេសចរណ៍។
- បណ្តាមូលដ្ឋានសេវាកម្មឯកជនជារួម នៅមិនទាន់បានស៊ីជម្រៅពីសមភាពយេនឌ័រក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ពិសេសស្ត្រីបម្រើឱ្យទីតាំងអាជីវកម្មកម្សាន្ត រីឯមូលដ្ឋានអាជីវកម្មខ្លះទៀត នៅមិនទាន់មានតំណាងស្ត្រីសម្រាប់អង្គភាពរបស់ខ្លួននៅឡើយទេ។
- ធនធានមនុស្សដែលកំពុងបម្រើការងារក្នុងវិស័យទេសចរណ៍ នៅមានកំរិតជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ ក្នុងការអនុវត្តការងារ ដើម្បីឆ្លើយតបទៅនឹងគុណភាព និងតម្រូវការទីផ្សារ។

## ២.៥. យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទេសចរណ៍អាទិភាព

ក្រុងបាត់ដំបងត្រូវបានចាត់ទុកជាទីក្រុងស្រស់បំព្រងមួយរបស់កម្ពុជា។ ក្រុងបាត់ដំបង ជាបេះដូងរបស់ខេត្តបាត់ដំបង និងជាទីក្រុងដែលពោរពេញដោយសម្បត្តិវប្បធម៌ សំណង់បុរាណ និងប្រវត្តិសាស្ត្រដ៏គួរឱ្យទាក់ទាញ។ កន្លងមក ក្រុងបាត់ដំបងត្រូវបានទទួលថាជាទីក្រុងស្អាត និងទទួលបានពានរង្វាន់ទីក្រុងស្អាតកម្ពុជា ទីក្រុងទេសចរណ៍ស្អាតអាស៊ាន ទីក្រុងប្រកបដោយនិរន្តភាពអាស៊ានជាដើម។ កត្តាទាំងនេះហើយ ទើបធ្វើឱ្យក្រុងបាត់ដំបង មានភាពទាក់ទាញយ៉ាងខ្លាំង ប៉ុន្តែការរៀបចំសម្រាប់វិស័យទេសចរណ៍នៅមានកម្រិតនៅឡើយ។ ហេតុនេះទាមទារឱ្យមានការកំណត់ឱ្យបានច្បាស់លាស់នូវតំបន់ សកម្មភាព និងសម្បទារទ្រទ្រង់ ដើម្បីធានាថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលទេសចរមកកម្សាន្ត។ ខាងក្រោមនេះ ជាគំនិតមួយចំនួនបន្ថែមក្នុងការរៀបចំប្រព័ន្ធទេសចរណ៍ក្នុងក្រុងបាត់ដំបង ឱ្យកាន់តែមានប្រសិទ្ធិភាព។

### ២.៥.១. ការរៀបចំវិថីវប្បធម៌ភូមិវត្តគរ

ដើម្បីអាចដើរតាមចក្ខុវិស័យនៃការអភិវឌ្ឍប្រកបគុណភាពលំដាប់ខ្ពស់ សម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ភូមិវត្តគរខេត្តបាត់ដំបង បានកំណត់វិសាលភាពរួម គឺរួមបញ្ចូលទាំងទេសចរណ៍វប្បធម៌ទេសចរណ៍ទីក្រុង កសិ-ទេសចរណ៍ និងប្រភេទទេសចរណ៍ទាក់ទាញដទៃទៀត ខណៈដែលបច្ចុប្បន្នការទស្សនាក្រុងបុរាណ និងតំបន់ធម្មជាតិ គឺជាមូលហេតុចម្បងរបស់ទេសចរដែលមកកាន់ខេត្តបាត់ដំបង។ គម្រោងនេះ ត្រូវ

ធ្វើការសិក្សា និងកំណត់ឱ្យបាននៅយុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីបង្កើនភាពទាក់ទាញ នៃក្រុងបាត់ដំបងទាំងមូលដែលមានលើសពីការទស្សនាក្រុងបុរាណ និងតំបន់ធម្មជាតិ ដោយត្រូវផ្សារភ្ជាប់ជាមួយសកម្មភាពកម្សាន្តដ៏សម្បូរបែបដ៏ទៃទៀត។

ក្រុងបាត់ដំបងត្រូវពង្រឹងលក្ខណៈសម្បត្តិរបស់ខ្លួន សម្រាប់ចាប់យកកាលានុវត្តភាពដែលមានលើទីផ្សារទេសចរណ៍អន្តរជាតិ និងត្រៀមខ្លួនឱ្យបានរួចរាល់ចំពោះបញ្ហាប្រឈមថ្មីៗដូចជាភាពគានតឹងនៃស្ថានភាពនយោបាយ និងសេដ្ឋកិច្ចពិភពលោក ពិសេសឆ្លើយតបនឹងវិបត្តិជំងឺកូវីដ-១៩។ ដូច្នេះ មន្ទីរទេសចរណ៍ខេត្តបាត់ដំបងរំពឹងថាៈការរៀបចំការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរនេះ នឹងក្លាយជាយន្តការដ៏មានសារៈសំខាន់ចាំបាច់ សម្រាប់ការឆ្លើយតបទៅនឹងស្ថានភាពនាពេលបច្ចុប្បន្នក៏ដូចជាអនាគត ដែលអាចគាំទ្រចក្ខុវិស័យទេសចរណ៍ខេត្តបាត់ដំបងឆ្នាំ២០២៥។ ក្នុងបរិការណ៍នេះ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង បានឯកភាពកំណត់យកថេរវេលានៃការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ ក្នុងរយៈពេល៥ឆ្នាំ (២០២១-២០២៥) និងបានស្នើឡើងជា **ចក្ខុវិស័យ គោលបំណង** និង**គោលដៅ** សម្រាប់ការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ។

### ក. ចក្ខុវិស័យ

ការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ កំណត់ចក្ខុវិស័យទេសចរណ៍រយៈពេលវែង (២០២១-២០២៥) ពិតជាមានសារៈសំខាន់ដោយហេតុថាថ្មីៗនេះការមកដល់នៃភ្ញៀវទេសចរអន្តរជាតិមកកាន់ខេត្តបាត់ដំបងមានល្បឿនកំណើនយឺត ហើយថែមទាំងមានការធ្លាក់ចុះបន្តិចផងនៅឆ្នាំ២០១៩ ខណៈដែលវិស័យទេសចរណ៍នៅតែបន្តកើនឡើងនៅលើផ្ទៃប្រទេសទាំងមូល។ ទន្ទឹមនឹងនោះ នៅឆ្នាំ២០២០ វិស័យទេសចរណ៍កម្ពុជា និងបាត់ដំបងបានកំពុងទទួលរងឥទ្ធិពលយ៉ាងដំណំពីវិបត្តិជំងឺឆ្លងកូវីដ១៩ (COVID-19)។

ដើម្បីសម្រេចបាននៅចក្ខុវិស័យទាំងនេះចាំបាច់ណាស់ ត្រូវតែកៀរគរធនធាននៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងបណ្តាភាគីពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ វិនិយោគទុនទេសចរណ៍ចាំបាច់នានា ដើម្បីរៀបចំនគរូបនីយកម្មទេសចរណ៍ ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗអមជាមួយនឹងការបង្កលក្ខខណ្ឌគាំទ្រនានា ការពង្រឹងធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងសមត្ថភាពផ្សព្វផ្សាយទេសចរណ៍ពង្រឹងការតភ្ជាប់នានាមកក្រុងបាត់ដំបង ឱ្យកាន់តែប្រសើរ។ល។

ការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ ក្រុងបាត់ដំបង (២០២១-២០២៥) ដាក់ចេញចក្ខុវិស័យ ដូចខាងក្រោមៈ

- ❖ ភូមិវត្តគរ ត្រូវកំណត់គោលដៅទេសចរណ៍អន្តរជាតិដ៏គួរឱ្យចាប់អារម្មណ៍ និងមានការទទួលស្គាល់ជាលក្ខណៈជាសាកលលើការអភិរក្ស ប្រពៃណីទំនៀមទំលាប់ និងកិច្ចគាំពារនៅសម្បត្តិបេតិកភណ្ឌវប្បធម៌ និងបរិស្ថាន ដោយផ្តល់នៅធនធានទេសចរណ៍ និងភាពទាក់ទាញជាច្រើនទៀត។
- ❖ ធានាឱ្យបានផលប្រយោជន៍សេដ្ឋកិច្ច-សង្គម ជាអតិបរមាពីវិស័យទេសចរណ៍ពោលគឺតំបន់ប្រវត្តិសាស្ត្រភូមិវត្តគរ ក្រុងបាត់ដំបង ដែលមានស្ទឹងសង្កែ និងតំបន់កសិទេសចរណ៍ ដែលមានគោលដៅទេសចរណ៍ត្រូវតែភ្ជាប់ជាមួយការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ។
- ❖ ភូមិវត្តគរ ក្រុងបាត់ដំបង ត្រូវតែជាគោលដៅទេសចរណ៍មានគុណភាពទាក់ទាញទេសចរមកកម្សាន្តបានម្តងហើយម្តងទៀត (Repeated Tourist) និងស្វាគមន៍ទេសចរកម្រិតខ្ពស់អាចបង្កើននូវចំណូលជូនប្រជាពលរដ្ឋមូលដ្ឋាន និងកសាងសេដ្ឋកិច្ចមូលដ្ឋាន។

## ខ. គោលបំណង

គោលបំណងជាយុទ្ធសាស្ត្រនៃ**ការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ** (២០២១-២០២៥) គឺត្រូវធ្វើយ៉ាងណាឱ្យក្រុងបាត់ដំបងក្លាយជាគោលដៅទេសចរណ៍ដ៏ចំបង និងទាក់ទាញនៅក្នុងតំបន់ និងសកលលោកដោយឈរលើមូលដ្ឋាននៃសម្បត្តិបេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ សាសនា និងភាពជាខ្មែរ ។ ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន ភូមិវត្តគរ ក្រុងបាត់ដំបង គួររៀនសូត្រពីគំរូអនុវត្តន៍ល្អៗពីគ្រប់សម័យកាល និងការអភិវឌ្ឍន៍ភូមិទេសចរណ៍បែបវប្បធម៌ពីមុនៗនៅក្នុងប្រទេសកម្ពុជានិងបណ្តាប្រទេសនានា ព្រមជាមួយការគិតគូរលើ **"ភាពស្អាត បៃតង និងវៃឆ្លាត"** ក្នុងបរិបទសម័យទំនើប និងដំណើរឆ្ពោះទៅការកសាងសេដ្ឋកិច្ចឌីជីថល។

**គោលបំណង ដែលនឹងដាក់ចេញក្នុងការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ (២០២១-២០២៥) រួមមាន៖**

- ✓ គោលដៅទេសចរណ៍ប្រកបដោយគុណភាពខ្ពស់
- ✓ ជាភូមិទេសចរណ៍វប្បធម៌វៃឆ្លាត
- ✓ ជាភូមិដែលគិតគូរខ្ពស់ដល់ការអភិវឌ្ឍ និងអភិរក្សធនធានវប្បធម៌ និងបរិស្ថាន
- ✓ ជាភូមិកសិទេសចរណ៍
- ✓ ជាភូមិឃុំ/សង្កាត់ទេសចរណ៍សុវត្ថិភាព
- ✓ ជាភូមិទេសចរណ៍ស្អាត
- ✓ ជាភូមិទេសចរណ៍ប្រកបដោយភាពបៃតង
- ✓ ជាភូមិមួយផលិតផលមួយសេវាចម្រុះ។

### គ. គោលដៅ

ដើម្បីសម្រេចបាននៅគោលបំណងខាងលើ **ការអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ** (២០២១-២០២៥) ដាក់ចេញគោលដៅយុទ្ធសាស្ត្រមួយចំនួន៖

- ✓ គោលដៅយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ទេសចរណ៍បែបវប្បធម៌ សាសនា ប្រវត្តិសាស្ត្រ
- ✓ គោលដៅយុទ្ធសាស្ត្រវិនិយោគទេសចរណ៍ និងការអភិវឌ្ឍសម្បទារទេសចរណ៍ថ្មីៗ
- ✓ គោលដៅយុទ្ធសាស្ត្រសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍នៅភូមិវត្តគរ
- ✓ គោលដៅយុទ្ធសាស្ត្រពង្រឹងគុណភាពទេសចរណ៍ និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍នៅភូមិវត្តគរ
- ✓ គោលដៅយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់គាំទ្រវិស័យទេសចរណ៍នៅភូមិវត្តគរ
- ✓ គោលដៅយុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថាននៅភូមិវត្តគរ
- ✓ គោលដៅយុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ច សម្រាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍នៅភូមិវត្តគរ។

### ឃ. ការជម្រុញអភិវឌ្ឍតំបន់ទេសចរណ៍បែបវប្បធម៌ សាសនា ប្រវត្តិសាស្ត្រ និងម្ហូបអាហារ

- ◆ ជម្រុញការផ្សារភ្ជាប់ដំណើរទេសចរណ៍វប្បធម៌ និងម្ហូបអាហារ (Tourism Gastronomy) ៖ ក្រុងបាត់ដំបងអាចផ្សារភ្ជាប់ជាមួយនឹងដំណើរទេសចរណ៍ដែលមាននៅក្នុងកសិដ្ឋាន ភោជនីយដ្ឋាន និងមជ្ឈមណ្ឌលបង្ហាត់បង្ហាញម្ហូបអាហារដោយប្រើមគ្គុទ្ទេសក៍ ឬសាស្ត្រាចារ្យ ឬចុងភៅដើម្បីពន្យល់ និងណែនាំភ្ញៀវទេសចរ។
- ◆ ដំណើរទេសចរណ៍នេះ ក៏អាចភ្ជាប់ជាមួយកន្លែងស្រាវជ្រាវ និងសារៈមន្ទីរផ្សេងៗគ្នាជាច្រើន ដើម្បីពន្យល់អំពីតួនាទីរបស់ទីក្រុង សំណង់សិល្បៈការពិព័រណ៍នានា និងអាចឱ្យភ្ញៀវស្វែងយល់ពីវប្បធម៌អរិយធម៌ខ្មែរ និងប្រវត្តិសាស្ត្រ ធម្មជាតិនិងសាសនា។ យើងក៏អាចអភិវឌ្ឍខ្សែដំណើរទេសចរណ៍តាមប្រធានបទ ផ្សេងៗ ពោលគឺសៀគ្វីទេសចរណ៍នេះអាចភ្ជាប់ទីក្រុង ភូមិវត្តគរ ប្រាសាទភ្នំបាណន់ និង/ឬវត្តអារាមនានានៅក្នុងក្រុងបាត់ដំបង។ ប្រពៃណី និងទំនៀមទម្លាប់អ្នកស្រុកក៏អាចត្រូវបានរួមបញ្ចូលផងដែរនៅក្នុងសៀគ្វីទេសចរណ៍នេះ ដោយអមជាមួយការបកស្រាយពន្យល់ និងនិទានរឿងនៅកន្លែង

ដែលបានទៅទស្សនាដល់ភ្ញៀវទេសចរ (Story Telling)។ ដូច្នេះ ត្រូវបណ្តុះបណ្តាលឱ្យមានអ្នករៀបរាប់ (Story-Tellers) នៅតាមគោលដៅ ឬរមណីយដ្ឋានទេសចរណ៍សំខាន់ៗ។

- រៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលក្នុងការវាយតម្លៃ និងអប់រំបណ្តុះបណ្តាលបន្ត
- ត្រូវផ្សារភ្ជាប់ដំណើរទេសចរណ៍វប្បធម៌នេះ ជាមួយនឹងទេសចរយុវជន៖ ជម្រុញការចូលរួមពីទេសចរក្នុងស្រុក (ពិសេសទេសចរ៖ យុវជន និងកុមារ) ដោយផ្សារភ្ជាប់នឹងទេសចរណ៍វប្បធម៌និងប្រពៃណីទំនៀមទំលាប់ដោយប្រើប្រាស់នូវគោលទស្សនៈភាពជាខ្មែរតែមួយ-Cambodianess សម្រាប់អនាគតកម្ពុជា (Cambodia's Future) ដែលបានគូសបញ្ជាក់ឱ្យឃើញពីសារៈសំខាន់នៃការរក្សាអត្តសញ្ញាណជាតិ ក្នុងន័យនេះគឺយើងជម្រុញឱ្យទេសចរក្នុងស្រុកឱ្យធ្វើដំណើរកម្សាន្តទៅកាន់តំបន់គោលដៅទេសចរណ៍វប្បធម៌ឱ្យបានច្រើនជាមួយការទទួលបានការបញ្ជ្រាបការយល់ដឹងអំពីវប្បធម៌ ទំនៀមទម្លាប់ ប្រវត្តិដំណើររឿងរបស់គោលដៅនីមួយៗ (Storytelling) ដោយ អាចប្រើប្រាស់មគ្គុទ្ទេសក៍ទេសចរក្នុងស្រុក ឬដោយការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋមូលដ្ឋានជាម្ចាស់ស្រុកភូមិ ឬ ការប្រើប្រាស់បច្ចេកវិទ្យា (ឧទាហរណ៍៖ VR, QR Code,...) ជាជំនួយនៅតាមគោលដៅ។
- ជម្រុញ ការបង្កើតសារមន្ទីទេសចរណ៍វប្បធម៌ភូមិវត្តគរ
- ជម្រុញ ផលិតកម្មភាពយន្ត ដែលគិតដល់លក្ខណៈពិសេសនៃតំបន់ទេសចរណ៍ភូមិវត្តគរ ក្រុងបាត់ដំបង ដោយសារមានប្រវត្តិនិងការផ្សព្វផ្សាយកន្លងមកអាចក្លាយជាមធ្យោបាយមួយក្នុងការបង្កើនកិត្តិនាមនិងប្រជាប្រិយ ភាពនៃទិសដៅទេសចរណ៍ និងបង្កើនការចូលមកទស្សនា។
- ជម្រុញ សិប្បកម្មសិល្បៈច្នៃប្រឌិត (វត្ថុអនុស្សាវរីយ៍) ប្រចាំភូមិវត្តគរ
- បង្កើតក្រុមសិល្បៈរស់ ភូមិវត្តគរ
- ជម្រុញធ្វើឱ្យភូមិវត្តគរ ជាកន្លែងច្នៃប្រឌិតខាងផ្នែកម្ហូបអាហារ (Gastronomy Tourism)៖ ចំពោះចំណុចនេះ សកម្មភាពមួយចំនួនត្រូវអនុវត្ត ដើម្បីឱ្យម្ហូបអាហារដើរតួយ៉ាងសំខាន់ ជាអាទិ៍ត្រូវរៀបចំឱ្យមានពិធីបុណ្យប្រចាំឆ្នាំដែលមិនត្រឹមតែផ្តោតសំខាន់ទៅលើម្ហូបអាហារ ដែលជាផលិតផលក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើការច្នៃប្រឌិតធ្វើម្ហូប ទាំងបច្ចេកទេស ទាំងការស្រាវជ្រាវផ្នែកអាហារវិទ្យា។
- ការបង្កើត និងពង្រឹងឧបករណ៍ និងមធ្យាបាយបកស្រាយពន្យល់បេតិកភណ្ឌ និងវប្បធម៌ដល់ភ្ញៀវ
- អ្នកនិពន្ធ និងវិចិត្រករក្នុងស្រុក អាចត្រូវបានប្រើដើម្បីអភិវឌ្ឍការនិទានកថាឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាពជាងមុនដល់ទេសចរឱ្យយល់ដឹងពីភូមិបុរាណ។ ទន្ទឹមនឹងនោះ លើកទឹកចិត្តឱ្យមានការផ្តល់

សេវាកម្មសម្រាប់វិចិត្រករក្នុងស្រុកគួរគាំទ្រសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិផ្សារភ្ជាប់នឹងទីតាំងផ្ទះបុរាណ នៃភូមិវត្តគរ

- មគ្គុទ្ទេសក៏ទេសចរណ៍ ក៏គួរត្រូវពង្រឹងសមត្ថភាព និងបច្ចុប្បន្នភាពចំណេះដឹងជាប្រចាំ និងគួរត្រូវបង្កើតឱ្យ មាននូវមគ្គុទ្ទេសក៍ទេសចរណ៍ពិសេសក្នុងភូមិវត្តគរដែលជាមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងស្រុក
- ត្រូវប្រើប្រាស់កម្មវិធី (App) ឬកម្មវិធី )QR Code) បកស្រាយពន្យល់ ឬកម្មវិធីបច្ចេកវិទ្យា (AR) ឬ (VR) ដើម្បីពន្យល់ និងបកស្រាយអត្ថន័យនៃធនធានសម្បត្តិវប្បធម៌បេតិកភណ្ឌទាំងរូបី និងអរូបីដល់ទេសចរជាតិ និងអន្តរជាតិ (អាចមានជាភាសាខ្មែរ និងភាសាបរទេស...)បំពាក់ឱ្យមាននៅតាមភូមិវត្តគរ។

## ខ. គោលដៅយុទ្ធសាស្ត្រវិនិយោគទេសចរណ៍ និងការអភិវឌ្ឍសម្បទារទេសចរណ៍ថ្មីៗ

- ធានាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព និងការទទួលខុសត្រូវខ្ពស់ក្នុងភូមិវត្តគរ៖ ភូមិវត្តគរត្រូវផ្តល់ឱ្យគម្រោងវិនិយោគ និងអភិវឌ្ឍន៍នៅភូមិវត្តគរ ដែលមានលក្ខណៈសម្បត្តិជាតំបន់ទេសចរណ៍វប្បធម៌ លើកទឹកចិត្តផ្នែកវិនិយោគឯកជនដោយអ្នកអភិវឌ្ឍន៍ភូមិទេសចរណ៍វប្បធម៌អាចទទួលបានការគាំទ្រ ដោយប្រើប្រាស់យន្តការភាពជាដៃគូរដ្ឋ-ឯកជន
- ការវិនិយោគលើកីឡាទេសចរណ៍៖ ការវិនិយោគលើវិស័យទេសចរណ៍កីឡានៅក្នុងភូមិវត្តគរ គឺក្នុងគោលបំណងធ្វើឱ្យភូមិវត្តគរក្លាយជាគោលដៅដែលមានការទាក់ទាញ ដូចជាកីឡាជិះកង់ និងប្រភេទកីឡាផ្សេងទៀតដែលអាចរៀបចំបាន
- ការវិនិយោគលើឧទ្យានកម្សាន្តបែបកម្រិតខ្ពស់៖ ភូមិវត្តគរអាចធ្វើឱ្យក្រុងបាត់ដំបង ប្រែក្លាយជាគោលដៅទេសចរណ៍លក្ខណៈគ្រួសារ ដោយបង្កើននូវការទាក់ទាញកុមារ និងយុវជន។ ដើម្បីសម្រេចគោលដៅនេះ គម្រោងស្នើឱ្យគិតគូរលើការវិនិយោគ សួនកម្សាន្តដែលរំលេចនូវចនាបទ ទាក់ទងនឹងរឿងរ៉ាវប្រវត្តិសាស្ត្រ និងវប្បធម៌របស់បាត់ដំបង
- ការវិនិយោគទេសចរណ៍វប្បធម៌៖ ភូមិវត្តគរ អាចជាទីតាំងនៃសារៈមន្ទីរជាតិខ្នាតតូចមួយដែលមានស្ថាបត្យកម្មគួរឱ្យស្ញប់ស្ញែង។ សារៈមន្ទីរបែបនេះនឹងអាចជាផលិតផលសម្រាប់ក្រុងបាត់ដំបង និងប្រទេសកម្ពុជាតែម្តង។
- ការវិនិយោគលើវិស័យសុខភាព(ទេសចរណ៍សុខភាព)៖ភូមិវត្តគរអាចក្លាយជាគោលដៅសម្រាប់វិស័យទេសចរណ៍សុខភាព ។ ចំណុចនេះមានន័យថាភូមិវត្តគរផ្តល់ឱ្យមានការវិនិយោគលើវិស័យសុខភាព និងសុខុមាលភាព ដោយផ្អែកលើការវិនិយោគពីបរទេស និងវិនិយោគក្នុងស្រុក ដើម្បីបម្រើឱ្យសេចក្តីត្រូវការរបស់ទេសចរ។

- បង្កើនការអភិវឌ្ឍ និងវិនិយោគរមណីយដ្ឋានទេសចរណ៍កម្សាន្តក្នុងតំបន់៖ គាំទ្រការអភិវឌ្ឍសម្បទាទេសចរណ៍ទ្រទ្រង់ ពិសេសត្រូវកែលម្អ ឬកែច្នៃរមណីយដ្ឋានទេសចរណ៍បែបវប្បធម៌ ដែលមានស្រាប់ បម្រើដល់ការកម្សាន្តរបស់ទេសចរជាតិ និងអន្តរជាតិ។

**ច. គោលដៅយុទ្ធសាស្ត្រសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍នៅភូមិវត្តគរ**

- ភាពទាក់ទាញនៃវប្បធម៌៖ ជាបេតិកភណ្ឌវប្បធម៌អរិយធម៌សម្បូរបែបខុសប្លែកពីគេ និងមានអាយុកាលយូរណាស់មកហើយ ដូចជា សាសនា, ប្រពៃណីទំនៀមទម្លាប់, ភាពរស់រវើក និងសិល្ប:
- ភាពទាក់ទាញនៃស្ថាបត្យកម្មផ្ទះបុរាណខ្មែរ៖ ជាការបង្ហាញនូវប្រពៃណីទំនៀមទំលាប់ វប្បធម៌ និងការរស់នៅ ការសាងសង់ និងការកកើតនៅភូមិឋានរបស់ប្រជាជនខ្មែរដ៏យូរលុងណាស់មកហើយ។
- ប្រជាជន និង ប្រពៃណីទំនៀមទម្លាប់៖ ប្រជាជនកម្ពុជាផ្តល់បដិសណ្ឋារកិច្ចយ៉ាងល្អ ស្មោះត្រង់ គោរពគ្នាទៅវិញទៅមក និងទទួលការស្វាគមន៍ដោយភាពកក់ក្តៅ ចិត្តល្អ ស្នាមញញឹមពោរពេញដោយក្តីស្រលាញ់។
- ប្រើប្រាស់និមិត្តសញ្ញា (Branding Logo) ដែលជាការកំណត់សម្គាល់ភូមិទេសចរណ៍វប្បធម៌វត្តគរ
- ផ្សព្វផ្សាយនិមិត្តសញ្ញាតាមគោលដៅទេសចរណ៍វត្តគរ ដើម្បីទាក់ទាញទេសចរមកទស្សនាកម្សាន្ត ស្របតាមផលិតផលទេសចរណ៍នានានៅភូមិវត្តគរ ដូចជា ទេសចរណ៍វប្បធម៌, ទេសចរណ៍ផ្ទះបុរាណ, ទេសចរណ៍ម្ហូបអាហារ និងទេសចរណ៍សហគមន៍ ជាដើម។
- ជម្រុញការប្រើប្រាស់ថ្នាលឌីជីថលទេសចរណ៍ក្នុងផ្សព្វផ្សាយ
- សិក្សានូវវិធីសាស្ត្រនានាក្នុងការជម្រុញដល់ទេសចរ (ឧទាហរណ៍៖ ការសាងសង់ទីតាំងថតរូប នៅមុខក្លោងទ្វារភូមិវត្តគរ និងបំពាក់ប្រព័ន្ធ Wi-Fi ប្រើប្រាស់ឥតគិតថ្លៃជាដើម)
- ជម្រុញឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់បណ្តាញសង្គម ដើម្បីផ្សព្វផ្សាយទេសចរណ៍ភូមិវត្តគរ។

**ឆ. គោលដៅយុទ្ធសាស្ត្រពង្រឹងគុណភាពទេសចរណ៍និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍នៅភូមិវត្តគរ**

- ផ្តល់នូវគុណវុឌ្ឍិច្បាស់លាស់ដល់សិស្ស-និស្សិត (កម្លាំងពលកម្មថ្មីៗ) ដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន និងសេវាកម្មទេសចរណ៍នៅខេត្តបាត់ដំបង និងចាប់យកឱកាសការងារថ្មីៗប្រកបដោយឧត្តមភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារការងារក្នុងភូមិវត្តគរ ។

- ជម្រុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលខាងក្នុង (In-House Training) ដោយត្រូវមានគ្រូបង្គោល និងជនបង្គោល មានការបញ្ចូលគ្នាត្រឹមត្រូវ និងទទួលស្គាល់ត្រឹមត្រូវជាផ្លូវការពីសំណាក់មន្ទីរទេសចរណ៍ខេត្តបាត់ដំបង
- បង្កើតឱ្យមានកម្មវិធីសិក្សាតាមប្រព័ន្ធអនឡាញ(E-Learning) ក្នុងវិស័យទេសចរណ៍ក្នុងនោះមានមគ្គុទ្ទេសក៍ទេសចរណ៍។
- ពង្រឹងការបណ្តុះបណ្តាលដែលផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងនៅក្នុងកម្មវិធីសិក្សាទេសចរណ៍ (ទាមទារជាពិសេសលើវិស័យគ្រប់គ្រងសណ្ឋាគារ ម្ហូបអាហារ និងភេសជ្ជៈ) ដែលនិស្សិតត្រូវទទួលបានការបណ្តុះបណ្តាលជាក់ស្តែងក្នុងអំឡុងពេលសិក្សា និងមុនចុះកម្មសិក្សា។
- អនុវត្តមូលនិធិបណ្តុះបណ្តាលក្នុងជំនាញវិជ្ជាជីវៈទេសចរណ៍បម្រើឱ្យការ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៅខេត្តបាត់ដំបងឱ្យមានប្រសិទ្ធភាព។
- បង្កើតកម្មវិធីអាហារូបករណ៍សម្រាប់ធនធានមនុស្សនៅភូមិវត្តគរ
- រៀបចំវេទិកាអប់រំ និងបណ្តុះបណ្តាលក្នុងវិស័យទេសចរណ៍នៅភូមិវត្តគរប្រចាំឆ្នាំ៖ ដោយផ្សារភ្ជាប់ទៅនឹងពិព័រណ៍ការងារទេសចរណ៍ និងដំណើរទស្សនកិច្ចបច្ចេកទេសសិក្សា ការអនុវត្តល្អៗ និងបង្ហាញការអនុវត្តឧស្សាហកម្មទេសចរណ៍ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ក្នុងភូមិវត្តគរ។
- ធ្វើបច្ចុប្បន្នភាពសមត្ថភាពគ្រូអំពីជំនាញវិជ្ជាជីវៈទេសចរណ៍ផ្សារភ្ជាប់នឹងរបកគំហើញថ្មីៗពាក់ព័ន្ធនឹងវិស័យទេសចរណ៍ វប្បធម៌។ល។
- បង្កើតបណ្តាញអ្នកជំនាញទេសចរណ៍ នៅខេត្តបាត់ដំបង និងក្រុងបាត់ដំបងដែលមានការចូលរួមពីស្ថាប័នបណ្តុះបណ្តាល សាកលវិទ្យាល័យ មហាវិទ្យាល័យ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិស័យឯកជននានា
- ធ្វើការស្ទង់មតិនិយោជិក (Employment Survey) ជារៀងរាល់ឆ្នាំពីកម្មវិធីសិក្សាទេសចរណ៍៖ ដើម្បីវាស់ស្ទង់ទស្សនៈរបស់និយោជិកក្នុងវិស័យទេសចរណ៍ ដើម្បីរៀបចំយុទ្ធសាស្ត្រ បណ្តុះបណ្តាលឱ្យឆ្លើយតបទីផ្សារទេសចរណ៍។
- កម្មវិធីបណ្តុះបណ្តាលបដិសណ្ឋារកិច្ចល្អសម្រាប់បុគ្គលិកទេសចរណ៍ជួរមុខ (Frontline tourism employees) ដើម្បីធ្វើឱ្យពួកគេចាប់អារម្មណ៍អំពីតួនាទីរបស់ពួកគេទាក់ទងនឹងការស្វាគមន៍ និងការផ្តល់ភាពកក់ក្តៅដល់ទេសចរ
- ពង្រឹងការបណ្តុះបណ្តាលសហគ្រិនភាព គំនិតច្នៃប្រឌិត (Creativity) និងធុរកិច្ចថ្មី (Start-up) ក្នុងវិស័យទេសចរណ៍

- បង្កើតវគ្គសិក្សាតាមអនឡាញ (E-Learning) ភាពច្នៃប្រឌិតផលិតផលទេសចរណ៍ដល់អាជីវកម្មទេសចរណ៍អំពីជំនាញវិជ្ជាជីវៈទេសចរណ៍អនឡាញ។ ឆ្លើយតបនឹងតម្រូវការទេសចរ វគ្គសិក្សាក៏គួរតែត្រូវផ្តល់នូវដំណោះស្រាយលើការគ្រប់គ្រងគុណភាព និរន្តរភាព និងក្រមសីលធម៌នៅតាមអាជីវកម្មទេសចរណ៍ផងដែរ
- បង្កើនការបណ្តុះបណ្តាលជំនាញឌីជីថល (Digital Skill) ដល់ប្រតិបត្តិករទេសចរណ៍ខ្នាតតូច ខ្នាតមធ្យម និងក្នុងកម្រិតជំនាញវិជ្ជាជីវៈ
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលសហគ្រិនភាព និងធុរកិច្ចថ្មី (Start-up) នៅភូមិវត្តគរ
- រៀបចំសិក្ខាសាលាស្តីពីការបង្កើតកញ្ចប់ទស្សនកិច្ចដោយផ្តោតលើទីផ្សារទេសចរណ៍ជាន់ខ្ពស់សម្រាប់ប្រតិបត្តិករទេសចរណ៍៖ដូចជាការធ្វើផែនការធ្វើដំណើរកម្សាន្ត រួមមានការផ្តល់អាហារដល់មនុស្សវ័យចំណាស់ ការចំណាយ និងផែនការផ្សេងៗទៀត។
- ជម្រុញការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យស្របតាមការព្យាករ នៃតម្រូវការទីផ្សារ
- រៀបចំឱ្យមានយន្តការប្រកួតប្រជែង "មគ្គុទ្ទេសក៍ទេសចរណ៍ឆ្នើម" ប្រចាំឆ្នាំ។

## ២.៥.២. ការរៀបចំតំបន់សំណង់អតិរេក្ស

✍ ការស្តារឡើងវិញនូវសង្កាត់បេតិកភ័ណ្ឌដោយការជួសជុលនិងការការពារស្ថាបត្យកម្ម

- ជម្រុញការគាំទ្រពីសហគមន៍
- បង្កើតគណៈកម្មធិការសហគមន៍
- ជួសជុលអាគារបេតិកភ័ណ្ឌ
- ស្វែងរកហិរញ្ញវត្ថុសម្រាប់ការគាំទ្រដល់សកម្មភាពស្តារឡើងវិញ
- ធ្វើការចុះបញ្ជីរតំបន់បេតិកភណ្ឌសម័យអាណានិគម
- ធ្វើចំណាត់ថ្នាក់ "សង្កាត់បេតិកភណ្ឌ "
- ថែរក្សានិងផ្សារភ្ជាប់ប្រធានបទបេតិកភណ្ឌអាណានិគម
- អភិវឌ្ឍន៍ "ផ្លូវវប្បធម៌" នៅក្នុង "សង្កាត់បេតិកភណ្ឌ "
- ដំឡើងស្លាកសញ្ញាស្តីពីបេតិកភណ្ឌជាពហុភាសា
- រៀបចំ "សង្កាត់បេតិកភណ្ឌ "នៃក្រុង
- បង្កើតផ្លូវដើរទស្សនាសម្រាប់ភ្ញៀវទេសចរ
- ធ្វើការដាំរុក្ខជាតិដើមធំៗនៅតាមដងមហាវិថី។

✍ការផលិតនូវផលិតផលសិប្បកម្មជំនាញបែបប្រពៃណីដែលផ្គត់ផ្គង់ដល់ការចែកចាយនិងលក់រាយក្នុងទីតាំង "សង្កាត់បេតិកភណ្ឌ"ដែលបានជួសជុលឡើងវិញក្នុងក្រុង៖

- សហការជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ផ្ដល់ការលើកទឹកចិត្ត
- តាំងបង្ហាញ សិប្បកម្មជំនាញដោយដៃនៅក្នុងសារៈមន្ទីរ
- ធ្វើកំណត់ត្រានៃរូបមន្តធ្វើម្ហូបបែបប្រពៃណី
- ធ្វើកំណត់ត្រានៃរូបមន្តធ្វើម្ហូបបែបប្រពៃណី
- តម្រូវឲ្យភ្នាក់ងារទេសចរណ៍ទាំងអស់ត្រូវបញ្ចូលដំណើរទេស្សនកិច្ចរបស់ខ្លួន។

✍ ដាក់បញ្ចូលពិធីបុណ្យទៅក្នុងសកម្មភាពទេសចរណ៍ ដែលអាចទាក់ទាញនូវការចូលរួមសំដែងរបស់សមាគមន៍ សិល្បៈសម្រាប់ធ្វើសំដែងសិល្បៈប្រពៃណី សហការជាមួយនឹងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងផ្ដល់ឱកាសដល់ការសំដែងសិល្បៈ។

# ជំពូកទី៣

# របកគំហើញនៃការសិក្សាស្រាវជ្រាវ

## ៣.១. របកគំហើញនៃការសិក្សាស្រាវជ្រាវទេសចរ

ក្នុងការសិក្សាវិភាគប្រមូលទិន្នន័យនៅក្នុងក្រុងបាត់ដំបង ក្រុមសិក្សាស្រាវជ្រាវរបស់យើងបានធ្វើការបង្កើតនូវកម្រងសំណួរដើម្បីធ្វើការសាកសួរទេចរដែលបានមកកម្សាន្ត។ ចំពោះទិន្នន័យត្រូវបានជ្រើសរើសចំនួន ២៥នាក់ ដើម្បីធ្វើការឆ្លើយតបមកកាន់ការសម្ភាសន៍របស់យើងខ្ញុំ។

### ៣.១.១. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើសញ្ជាតិ




ក្រាហ្វិកទី១៖ ការបង្ហាញពីសញ្ជាតិ

តាមរយៈក្រាហ្វិកបានបង្ហាញថាទេចដែលបានទទួលការសម្ភាសន៍ជាជនជាតិខ្មែរមាន១៨នាក់ ស្មើ៧២% បរទេស២៨% ស្មើ២៨%។

### ៣.១.២. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើភេទ




ក្រាហ្វិកទី២៖ ការបង្ហាញពីភេទ

តាមរយៈក្រាហ្វិកបានបង្ហាញថាក្នុងចំនោមទេសចរទាំង ២៥នាក់មានទេសចរចំនួន១០នាក់ដែលជាប្រុសស្មើ៤០% មានទេសចរចំនួន ១៥នាក់ជាស្រីស្មើ៦០%។

### ៣.១.៣. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើអាយុ

តាមរយៈក្រាហ្វិកបានបង្ហាញថាក្នុងចំនោមទេសចរ២៥នាក់មានទេសចរចំនួន ១៥នាក់មានចន្លោះអាយុពី ១៨ ដល់ ៣០ឆ្នាំស្មើនឹង៦០% ៧នាក់មានចន្លោះអាយុពី ៣០ ដល់ ៦០ឆ្នាំស្មើនឹង២៨% និង៣នាក់មានចន្លោះអាយុពី ៦០ឡើងទៅស្មើនឹង១២%។




ក្រាហ្វិកទី៣៖ ការបង្ហាញពីអាយុ

## ៣.១.៤. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើមុខរបរ




ក្រាហ្វិកទី៤៖ ការបង្ហាញពីមុខរបរ

តាមរយៈក្រាហ្វិកបានបង្ហាញថាក្នុងចំនោមទេសចរ២៥នាក់មានទេសចរចំនួន៤នាក់មានមុខរបរជាគរុសិស្សស្មើនឹង១៦% ១១នាក់មានមុខរបរជានិស្សិតស្មើនឹង៤៤% ៧នាក់ជាបុគ្គលិកក្រុមហ៊ុនស្មើនឹង២៨% និង ៣នាក់មានមុខរបរជាគ្រូបង្រៀន១២%។

### ៣.១.៥. របកគំហើញនៃការសិក្សាស្រាវជ្រាវនៅលើបរិស្ថានក្នុងតំបន់គោលដៅ




ក្រាហ្វិកទី៥៖ បរិស្ថាននៅតំបន់គោលដៅ

តាមរយៈក្រាហ្វិកបានបង្ហាញការយល់ឃើញរបស់ទេសចរក្នុងចំណោម២៥នាក់គិតជាភាគរយមានដូចជា៖ ៨% បរិស្ថាននៅតំបន់គោលដៅគឺល្អណាស់ ៦០% មានការយល់ឃើញថាបរិស្ថាននៅតំបន់គោលដៅគឺល្អ ២០% មានការយល់ឃើញថាបរិស្ថាននៅតំបន់គោលដៅគឺបង្គួរ ១២% មានការយល់ឃើញថាបរិស្ថាននៅតំបន់គោលដៅគឺមធ្យម។

### ៣.១.៦. របកគំហើញនៃការសិក្សាស្រាវជ្រាវនៅលើហេដ្ឋារចនាសម្ព័ន្ធ

តាមរយៈក្រាហ្វិកបានបង្ហាញថាក្នុងចំនោមទេសចរ២៥នាក់មានទេសចរចំនួន ហេដ្ឋារចនាសម្ព័ន្ធមានលក្ខណៈល្អមានចំនួន ១៣នាក់ស្មើនឹង៥២% ហេដ្ឋារចនាសម្ព័ន្ធមានលក្ខណៈបង្គួរមានចំនួន ៩នាក់ស្មើនឹង៣៦% ហេដ្ឋារចនាសម្ព័ន្ធមានលក្ខណៈមធ្យមមានចំនួន ៣នាក់១២%។




ក្រាហ្វិកទី៦៖ ហេដ្ឋារចនាសម្ព័ន្ធ

### ៣.១.៧. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើអនាម័យក្នុងតំបន់គោលដៅ




ក្រាហ្វិកទី៧៖ អនាម័យក្នុងតំបន់គោលដៅ

តាមរយៈក្រាហ្វិកបានបង្ហាញពីអនាម័យក្នុងតំបន់គោលដៅក្នុងចំនោមទេសចរ២៥នាក់មាន ២នាក់មានការយល់ឃើញថាអនាម័យក្នុងតំបន់គោលដៅមានលក្ខណៈល្អណាស់ស្មើនឹង៨% ១១នាក់មានការយល់ឃើញថាអនាម័យក្នុងតំបន់គោលដៅមានលក្ខណៈល្អស្មើនឹង៤៤% ១០នាក់មានការយល់ឃើញថាអនាម័យក្នុងតំបន់គោលដៅមានលក្ខណៈបង្គួរស្មើនឹង៤០% និង២នាក់មានការយល់ឃើញថាអនាម័យក្នុងតំបន់គោលដៅមានលក្ខណៈមធ្យមស្មើនឹង៨%។

## ៣.១.៨. របកគំហើញនៃការសិក្សាស្រាវជ្រាវនៅលើការស្គាល់តំបន់គោលដៅ

តាមរយៈក្រាហ្វិកបានបង្ហាញថាទេសចរទាំង២៥នាក់បានស្គាល់តំបន់គោលដៅតាមរយៈ(គិតជាភាគរយ) ប្រព័ន្ធផ្សព្វផ្សាយមាន ៤៤,១% គ្រួសារ/មិត្តភក្តិមាន៥២,៩% និងខិត្តប័ណ្ណមាន២.៩%។




ក្រាហ្វិកទី៨៖ ការស្គាល់ពីតំបន់គោលដៅ

## ៣.១.៩. របកគំហើញនៃការសិក្សាស្រាវជ្រាវនៅលើមធ្យោបាយធ្វើដំណើរ

តាមរយៈក្រាហ្វិកបានបង្ហាញថាការធ្វើដំណើររបស់ទេសចរ២៥នាក់មាន ការធ្វើដំណើរតាមរយៈរថយន្តផ្ទាល់ខ្លួនមានចំនួន ៦នាក់ស្មើនឹង២៤% ការធ្វើដំណើរតាមរយៈរថយន្តទេសចរណ៍មានចំនួន ៥នាក់ស្មើនឹង២០% ការធ្វើដំណើរតាមរយៈម៉ូតូមានចំនួន ១២នាក់ស្មើនឹង៤៨% និងការធ្វើដំណើរតាមរយៈមធ្យោបាយផ្សេងៗមានចំនួន ២នាក់ស្មើនឹង៨%។




ក្រាហ្វិកទី៩៖ មធ្យោបាយធ្វើដំណើរ

### ៣.១.១០. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើគោលបំណងនៃធ្វើដំណើរទៅកាន់គោលដៅ




ក្រាហ្វិកទី១០៖ គោលបំណងក្នុងការកម្សាន្ត

តាមរយៈក្រាហ្វិកបានបង្ហាញថាគោលបំណងសម្រាប់ទេសចរមាន(គិតជាភាគរយ) ៧៦% មានគោលបំណងក្នុងការសម្រាកកម្សាន្ត ១២% មានគោលបំណងក្នុងសិក្សាស្រាវជ្រាវ ៤% មានគោលបំណងក្នុងការធ្វើការងារ និង៨% មានគោលបំណងក្នុងការមកលេងសាច់ញាតិ។

### ៣.១.១១. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើប្រភេទគោលដៅដែលមាននៅក្នុងក្រុងបាត់ដំបង




ក្រាហ្វិកទី១១៖ ប្រភេទគោលដៅក្នុងក្រុងបាត់ដំបង

តាមរយៈក្រាហ្វិកបានបង្ហាញពីប្រភេទគោលដៅក្នុងក្រុងបាត់ដំបងជាភាគរយមាន ទេសចរណ៍សិក្សាស្រាវជ្រាវមាន១០,៣% ទេសចរណ៍សម្រាកលំហែរមាន ៤៨,៧% និងទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ៤១%។

### ៣.១.១២. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើឱកាសនៃការធ្វើដំណើរកម្សាន្ត

តាមរយៈក្រាហ្វិកបានបង្ហាញថាឱកាសក្នុងការទៅកម្សាន្តមាន(គិតជាភាគរយ) ចុងសប្តាហ៍មាន ៣៧.៩% ពិធីបុណ្យនានា ៤១.៤% និងផ្សេងៗ ២០.៧%។




ក្រាហ្វិកទី១២៖ ឱកាសក្នុងការទៅកម្សាន្ត

### ៣.១.១៣. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើសេវាកម្មបម្រើដល់ទេសចរ

តាមរយៈក្រាហ្វិកបានបង្ហាញពីសេវាកម្មដែលបម្រើដល់ទេសចរមាន(គិតជាភាគរយ) ការស្នាក់នៅមាន ២៧.៣% ម្ហូបអាហារមាន ៣១.៨% កម្សាន្តមាន ២៨.៨% ការដឹកជញ្ជូនមាន ៦.១% និងផ្សេងៗមាន ៦.១%។




ក្រាហ្វិកទី១៣៖ សេវាកម្មបម្រើដល់ទេសចរក្នុងតំបន់គោលដៅ

### ៣.១.១៤. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការពេញចិត្តនៃសេវាកម្ម

តាមរយៈក្រាហ្វិកបានបង្ហាញពីការពេញចិត្តចំពោះសេវាកម្មក្នុងចំនោម២៥នាក់មានចំនួន ២នាក់មានការពេញចិត្តណាស់ស្មើនឹង៨% ១៤នាក់មានការពេញចិត្តស្មើនឹង៥៦% ៨នាក់បង្គួរស្មើនឹង៣២% និង១នាក់មធ្យម៤%។




ក្រាហ្វិកទី១៤៖ ការពេញចិត្តចំពោះសេវាកម្មបម្រើដល់ទេសចរក្នុងតំបន់គោលដៅ

### ៣.១.១៥. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការយល់ឃើញពីសេវាកម្មថាគ្រប់គ្រាន់ទេ




ក្រាហ្វិកទី១៥៖ ភាពគ្រប់គ្រាន់នៃសេវាកម្មបម្រើដល់ទេសចរក្នុងតំបន់គោលដៅ

តាមរយៈក្រាហ្វិកមានបង្ហាញពីការពេញចិត្តនៃសេវាកម្មនៅតំបន់គោលដៅគឺ មាន៩នាក់យល់ឃើញថាគ្រប់គ្រាន់ស្មើនឹង៣៦% និងមាន១៦នាក់យល់ឃើញថាមិនទាន់គ្រប់គ្រាន់ស្មើនឹង៦៤%។

### ៣.១.១៦. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើរយៈពេលនៃការមកកម្សាន្ត




ក្រាហ្វិកទី១៦៖ រយៈពេលនៃការមកកម្សាន្ត

តាមរយៈក្រាហ្វិកបានបង្ហាញឲ្យឃើញពីរយៈពេលនៃដំណើរកម្សាន្ត មាន ៩នាក់ទៅកម្សាន្តមួយថ្ងៃស្មើនឹង៣៦% មាន៨នាក់ទៅកម្សាន្តពីរថ្ងៃស្មើនឹង៣២% និងមាន៨នាក់ទៅកម្សាន្តលើសពីពីរថ្ងៃស្មើនឹង៣២%។

### ៣.១.១៧. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើសន្តិសុខសុវត្ថិភាពក្នុងតំបន់គោលដៅ

តាមរយៈក្រាហ្វិកបានបង្ហាញពីសន្តិសុខនៅតំបន់គោលដៅក្នុងចំនោម២៥នាក់មាន ២នាក់យល់ឃើញថាល្អណាស់ស្មើនឹង៨% ១១នាក់យល់ឃើញថាល្អស្មើនឹង៤៤% ១០នាក់យល់ឃើញថាបង្គួរស្មើនឹង៤០% និង២នាក់យល់ឃើញថាមធ្យម៨%។




ក្រាហ្វិកទី១៧៖ សុខសុវត្ថិភាពនៅតំបន់ទេសចរណ៍ក្នុងក្រុង

### ៣.១.១៨. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការវិលត្រឡប់មកកម្សាន្តជាថ្មីម្តងទៀត




ក្រាហ្វិកទី១៨៖ ការវិលត្រឡប់មកវិញ

តាមរយៈក្រាហ្វិកបានបង្ហាញពីការត្រឡប់មកវិញក្នុងចំនោម២៥នាក់មាន ២៣នាក់នឹងត្រឡប់មកវិញស្មើនឹង៩២% និង២នាក់មិនទាន់ប្រាកដស្មើនឹង៨%។

## ៣.១.១៩. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការផ្សព្វផ្សាយពីតំបន់គោលដៅ

តាមរយៈក្រាហ្វិបានបង្ហាញពីការផ្សព្វផ្សាយពីតំបន់គោលដៅក្នុងចំនោម២៥នាក់មាន ១២% យល់ឃើញថាល្អណាស់ ៤៤% យល់ឃើញថាល្អ ៣២% យល់ឃើញថាបង្គួរ ១២%យល់ឃើញថាមធ្យម។




ក្រាហ្វិកទី១៩៖ ការផ្សព្វផ្សាយពីតំបន់គោលដៅ

## ៣.១.២០. របកគំហើញនៃការសិក្សាស្រាវជ្រាវទៅលើការពន្យាពេលស្នាក់នៅរបស់ទេសចរដោយបង្កើនផលិតផលទេចរណ៍

តាមរយៈក្រាហ្វិកបានបង្ហាញពីការពន្យាពេលស្នាក់នៅរបស់ទេសចរក្នុងចំនោម២៥នាក់មាន ២១នាក់ស្មើនឹង ៨៤%មានការយល់ឃើញថាបាន ហើយ៤នាក់ស្មើនឹង១៦% យល់ឃើញមិនបាន។




ក្រាហ្វិកទី២០៖ ការពន្យាពេលស្នាក់នៅ

### ៣.២. ការសិក្សាវិភាគពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង

ជានិច្ចកាល រាល់ការអភិវឌ្ឍអ្វីមួយតែងជួបប្រទះនូវឥទ្ធិពលផ្សេងៗ ដោយក្នុងនោះគឺ ឥទ្ធិពលវិជ្ជមាន និង ឥទ្ធិពលអវិជ្ជមាន។ ការវិភាគ SWOT នេះ ធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីស្ថានភាពទេសចរណ៍ក្នុងខេត្ត (បច្ចុប្បន្ន និងអនាគត)។ លទ្ធផលនៃការ វិភាគ SWOT នេះ នឹងអាចជួយកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ឱ្យកាន់តែមានភាពច្បាស់លាស់ និងប្រកបដោយ ប្រសិទ្ធិភាព និងភាពទទួលខុសត្រូវខ្ពស់ និងបង្ហាញឲ្យឃើញពីសក្តានុពលទេសចរណ៍ក្នុងក្រុងបាត់ដំបងដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកលើកិត្យានុភាពមុខមាត់ខេត្តតាមរយៈការអភិវឌ្ឍន៍វិស័យទេសចរណ៍។ លើសពីនេះទៅទៀត ការវិភាគនេះជួយបង្ហាញថាក្រុងបាត់ដំបងនឹងផ្តល់ ឱកាសច្រើនសម្រាប់អ្នកវិនិយោគលើ វិស័យទេសចរណ៍ និងការគាំទ្រ។

### ៣.២.១. ចំណុចខ្លាំង

ចំណុចខ្លាំងបង្ហាញពីសក្តានុពលដែលនាំឱ្យក្រុងបាត់ដំបង  មានភាពទាក់ទាញទេសចរណ៍មកកម្សាន្តបានយ៉ាងច្រើន៖

- សម្បទាទេសចរណ៍សម្បូរបែប៖ ក្រុងបាត់ដំបងជាតំបន់ប្រមូលផ្តុំនៃសម្បទា និងសេវាកម្មទេសចរណ៍ចម្រុះ ដែលអាចផ្គត់ផ្គង់បានគ្រប់គ្រាន់នឹងទាន់ពេលវេលាសម្រាប់ទេសចរណ៍។ ភាពសម្បូរបែបនៃសេវាកម្មទេសចរណ៍ បានផ្តល់ជម្រើសជាច្រើនដល់ភ្ញៀវសម្រាប់ការសម្រេចចិត្តប្រើប្រាស់សេវាទាំងនោះ។ បើយើងប្រៀបធៀបជាមួយបណ្តាខេត្តជុំវិញ សង្កេតឃើញថា ក្រុងបាត់ដំបងមានភាពលេចធ្លោលើសម្បទាទ្រទ្រង់ទេសចរណ៍ជាងខេត្តផ្សេងៗ។
- កេរ្តិ៍ឈ្មោះរបស់ក្រុងបាត់ដំបង៖ ខេត្តបាត់ដំបង ជាខេត្តមួយដែលមានកេរ្តិ៍ឈ្មោះល្បីតាំងពីសម័យបាត់ដំបងសម័យលោកម្ចាស់ សម័យបារាំង សម័យសង្គមរាស្ត្រនិយមមកម្លេះ។ មិនតែប៉ុណ្ណោះគេស្គាល់បាត់ដំបងច្រើនតាមរយៈបទចម្រៀងរបស់កវីអ្នកនិពន្ធដូចជាកវីម្ចាស់ដងស្ទឹងសង្កែគង្គប៊ុនឈឿន សំនៀងសូរស័ព្ទរបស់អធិរាជសម្លេងមាស ស៊ិន ស៊ីសាមុត រស់ សេរីសុទ្ធា ប៉ែន រ៉ន... និងភាពសម្បូរបែបនៃសម្បត្តិវប្បធម៌ បេតិកភណ្ឌ ទំនៀមទំលាប់ប្រពៃណី របស់អ្នកបាត់ដំបងផងដែរ។ ជាពិសេសក្រុងបាត់ដំបង បានជាប់ជាជ័យលាភីលេខ១ ក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត។ បន្ថែមលើសនេះទៅទៀតបាត់ដំបងជាទីក្រុងស៊ីវិល័យនាទសវត្សឆ្នាំ៦០។
- សក្តានុពលទាក់ទាញ៖ ក្រុងបាត់ដំបងមានសក្តានុពលទាក់ទាញទេសចរណ៍យ៉ាងសម្បូរបែប ដែលរួមមាន៖វប្បធម៌ ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម ប្រពៃណី ធម្មជាតិ កែច្នៃ និងផលិតផលទ្រទ្រង់ទេសចរណ៍ប្រចាំតំបន់ចម្រុះយ៉ាងសំបូរបែបផងដែរ។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖ ទីក្រុងបាត់ដំបងមានផ្លូវប្រវត្តិដ៏អស្ចារ្យដែលអាចទាក់ទាញទេសចរបានយ៉ាងច្រើន ដែលផ្លូវទាំងអស់នោះមានសភាពស្អាតស្ទើតែគ្រប់សង្កាត់ទូទាំងក្រុង ផ្ទះដែលបានតភ្ជាប់នឹងបណ្តាញទឹកស្អាតរហូតដល់ ៨៥.៥៨ % និងទឹកតភ្ជាប់បណ្តាញអគ្គិសនី រហូតដល់ ៩៨.៧% និងមានចញ្ចើមផ្លូវដែលអាចរៀបចំសម្បទារទ្រទ្រង់សម្រាប់វិស័យទេសចរណ៍ទីក្រុង។
- សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព៖ ធានាបានចំពោះភ្ញៀវព្រោះមានកងកម្លាំងប្រដាប់អាវុធល្បាតជាប្រចាំ និងកម្រនឹងមានបាតុភូតណាមួយកើតឡើងក្នុងដែនដីក្រុងបាត់ដំបងណាស់។ បន្ថែមពីនេះនគរបាលទេសចរណ៍ខេត្ត បានសហការយ៉ាងស្អិតរមួតជាមួយមន្ទីរទេសចរណ៍ដើម្បីធានាអំពីសុខសុវត្ថិភាពជូនទេសចរទាំងជាតិ និងអន្តរជាតិ។
- សក្តានុពលបណ្តាញទឹកធម្មជាតិ៖ ទីក្រុងបាត់ដំបងមានដងស្ទឹងសង្កែ ដែលជាបណ្តាញផ្លូវទឹកធម្មជាតិ និងមានប្រវត្តិសាស្ត្រយ៉ាងសំបូរបែប។ ដងស្ទឹងសង្កែមានសក្តានុពលទេសចរណ៍យ៉ាងសម្បូរបែប ដែលអាចរៀបចំជាបណ្តាញទស្សនៈកិច្ចផ្លូវទឹកដោយរៀបចំជាការជិះទូកកំសាន្ត អមដោយការរៀបរាប់

នូវប្រវត្តិសាស្ត្រ និងសិល្បៈ ។ ដងស្ទឹងសង្កែក៏ជាប្រពភនៃជីវៈភាពប្រចាំថ្ងៃប្រជាពលរដ្ឋដែលរស់នៅតាមដងស្ទឹងដែលប្រកបរបរនេសាទ កសិកម្មផងដែរ។

- ភាពរួសរាយរាក់ទាក់របស់អ្នកបាត់ដំបងៈ ស្នាមញញឹម ភាពរាក់ទាក់ ជួយយកអាសារ ព្រមទាំងភាសានិយាយច្បាស់ៗ ដែលគួរឱ្យចង់ស្តាប់ ក៏ជាចំណុចទាក់ទាញទេសចរផងដែរ។
- ភាពសម្បូរបែប និងទាក់ទាញនៃម្ហូបអ្នកបាត់ដំបង (Gastronomy Tourism)។

### ៣.២.២. ចំណុចខ្សោយ

- គោលដៅទេសចរណ៍មួយចំនួន មិនទាន់មានការអភិវឌ្ឍ និងរៀបចំបានល្អៈ តំបន់ទេសចរវប្បធម៌ ភូមិវត្តគរ វត្តមានសក្តានុពលទេសចរណ៍ ផាប់ស្រ្ទីត វិថីលក់ម្ហូបអាហារ នៅមិនទាន់រៀបចំឆ្លើយតបនឹងតម្រូវការទេសចរណ៍នៅឡើយ។
- ការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ក្រុងបាត់ដំបងនៅមានកម្រិតៈ ជាពិសេសទៅកាន់ទីផ្សារអន្តរជាតិ ការផ្សព្វផ្សាយថ្នាក់ជាតិភាគច្រើនផ្តោតទៅលើតែតំបន់ប៉ូលទាំង៤ រួមមាន ភ្នំពេញ សៀមរាប តំបន់ឆ្នេរ និងភូមិភាគឥសាន្ត។
- ខ្វះនូវការផ្តល់ព័ត៌មានទេសចរណ៍ៈ ខ្វះមណ្ឌល និងបញ្ជរព័ត៌មានទេសចរណ៍នៅកន្លែងសំខាន់ៗក្នុងក្រុង។
- ខ្វះស្លាកសញ្ញានានាៈ ស្លាកសញ្ញាបង្ហាញផ្លូវ និងព័ត៌មានសំខាន់ៗក្នុងក្រុងមិនទាន់មានគ្រប់គ្រាន់ នាំឱ្យទេសចរមានការលំបាកក្នុងការស្វែងរកទីតាំង ឬព័ត៌មានមួយចំនួន។
- មធ្យោបាយដឹកជញ្ជូនភ្ញៀវមិនទាន់សម្បូរបែបៈ បច្ចុប្បន្ន បាត់ដំបងប្រើប្រាស់ផ្លូវថ្នល់ជាមធ្យោបាយសំខាន់សម្រាប់ការដឹកជញ្ជូនទេសចរណ៍។ ផ្លូវដែកត្រូវបានរៀបចំតែមិនបម្រើឱ្យការដឹកជញ្ជូនទេសចរឡើយព្រោះ កាលវិភាគមិនញឹកញាប់ និងផ្តោតសំខាន់លើការដឹកជញ្ជូនទំនិញ និងប្រេងប៉ុណ្ណោះ។ ផ្លូវទឹកប្រែប្រួលទៅតាមរដូវកាល និងមិនមានការកំណត់ច្បាស់លាស់នៅឡើយ។ មិនទាន់ដំណើរការនូវអាកាសយានដ្ឋាន មិនអាចផ្តល់សេវាដឹកជញ្ជូនភ្ញៀវតាមផ្លូវអាកាសបានឡើយ។
- បុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍មិនទាន់មានជំនាញច្បាស់លាស់ៈ ភាគច្រើននៃបុគ្គលិកមិនបានទទួលការបណ្តុះបណ្តាលជំនាញត្រឹមត្រូវ បណ្តាលឱ្យគុណភាពសេវាដែលបម្រើជូនភ្ញៀវនៅមានកម្រិត។
- ខ្វះដៃគូអភិវឌ្ឍន៍ផ្ទាល់ជាមួយមន្ទីរទេសចរណ៍ៈ គម្រោងពាក់ព័ន្ធនឹងវិស័យទេសចរណ៍មួយចំនួនធំមិនសូវមានការចូលរួមដោយមន្ត្រីជំនាញពីមន្ទីរទេសចរណ៍ឡើយ។

- មន្ត្រីដែលមានជំនាញទេសចរណ៍នៅមានកម្រិត៖ អ្នកជំនាញក្នុងការធ្វើផែនការ និងគំនិតអភិវឌ្ឍទេសចរណ៍នៅមានតិចតួចបើប្រៀបធៀបនឹងខេត្តនៃតំបន់ប៉ូលទេសចរណ៍។
- សេវាកម្មបម្រើទេសចរណ៍មិនទាន់មានភាពប្រសើរតាមស្តង់ដា និងគុណភាពផលិតផលទេសចរណ៍នៅមានកម្រិត៖ អាជីវករមួយចំនួនធំមិនមែនជាអ្នកជំនាញក្នុងវិស័យទេសចរណ៍ នាំឱ្យពួកគាត់មិនសូវយល់ច្បាស់ពីស្តង់ដាទេសចរណ៍។
- ខ្វះខាតនូវមូលនិធិទេសចរណ៍សម្រាប់ទ្រទ្រង់និងគាំពារវិស័យទេសចរណ៍
- ការសហការរវាងស្ថាប័នពាក់ព័ន្ធនៅមិនទាន់បែងចែកការគ្រប់គ្រងឱ្យបានច្បាស់៖ ការចូលរួមសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធនៅមានកម្រិត។
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត៖ ប្រជាជនមានការយល់ដឹងពីអត្ថប្រយោជន៍ពីវិស័យទេសចរណ៍នៅមានកម្រិតនៅឡើយ។

### ៣.២.៣. ឱកាស

ឥទ្ធិពលវិជ្ជមាន គឺជាឥទ្ធិពលទាំងឡាយណាដែលផ្តល់នូវភាពល្អប្រសើរ ឬបង្កលក្ខណៈងាយស្រួលដល់គម្រោងអភិវឌ្ឍន៍មួយ។ ឥទ្ធិពលវិជ្ជមានអាចមានដូចខាងក្រោម៖

- សេដ្ឋកិច្ចរីកចម្រើន៖ ជួយជម្រុញឱ្យប្រជាពលរដ្ឋហ៊ានចំណាយច្រើនជាងមុន ដូចនេះពួកគាត់នឹងមានទំនោរដើរកម្សាន្តច្រើនជាងមុន។ កត្តាបានជម្រុញតម្រូវការច្រើនក្នុងវិស័យទេសចរណ៍ ដែលទាមទារនូវការអភិវឌ្ឍដើម្បីឆ្លើយតបទៅនឹងតម្រូវការឱ្យបានគ្រប់គ្រាន់។ ដូចនេះ ការអភិវឌ្ឍគឺមានទីផ្សារស្រាប់ធានាថានឹងទទួលបានអត្ថប្រយោជន៍ភ្លាមៗតែម្តង។ ជាក់ស្តែង ២ឆ្នាំចុងក្រោយនេះ មានទេសចរជាតិនិងអន្តរជាតិជាច្រើនបានមកទស្សនាខេត្តបាត់ដំបង និងមានការចំណាយខ្ពស់ជាងមុន។ សណ្ឋាគារបែបរីស៊ត ដែលមានតម្លៃចាប់ពី៤០ដុល្លារទៅ មានទីផ្សារខ្ពស់ ព្រោះទេសចរហ៊ានចំណាយដើម្បីទទួលបាននូវបទពិសោធន៍ថ្មីៗ។
- ភាពរីកចម្រើននូវប្រព័ន្ធផ្សព្វផ្សាយ៖ ដូចជាបណ្តាញទំនាក់ទំនងសង្គមFacebook Telegram Instagram -ល- បានជួយជម្រុញ លើកទឹកចិត្តឱ្យមនុស្សចង់ដើរកម្សាន្ត។ ជាក់ស្តែង ក្នុងខែឧសភាឆ្នាំ២០២០ ទោះបីដំណាក់កាលនៃជំងឺកូវីដ១៩ មិនទាន់បានធូរស្រាលនៅឡើយ តែចំនួនភ្ញៀវទេសចរក្នុងស្រុកដើរកម្សាន្តតាមរមណីយដ្ឋាន និងគោលដៅទេសចរណ៍ក្នុងខេត្តបាត់ដំបង មានកំណើនជាងឆ្នាំ២០១៩ ជិតពាក់កណ្តាល។

- ភាពរីកចំរើននូវប្រព័ន្ធគមនាគមន៍៖ នឹងជួយសម្រួលដល់ការធ្វើដំណើររបស់ទេសចរទៅដល់កន្លែងដែលគាត់ប្រាថ្នាចង់ទៅ។ ប្រព័ន្ធគមនាគមន៍នេះ និយាយអំពីភាពសម្បូរបែបនូវសេវាដឹកជញ្ជូន ទាំងផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក។ ជាក់ស្តែង អាកាសយានដ្ឋានរបស់ក្រុងបាត់ដំបងកំពុងសិក្សាដើម្បីរៀបចំបើកដំណើរការឡើងវិញដោយក្រុមហ៊ុនអាកាសចរមួយរបស់ប្រទេសបារាំង ដែលជាឱកាសមួយក្នុងការបង្កភាពងាយស្រួលដល់ទេសចរលំដាប់ខ្ពស់អាចមកទស្សនាខេត្តបាត់ដំបងវិញដោយចំណេញពេលវេលាក្នុងការធ្វើដំណើរ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុន Royal Railway កំពុងត្រៀមដំណើរការការដឹកជញ្ជូនតាមផ្លូវដែកឡើងវិញ (ដូចពីភ្នំពេញទៅកំពត) ដែលអាចផ្តល់នូវបទពិសោធន៍ថ្មីៗជូនភ្ញៀវតាមរយៈការធ្វើដំណើរតាមមធ្យោបាយនេះ។ មិនតែប៉ុណ្ណោះ ទំនប់សាលាតាអននឹងធ្វើរួចរាល់ធ្វើឱ្យកម្ពស់ទឹកថេរ ដែលនាំឱ្យទីតាំងចំណតទូកទេសចរណ៍មានភាពច្បាស់លាស់ ធ្វើឱ្យកាលវិភាគដឹកជញ្ជូនភ្ញៀវនឹងមានភាពញឹកញាប់ជាងមុន។
- សាកលវិទ្យាល័យមួយចំនួនបានចាប់អារម្មណ៍ជាមួយនឹងការបណ្តុះបណ្តាលជំនាញទេសចរណ៍៖ និស្សិតសិក្សាជំនាញទេសចរណ៍មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលនាំឱ្យអ្នកជំនាញក្នុងវិស័យនេះកាន់តែច្រើន និងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តកាន់តែប្រសើរ។
- វិនិយោគិនមួយចំនួនងាកមកវិនិយោគក្នុងវិស័យទេសចរណ៍ក្នុងខេត្ត៖ គោលដៅទេសចរណ៍ថ្មីៗត្រូវបានបង្កើតឡើងដែលនាំឱ្យភ្ញៀវមកលេងក្រុងបាត់ដំបងមានជំរើសច្រើនក្នុងការដើរទស្សនកិច្ចនិងពន្យារពេលស្នាក់នៅរបស់ពួកគេ។
- ក្រុងបាត់ដំបងត្រៀមចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក៖ នឹងកាន់តែធ្វើឱ្យពិភពលោកស្គាល់បាត់ដំបងកាន់តែច្បាស់ ព្រមទាំងអាចទទួលបានភ្ញៀវទេសចរអន្តរជាតិច្រើននាពេលខាងមុខដូចនៅ លួងព្រះបាង ប្រទេសឡាវ។
- កម្ពុជាត្រៀមធ្វើជាម្ចាស់ផ្ទះ SEAGAME ឆ្នាំ២០២៣៖ ក្រុងបាត់ដំបងនឹងទទួលនូវការប្រកួតកីឡាមួយចំនួនដូចជា កីឡាហែលទឹក -ល-។
- ការរីកលូតលាស់នៃហេដ្ឋារចនាសម្ព័ន្ធទៅកាន់តំបន់សក្តានុពលទេសចរណ៍ និងការតភ្ជាប់ផ្លូវជាតិសំខាន់ៗ៖
    - ការជួសជុលរួចជាស្ថាពរឡើងវិញនូវផ្លូវជាតិលេខ៥ (ភ្នំពេញ-បាត់ដំបង-សេរីសោភ័ណ្ឌ)
    - ផ្លូវវៀងក្រុងទី២ (ក្រុងបាត់ដំបងនឹងកាន់តែមានផាសុកភាពក្នុងការធ្វើចរាចរណ៍)
    - ផ្លូវកាត់តាមស្របតាមបឹងទន្លេសាប កាត់តាមស្រុកឯកភ្នំ ស្រុកព្រះនេត្រព្រះ ឆ្ពោះទៅកាន់ខេត្តសៀមរាប (ជាង ៧០ គ.ម)

- បើកសម្ពោធច្រក ៤០០ ជាច្រកទ្វារអន្តរជាតិ (កំណើនទេសចរណ៍ថៃ)

◆ ការសាងសង់ទំនប់សាលាតាអនះ នាំឱ្យទឹកស្ទឹងសង្កែក្នុងក្រុងខ្ពស់ ផ្តល់ភាពទាក់ទាញនៃសម្រស់ក្រុងបាត់ដំបងកាន់តែខ្លាំង។

◆ ការរីកលូតលាស់នៃកសិទេសចរណ៍នៅតំបន់ជុំវិញក្រុង៖ ទេសចរអាចស្វែងយល់ពីការរស់នៅ និងរបរចិញ្ចឹមជីវិតរបស់កសិករក្នុងខេត្តបាត់ដំបងបន្ថែម។

◆ គោលដៅទេសចរណ៍សាសនាដ៏ធំប្រចាំភូមិភាគពាយ័ព្យ៖ មានមជ្ឈមណ្ឌលវិបស្សនាធំប្រចាំតំបន់ និងការកសាងពុទ្ធប្រវត្តិនៅជញ្ជាំងភ្នំសំពៅ និងការត្រៀមរៀបចំវត្តទេសចរណ៍ក្នុងសម័យលោកម្ចាស់ដើម្បីបម្រើដល់ការទស្សនា សិក្សាស្រាវជ្រាវរបស់ទេសចរផងដែរ។

### ៣.២.៤. ការគំរាមកំហែង

◆ បញ្ហាបម្រែបម្រួលធម្មជាតិ៖ ជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យទេសចរណ៍។ ខ្យល់ព្យុះ ទឹកជំនន់ -ល- បានបង្កផលប៉ះពាល់ជាច្រើនដល់គោលដៅទេសចរណ៍ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ជាក់ស្តែងតំបន់ទេសចរណ៍ល្បីៗនៅក្នុងខេត្តបាត់ដំបងភាគច្រើនពឹងផ្អែកលើប្រភពទឹក ស្ទឹង បឹង ទន្លេ។ ក្នុងរដូវទឹកឡើង គោលដៅទេសចរណ៍ទាំងនោះភាគច្រើនមិនអាចបើកដំណើរការបានទេ ព្រោះត្រូវបានទឹកជន់ជោរលិច។ ជាអកុសល ក្នុងឆ្នាំ២០១៩ មានទឹកទំនន់ធំបានហូរច្រោះដីច្រាំងព្រមទាំងដើមឈើដំណាំ ជាពិសេសដើមធុរេនជាច្រើនសិបដើមទៅតាមទឹក នៅរមណីយដ្ឋានស្ទឹងថ្មចាចំការធុរេន ក្នុងស្រុកសំឡូត។ រីឯផលប៉ះពាល់ដោយប្រយោល គឺប្រជាជនរងគ្រោះធម្មជាតិ កសិផលមិនសូវបាន នាំឱ្យបាត់បង់ចំនូល មិនមានលទ្ធភាពក្នុងការដើរកម្សាន្ត។

◆ ការរីករាលដាលនៃជំងឺឆ្លង៖ ជាពិសេសជំងឺផ្លូវដង្ហើមដូចជា ជំងឺសារ ជំងឺផ្តាសាយ ជំងឺកូវីដ១៩ បង្កឱ្យមានការធ្លាក់ចុះយ៉ាងគំហុកនូវទេសចរទូទាំងពិភពលោក ដែលបណ្តាលឱ្យអាជីវកម្មទេសចរណ៍ភាគច្រើនទទួលរងផលប៉ះពាល់ ស្ទើរតែក្ស័យធន។

◆ ការគ្រប់គ្រងសំណល់នៅមានកម្រិត៖ ក្រុមហ៊ុនប្រមូលសម្រាមមិនទាន់មានលទ្ធភាពប្រមូលសម្រាមបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដែលនាំឱ្យពេលខ្លះសម្រាមនៅគរទុកយូរថ្ងៃប៉ះពាល់ដល់ទេសចរ។ បន្ថែមពីនេះទៅទៀត ទីលានចាក់សម្រាមកំពុងតែប្រឈមនឹងបញ្ហាលើសសមត្ថភាពផ្ទុក ជាពិសេសនៅរដូវវស្សា ហើយទីលាននេះមានភ្លើងឆេះជាប្រចាំនៅរដូវប្រាំងដែលជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថាន និងគុណភាពខ្យល់ក្នុងក្រុងបាត់ដំបង។

- ការជួសជុលសំណង់អភិរក្ស៖ សំណង់អភិរក្សមួយចំនួនកំពុងប្រឈមនឹងសភាពចាស់ទ្រុឌទ្រោម ដែលនាំឱ្យទាមទារការជួសជុលនឹងអភិរក្ស ហើយម្ចាស់ផ្ទះមួយចំនួនពុំមានលទ្ធភាពក្នុងការជួសជុលឱ្យសមស្របតាមលក្ខខណ្ឌតម្រូវរបស់អាជ្ញាធរឡើយ។ បន្ថែមពីនេះ ផ្ទះមួយចំនួនបានជួសជុលខុសពីស្ថាបត្យកម្មដើម ដែលនាំឱ្យបាត់បង់អត្តសញ្ញាណនៃភាពទាក់ទាញ។
- ទទួលរងឥទ្ធិពលសេដ្ឋកិច្ចពិភពលោក៖ ការធ្លាក់ចុះនៃសេដ្ឋកិច្ចជាសាកល នាំឱ្យក្រុងបាត់ដំបងអាចបាត់បង់ភ្ញៀវចូលមកកម្សាន្តផងដែរ។

# ជំពូកទី៤

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវ និងវិភាគលើស្ថានការណ៍នៃការគ្រប់គ្រង និងអភិវឌ្ឍន៍ជាក់ស្តែងយ៉ាងលម្អិតនិងស៊ីជម្រៅរួចមកយើងសង្កេតឃើញថាមានកំណែទម្រង់ជាច្រើននៅតំបន់នោះ។ តំបន់ដែលប្រៀបបីដូចជាទីក្រុងដែលប្រណីតជាមជ្ឈដ្ឋានដែលទាក់ទាញទេសចរពីគ្រប់ទិសទីជាពិសេសទេសចរបារាំង ឱ្យមកកម្សាន្តសិក្សាស្វែងយល់ និងទទួលបានបទពិសោធន៍ថ្មីៗទាំងថ្ងៃឈប់សម្រាក វិស្សមកាល និងពិធីបុណ្យនានា។នៅក្នុងដំណើរការនៃការជម្រុញភាពទាក់ទាញ ការគ្រប់គ្រង និងការអភិវឌ្ឍផែនការទាំងអស់នេះគឺកើតចេញពីការខិតខំប្រឹងប្រែង និងការរួបរួមគ្នាទាំងផ្នែករដ្ឋ ឯកជន អង្គការដែលពាក់ព័ន្ធប្រជាពលរដ្ឋមូលដ្ឋានរួបរួមគ្នាក្នុងការសហការនានាក្នុងការជម្រុញផែនការទាំងនោះឱ្យមានប្រសិទ្ធិភាព។ យ៉ាងណាក៏ដោយគ្រប់ការអភិវឌ្ឍមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព ការរីកលូតលាស់យ៉ាងណាក៏ដោយគម្រោងទាំងនោះក៏នៅតែមានចន្លោះខ្វះខាតនៅឡើយដោយសារតែគម្រោងអភិវឌ្ឍន៍នេះនឹងក្លាយទៅជាមេរៀន និងការកែលម្អចំពោះយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ក្រុងដោយផ្អែកទៅតាមយន្តការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ។

ដើម្បីឱ្យក្រុងបាត់ដំបង ខេត្តបាត់ដំបងអាចក្លាយជាទិសដៅទេសចរណ៍មួយដ៏ទាក់ទាញ វាត្រូវការនូវវិធានការសកម្មមួយចំនួនចាំបាច់សម្រាប់លូតលាស់។ យុទ្ធសាស្ត្រនិងគំនិតផ្តួចផ្តើមដែលបានបរិយាយក្នុងការអភិវឌ្ឍនេះ នឹងបង្កើតកាលានុវត្តភាពដើម្បីកំណើននិងលើកកម្ពស់សេវាកម្មទេសចរណ៍ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍។ គំនិតផ្តួចផ្តើមនៅក្នុងផែនការអភិវឌ្ឍទេសចរណ៍ក្រុងបាត់ដំបង ២០២១-២០២៥ ដែលផ្តោតសំខាន់លើសក្តានុពលលេចធ្លោក្នុងវិស័យទេសចរណ៍ក្រុងបាត់ដំបង ខេត្តបាត់ដំបងរួមមាន៖ វប្បធម៌បេតិកភណ្ឌនិងកន្លែងទាក់ទាញ ធម្មជាតិនិងស្ទឹង ការសម្រាកនិងកម្សាន្ត ធុរកិច្ចនិងមជ្ឈមណ្ឌលម៉ាយស៍ កីឡាការទិញទំនិញ ការកំណត់តំបន់ ការរៀបចំកញ្ចប់ទស្សនៈកិច្ច ផែនទីបង្ហាញផ្លូវ ផ្លូវថ្មើរជើងនិងផ្លូវជិះកង់ គឺផ្តោតសំខាន់ទៅលើការជម្រុញផលិតផល និងបទពិសោធន៍ទេសចរណ៍។ លទ្ធផលដែលនឹងសម្រេចបានអំពីយុទ្ធសាស្ត្រដែលបានចែងក្នុងផែនការអភិវឌ្ឍន៍ទេសចរណ៍ក្រុងបាត់ដំបង ២០២១-២០២៥នេះ គឺការបង្កើនចំនួនភ្ញៀវទេសចរ រយៈពេលមធ្យមនៃការស្នាក់នៅ និងការចំណាយមធ្យមក្នុងមួយថ្ងៃ។ ជាលទ្ធផល វានឹងបង្កើនចំណូលសម្រាប់ភាគីពាក់ព័ន្ធជាពិសេសសម្រាប់ខេត្តបាត់ដំបង ពិសេសទីក្រុងបាត់ដំបងផ្ទាល់តែម្តង។

ក្រោយពីធ្វើការអភិវឌ្ឍកែលម្អ និងថែរក្សាក្រុងបាត់ដំបងរួមទាំងតំបន់គោលដៅបែបវប្បធម៌ ប្រវត្តិសាស្ត្ររួចមកយើងសង្កេតឃើញថាទាំងជីវភាពប្រជាពលរដ្ឋមូលដ្ឋានមានការប្រែប្រួលកាន់តែល្អប្រសើរឡើង ពួកគាត់បានចូលរួមក្នុងការថែរក្សា និងអភិរក្សនូវហេដ្ឋារចនាសម្ព័ន្ធ សំណង់អគារអភិរក្សនាសម័យមុន និងបានបង្កើតនូវមុខរបរបន្ថែមថ្មីទៀត។ ក្រឡេកទៅមើលហេដ្ឋារចនាសម្ព័ន្ធ និងអនាម័យបរិស្ថានកាលពីមិនទាន់មានការអភិវឌ្ឍ និងគ្រប់គ្រងលើតំបន់គោលដៅក្នុងក្រុង ក៏ដោយជាក្រុងទាំងមូលពុំទាន់មានភាពល្អប្រសើរនៅឡើយ ប៉ុន្តែក្រោយទទួលបានការគ្រប់គ្រង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រូវបានកែលម្អ និងស្ថារ បង្កើតថ្មីជាបន្តបន្ទាប់។ ហេដ្ឋារចនាសម្ព័ន្ធមានការរីកដុះដាលយ៉ាងកុះករសម្រាប់ទទួលភ្ញៀវជាតិនិងអន្តរជាតិឱ្យចូលមកកាន់ក្រុងបាត់ដំបងដោយសម្រួលទៅដល់ការធ្វើដំណើរ ស្នាក់នៅការហូបចុកទាំងប្រជាជនមូលដ្ឋាន និងភ្ញៀវដែលទៅដល់ទីនោះដោយលក្ខណៈងាយស្រួលនិងល្អជាងមុន។ ឯអនាម័យបរិស្ថានមានភាពល្អប្រសើរជាខ្លាំងដោយពុំមានសម្រាមនៅទីសាធារណៈ ដងផ្លូវ និងនៅតាមតំបន់គោលដៅនានានៅក្នុងក្រុងបាត់ដំបង។ តំបន់គោលដៅបែបវប្បធម៌ក៏ត្រូវបានទទួលបានការថែរក្សា និងអភិរក្សប្រកបដោយនិរន្តរភាពដែលអាចបន្សល់ទុកជាកេរដំណែលសម្រាប់ប្រជាជនក៏ដូចជាទេសចរណ៍។

សរុបសេចក្តីមកការអភិវឌ្ឍ និងជម្រុញទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រនាក្រុងបាត់ដំបងពិតជាកំពុងដើរលើមាគ៌ាដែលជោគជ័យ និងឈានទៅរកការអភិវឌ្ឍមួយក៏ពេញលេញ ជាក់ស្តែងប្រសិនបើប្រជាជនមូលដ្ឋានក្រសួងដែលពាក់ព័ន្ធមិនបានចូលរួមក្នុងការការពារ អភិរក្ស និងថែរក្សានូវអ្វីដែលមាន និងលក្ខណៈពិសេសដែលជាក្រុងបែបទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រដ៏មានតម្លៃនោះទេការអភិវឌ្ឍក៏ពុំមានភាពជោគជ័យដែរ។ ដោយការអភិវឌ្ឍទទួលបានជោគជ័យដល់សព្វថ្ងៃគឺដោយមានការជួយជ្រោមជ្រែង និងគ្រប់គ្រងបានយ៉ាងល្អពីសំណាក់ក្រសួងមន្ទីរពាក់ព័ន្ធ ប្រជាពលរដ្ឋមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងឯកជនដែលបានវិនិយោគជាពិសេសពីភ្ញៀវជាតិនិងអន្តរជាតិផងដែរ។ ទោះជាយ៉ាងណាក៏ដោយក៏នៅមានចំណុចខ្វះខាតដែលទាមទារឱ្យមានការបំពេញចន្លោះដែលរួមត្រូវរួមពីយើងគ្រប់គ្នា តាមគ្រប់សកម្មភាពទាំងអស់ដែលអាចធ្វើបានតាមលទ្ធភាពដែលមាន។

## អនុសាសន៍

តាមរយៈការមើលឃើញនូវចំណុចខ្វះខាតខ្លះៗនៅក្នុងក្រុង និងដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍក្រុងបាត់ដំបងឱ្យកាន់តែល្អប្រសើរឡើង យើងខ្ញុំសូមចូលរួមផ្តល់មតិយោបល់តាមរយៈការផ្តល់អនុសាសន៍មួយចំនួនដូចតទៅ៖

- ✓ ការចូលរួមលើកកំពស់ការប្រើប្រាស់ផលិតផលក្នុងស្រុកឱ្យបានកាន់តែច្រើនជាភាពទាក់ទាញសំខាន់មួយក្នុងចំណោមភាពទាក់ទាញទាំងឡាយដែលអាចទាញយកការចាប់អារម្មណ៍ពីភ្ញៀវផលិតផលក្នុងស្រុកអាចបង្ហាញពីអត្តសញ្ញាណមួយរបស់ម្ចាស់តំបន់ផងដែរ។
- ✓ ការពង្រឹងលើផ្នែកគ្រប់គ្រងកាកសំណល់ និងការរក្សាអនាម័យបរិស្ថានដែលជាកត្តាមួយដែលចាំបាច់ក្នុងការផ្តល់ភាពទាក់ទាញរួមទាំងមានជាសុកភាពទៅកាន់ទេសចរណ៍។
- ✓ ការបង្កើតនូវចំណេះដឹងភាសាបរទេសសម្រាប់ទំនាក់ទំនងឱ្យកាន់តែប្រសើរភាសាជាទំនាក់ទំនងមួយសម្រាប់ការប្រាស្រ័យទាក់ទងគ្នាពីជនជាតិមួយទៅកាន់ជនជាតិមួយផ្សេងទៀត ដើម្បីសម្រួលដល់ការទំនាក់ទនងហើយផ្តលសេវាកម្មចំគោលដៅចង់បានរបស់ភ្ញៀវ។

# ឯកសារយោង


- ប្រភពអត្ថបទ៖  ទស្សនាវដ្ដីទេសចរណ៍បាត់ដំបង
- ទេសចរណ៍ ទ្រឹស្ដី និងទស្សនៈជាមូលដ្ឋាន៖ បណ្ឌិត សួន វ៉ានី
- ផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ខេត្តបាត់ដំបង (មន្ទីរទេសចរណ៍ខេត្តបាត់ដំបង)
- រមណីយដ្ឋាន និងគោលដៅទេសចរណ៍ក្នុងខេត្តបាត់ដំបង (មន្ទីរទេសចរណ៍ខេត្តបាត់ដំបង)
- ប្រវត្តិសំខាន់ៗរបស់ខេត្តបាត់ដំបងនាសម័យបាត់ដំបងសម័យលោកម្ចាស់ (រៀបរៀងដោយ ហម អរុណ)
- ផែនការយុទ្ធសាស្ត្រស្ដីពីគម្រោងអភិវឌ្ឍទេសចរណ៍វប្បធម៌ភូមិវត្តគរ (២០២២ដល់២០២៥)
- សេចក្ដីផ្ដើមទេសចរណ៍៖ លោកសាស្ត្រចារ្យ ឈឹម ផាន់ណា
- ភូមិវិទ្យាទេសចរណ៍សម្រាប់ឆ្នាំសិក្សាមូលដ្ឋាន
- គ្រប់គ្រងសាជីវកម្មទេសចរណ៍ដោយ៖ លោកគ្រូ លន់ ពិសិដ្ឋ
- Facebook Page: មន្ទីរទេសចរណ៍ខេត្តបាត់ដំបង
- Web: ebook.elibrary-rule.com
- Web:https://en.m. Wikipedia.org

# ឧបសម្ព័ន្ធ

# កម្រងសំណួរ

# ស្តីពី

# ជម្រុញការទាក់ទាញទេសចរណ៍វប្បធម៌

# ករណីសិក្សាៈ ខេត្តបាត់ដំបង

ជាដំបូងខ្ញុំបាទ/នាងខ្ញុំសូមគោរពជំរាបសួរ លោក លោកស្រី អ្នកនាង កញ្ញា ជាទេសចរជាតិនិងអន្តរជាតិជាទីគោរព នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាប័ត្រ ជំនាញ គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច ឆ្នាំទី៤ ជំនាន់ទី៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពជំរាបថានៅឆ្នាំបញ្ចប់នៃការសិក្សារបស់ពួកខ្ញុំត្រូវធ្វើការសិក្សាស្រាវជ្រាវព្រមទាំងប្រមូលព័ត៌មានដើម្បីទុកជាពុទ្ធិក្នុងការការពារសារណារបស់ពួកខ្ញុំ ហើយដើម្បីសម្រេចបានពួកខ្ញុំត្រូវការចម្លើយខ្លះៗពី លោក លោកស្រី អ្នកនាង កញ្ញា ដែលជាទេសចរជាតិនិងអន្តរជាតិ។

ជាចុងក្រោយ ខ្ញុំបាទ/នាងខ្ញុំសូមអរគុណសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃរបស់អស់លោកអ្នកក្នុងការឆ្លើយតបសំណួររបស់យើងខ្ញុំ។

ចូរគូសសញ្ញា √ ក្នុងប្រអប់ជាចម្លើយរបស់លោកអ្នក។

1. សញ្ជាតិៈ.......................................

2. ភេទៈ ☐ ប្រុស ស្រី ☐

3. អាយុៈ.........

4. មុខរបរ.................................................

5. តើបរិស្ថានតាមតំបន់ទេសចរណ៍នៅក្នុងក្រុងបាត់ដំបងមានលក្ខណៈបែបណាដែរ?

☐ ល្អណាស់ ☐ ល្អ ☐ បង្គួរ ☐ មធ្យម ☐ មិនសូវល្អ

6. តើហេដ្ឋារចនាសម្ព័ន្ធនៅក្នុងក្រុងបាត់ដំបងមានលក្ខណៈបែបណាដែរ?

☐ ល្អណាស់ ☐ ល្អ ☐ បង្គួរ ☐ មធ្យម ☐ មិនសូវល្អ

7. តើអនាម័យតាមតំបន់ទេសចរណ៍ក្នុងក្រុងបាត់ដំបងមានលក្ខណៈបែបណាដែរ?

☐ ល្អណាស់ ☐ ល្អ ☐ បង្គួរ ☐ មធ្យម ☐ មិនសូវល្អ

8. តើអ្នកស្គាល់តំបន់ទេសចរណ៍ក្នុងខេត្តបាត់ដំបងតាមរយៈអ្វី?

☐ ប្រព័ន្ធផ្សព្វផ្សាយ

☐ គ្រួសារ/មិត្តភក្តិ

☐ ខិត្តប័ណ្ណ

9. តើលោកអ្នកធ្វើដំណើរទៅកាន់តំបន់ទាំងនោះដោយរបៀបណា?

☐ រថយន្តផ្ទាល់ខ្លួន

☐ រថយន្តទេសចរណ៍

☐ ម៉ូតូ

☐ ផ្សេងៗ

10.តើលោកអ្នកទៅកម្សាន្តនៅទីនោះក្នុងគោលបំណងអ្វី?

☐ សម្រាកលំហែរ ☐ សិក្សាស្រាវជ្រាវ ☐ ការងារ

☐ មកលេងសាច់ញាតិ

11. តើអ្នកចូលចិត្តមកកម្សាន្តតំបន់បែបណាក្នុងខេត្តបាត់ដំបង?

☐ តំបន់ភ្នំ

☐ តំបន់វប្បធម៌ប្រវត្តិសាស្ត្រ

☐ តំបន់រមណីយដ្ឋាន

☐ តំបន់ធម្មជាតិ

12.នៅក្នុងក្រុងបាត់ដំបងសម្បូរទៅដោយទេសចរណ៍ប្រភេទណា?

☐ ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

☐ ទេសចរណ៍សម្រាកលំហែរ

☐ ទេសចរណ៍ធុរកិច្ច

☐ ទេសចរណ៍សិក្សាស្រាវជ្រាវ

13. តើលោកអ្នកចូលចិត្តមកកម្សាន្តក្នុងឱកាសណា?

☐ ចុងសប្តាហ៍ ☐ ពិធីបុណ្យនានា ☐ ផ្សេងៗ

14. តើតំបន់ទាំងនោះមានសេវាកម្មបម្រើដល់ទេសចរណ៍អ្វីខ្លះ?

☐ ស្នាក់នៅ

☐ ម្ហូបអាហារ

☐ កម្សាន្ត

☐ ការដឹកជញ្ជូន

☐ ផ្សេងៗ

15. តើលោកអ្នកពេញចិត្តចំពោះសេវាកម្មបម្រើដល់ទេសចរណ៍កម្រិតណា?

☐ ពេញចិត្តណាស់

☐ ពេញចិត្ត

☐ បង្គួរ

☐ មធ្យម

☐ មិនសូវពេញចិត្ត

16. តើលោកអ្នកយល់ថាសេវាកម្មសម្រាប់បម្រើដល់ទេសចរតាមតំបន់ទេសចរណ៍នៅខេត្តនេះគ្រប់គ្រាន់ហើយឬនៅ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

17. តើលោកអ្នកមកទស្សនាតំបន់ទាំងនោះរយៈពេលប៉ុន្មានថ្ងៃ?

☐ មួយថ្ងៃ ☐ ពីរថ្ងៃ ☐ លើសពីពីរថ្ងៃ

18. តើលោកអ្នកយល់យ៉ាងណាចំពោះសន្តិសុខសុវត្ថិភាពនៅតាមតំបន់ទេសចរណ៍នៅក្នុងខេត្តនេះ?

☐ ល្អណាស់ ☐ ល្អ ☐ បង្គួរ ☐ មធ្យម ☐ ខ្សោយ

19. បើមានឱកាសលោកអ្នកនឹងត្រឡប់មកទស្សនាម្តងទៀតដែរឬទេ?

☐ មកម្តងទៀត

☐ មិនប្រាកដ

☐ មិនមក

20. តើលោកអ្នកយល់យ៉ាងណាចំពោះការផ្សព្វផ្សាយរបស់តំបន់ទេសចរណ៍ក្នុងខេត្តនេះ?

☐ ល្អណាស់ ☐ ល្អ ☐ បង្គួរ ☐ មធ្យម ☐ ខ្សោយ

21. តើអ្នកស្គាល់តំបន់ទេសចរណ៍បែបវប្បធម៌ដែរឬទេ?

☐ ស្គាល់ ☐ មិនស្គាល់

22. តើខេត្តណាមួយដែលសម្បូរទៅដោយទេសចរណ៍វប្បធម៌?

☐ ខេត្តកណ្តាល ☐ ខេត្តបាត់ដំបង ☐ ខេត្តក្រចេះ ☐ ខេត្តកែប

23. តើលោកអ្នកមានមតិយោបល់យ៉ាងណាចំពោះការអភិវឌ្ឍតំបន់ទេសចរណ៍ក្នុងខេត្តនេះ?

.....................................................................................................................................

.....................................................................................................................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ**

យើងខ្ញុំឈ្មោះ **ធុច វត្តនា** និងឈុន **គីមឡេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច ឆ្នាំទី៤ ជំនាន់ទី៨ ក្រុមT4A01 ឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**សូមគោរពជូន**

**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត**

**និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ ។

តាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា បន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេរសារណា និងការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី <<**ជុំវិញការទាក់ទាញទេសចរណ៍វប្បធម៌ ករណីសិក្សាខេត្តបាត់ដំបង**>> ដោយត្រូវចុះស្រាវជ្រាវឯកសារនៅ មន្ទីរទេសចរណ៍ខេត្ត បាត់ដំបង ចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២។

អាស្រ័យហេតុនេះសូម **ឯកឧត្តម** មេត្តាអនុញ្ញាតឲ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២

ហត្ថលេខា

ធុច វត្តនា　　　　ឈុន គីមឡេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**បញ្ជីរាយនាម**
**និស្សិតថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច**
**ឆ្នាំទី៤ ជំនាន់ទី៨ ក្រុមT4A01 ឆ្នាំសិក្សា ២០២១-២០២២**
**ដែលត្រូវចុះស្រាវជ្រាវឯកសារ នៅមន្ទីរទេសចរណ៍ ខេត្តបាត់ដំបង**

| ល.រ | គោត្តនាម នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ធុច វត្តនា | ស្រី | ២៥-មេសា-២០០០ | 097 844 5666 | |
| ២ | ឈុន គឹមឡេង | ប្រុស | ២៨-ធ្នូ-១៩៩៥ | 096 699 0240 | |

ថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២
**ប្រធានការិយាល័យស្រាវជ្រាវ**

ញឹក_វុទ្ធី

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
លេខ...[illegible]...ស.ភ.ន.វ.ស

ថ្ងៃ [illegible] ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២២

**ជម្រាបជូន**
**លោកប្រធានមន្ទីរទេសចរណ៍ ខេត្តបាត់ដំបង**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន០២រូប ចុះស្រាវជ្រាវឯកសារ។

**យោង៖** សំណើរបស់សាមីនិស្សិតចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូន **លោកប្រធានមន្ទីរ** ជ្រាបថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួន០២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី **«ជំរុញការទាក់ទាញទេសចរណ៍វប្បធម៌ករណីសិក្សាខេត្តបាត់ដំបង»** នៅមន្ទីរទេសចរណ៍ ខេត្តបាត់ដំបង ចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធានមន្ទីរ** ពិនិត្យលទ្ធភាពអនុញ្ញាតឱ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម **លោកប្រធានមន្ទីរ** ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

**ជ.សាកលវិទ្យាធិការ**
**សាកលវិទ្យាធិការរង**

**យិត-សុវុទ្ធ**

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh



រូបភាពទី១១ ៖ ថ្ងៃទី១ នៃការជួបជាមួយបងៗនៅមន្ទីរទេសចរណ៍ខេត្តបាត់ដំបង



រូបភាពទី១២៖ ថ្ងៃទី១ នៃការជួបជាមួយបងៗនៅមន្ទីរទេសចរណ៍ខេត្តបាត់ដំបង



រូបភាពទី១៣៖ ថ្ងៃទី២ នៃការជួបជាមួយបងៗនៅមន្ទីរទេសចរណ៍ខេត្តបាត់ដំបង



រូបភាពទី១៤៖ ផ្ទះបុរាណភូមិវត្តគរ ផ្ទះខ សង(លោកយាយបានរៀបរាប់ពីប្រវត្តិផ្ទះ)



រូបភាពទី១៥៖ ផ្ទះបុរាណភូមិវត្តគរ ផ្ទះប៉ិត



រូបភាពទី១៦៖ ឧបករណ៍នៅខាងក្រោម ផ្ទះបុរាណភូមិវត្តគរ ផ្ទះប៉ិត




រូបភាពទី១៧៖ របងសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង




រូបភាពទី១៨៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសំណង់អគារបារាំង




រូបភាពទី១៩៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសំណង់អគារបារាំង



រូបភាពទី២០៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសារមន្ទីរវប្បធម៌



រូបភាពទី២១៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសារមន្ទីរវប្បធម៌


រូបភាពទី២២៖ ការសម្ភាសន៍ទេសចរដែលមកកម្សាន្តនៅសំណង់អគារបារាំង



រូបភាពទី២៣, ២៤៖ ផ្ទះបុរាណផ្ទះប៊ិត

